## វគ្គទី១១

## ភ្លើងស្នេហ៍ ភ្លើងកំហឹង

ស្រមោលរាត្រីកាលឈានចូលមកដល់សន្សឹមៗ។ រាត្រីទីមួយនៅក្រុងចាយាពូរ៉ាពិតជាគួរឲ្យទាក់ចិត្ត ដោយសារទិដ្ឋភាពភ្លើងចម្រុះពណ៌ដែលអ្នកផងមិនដែលនឹកស្មានថាទីក្រុងដែនកោះដ៏ឆ្ងាយមួយរបស់ខេត្តប៉ាពួ អាចមានសោភ័ណភាពថ្នាក់នេះ។

នៅក្នុងបន្ទប់មួយនៃផ្ទះបុរាណ នាយBirdកំពុងឈរតាមដានស្តាប់បញ្ជាថ្មីពីលំអងដោយស្ងៀមស្ងាត់។ រហូតចប់ការណែនាំ ទើបអង្គរក្សបង្កប់ខ្លួនរូបនេះនិយាយតបវិញ៖

-ខ្ញុំយល់ហើយ! បានន័យថាឲ្យតែពេលដែលរាមនរិន្ទដឹងរឿងហើយផ្ទុះកំហឹងធ្វើអ្វីមួយខុសច្បាប់ភ្លាម ខ្ញុំមានតួនាទីថតយកសកម្មភាពអស់ហ្នឹងដើម្បីជាភស្តុតាងប្តឹងគេ។

លំអងងក់ក្បាលផ្ងក់ៗ៖

-ឆាប់យល់អញ្ចឹងល្អហើយ!

នាយ Birdសួរវិញភ្លាម៖

-តែចាត់ការពេលណាទៅ?

លំអងប្រញាប់ឆ្លើយវិញ៖

-យើងអត់ពេលច្រើនទេ! បន្តិចទៀតនេះរាមនរិន្ទ និងឌីម៉ាត្រឡប់មកពីដើរលេងវិញពួកគេនឹងបែកគ្នា! ខ្ញុំចូលទៅខាងប្រុសនិយាយដុតគេ ចំណែកពេលគេជឿសម្តីខ្ញុំនឹងនាំគេមកបន្ទប់នាង! ឯងត្រូវឲ្យសញ្ញាទៅបងKenដើម្បីឲ្យគាត់ទូរសព្ទមក! ពេលនោះបងKenនឹងនិយាយជាមួយកេតឌីម៉ាដើម្បីឲ្យនាងនិយាយរៀបរាប់ពីល្បិចកលរបស់នាងក្នុងការបង្កប់ខ្លួននៅទីនេះ។ ពេលរាមនរិន្ទមកដល់គេនឹងគិតថាប្រុសម្នាក់ទៀតដែលកំពុងនិយាយទូរសព្ទជាមួយឌីម៉ាជាសិទ្ធិគុណ។

ដោយមិនសូវទុកចិត្តBirdសួរវិញភ្លាម៖

-លោកប្រុសរាមម៉ត់ចត់ម្លឹងៗ ល្បិចស្វាវាស៊ីបាយលាបមាត់ពពែនេះទៅរួចទេ?

លំអងបង្ហាញជំនឿចិត្តតាមរយៈទឹកមុខ៖

-បុរសឆ្លាតយ៉ាងណាក៏ដោយ ឲ្យតែភ្លើងប្រចណ្ឌចូលដល់ហើយ គឺរលាយប្រាជ្ញាអស់ហើយ!

-ចុះខាងសិទ្ធិគុណ? បើរាមនរិន្ទខឹងដល់ផ្តាច់ជីវិតកេតឌីម៉ាមែន មានរឿងអីសិទ្ធិគុណព្រមតតាំងឈ្លោះជាមួយរាមនរិន្ទដោយចេញមុខប្តឹងគេនោះ?

លំអងក្រពាត់ដៃសើចៈ

-អភិជនស្ទើរភ្លើងហ្នឹងគ្រាន់បើមួយជាតិហើយ បែរជាមកងប់សម្រស់ស្រីដែលគេមិនស្រលាញ់ខ្លួន! គេតាមមកដល់ចាយ៉ាពូរ៉ាដោយសារបងKenប្រើល្បិចថាកេតឌីម៉ាគឺត្រូវរាមនរិន្ទធ្វើបាប នាងរស់ដូចស្លាប់។ សិទ្ធិគុណឮហើយពុះកញ្ជ្រោលណាស់! គេត្រូវរកវិធីដើម្បីជួយកេតឌីម៉ា! បើយប់នេះរាមនរិន្ទច្រឡោតដល់ថ្នាក់ជ្រុលដៃនោះ អ្នកឈឺចាប់បំផុតគឺសិទ្ធិគុណ! យើងចាំតែឱបដៃមើលចុះ!

នាយBirdងក់ក្បាលផ្ញក់ៗ ក្នុងក្តីសង្ឃឹមថាសភាពការណ៍ហាក់បីដូចជាកំពុងស្ថិតនៅក្នុងគន្លងល្អប្រសើរដូចគម្រោងការដែលបានរៀបមកដោយម៉ត់ចត់។ ដោយសារនាយKen ដែលពួននៅទីងងឹត បានបង្កើតពាក្យចចាមអារ៉ាមមួយចំនួនស្តីពីពិធីដេញថ្លៃតន្ទបដិមា ធ្វើឲ្យនាយរឿនអង្គរក្សឆ្លាតជាងគេរបស់រាម នរិន្ទ ត្រូវចេញទៅស៊ើបដូចពន្លែងទីនេះអោយពួកខ្លួនអាចធ្វើអ្វីតាមចិត្តចង់។

គេញញឹមក្នុងខណៈដែលលំអងឈានចាកចេញទៅ។ នាងនិយាយជាចុងក្រោយៈ

-ត្រៀមទៅ! យប់នេះមានរឿងល្អមើលហើយ!

នៅឯណេះស្រស់ស្រី ឌីម៉ា មិនដឹងទាល់តែសោះថា ជីវិតកំពុងស្ថិតដល់ដំណាក់កាលគ្រោះថ្នាក់។ ត្រឡប់មកពីបឹងសេនតានី នាងដើរមួយៗបែកពីរាម នរិន្ទមកកាន់ទីសម្រាកវិញ។ នាយBirdស្ថិតនៅក្នុងសួនច្បារធ្វើជាដើរយាមចុះឡើង ប៉ុន្តែតាមពិតគឺរង់ចាំឲ្យតែលំអងចូលទៅរាយការណ៍ក្នុងកន្លែងរាមនរិន្ទចេញមកវិញពេលណា គេនឹងឲ្យសញ្ញាទៅនាយKenដើម្បីឲ្យនាយនោះទូរសព្ទមករកកេតឌីម៉ា។

ដូចបានគិតទុក មិនដល់១០នាទីផង គេបានឃើញរាមនរិន្ទដើរដោយស្វាហាប់សំដៅមកកាន់ទីកន្លែងរបស់កេតឌីម៉ា។ នាយBirdដឹងថាគឺរាមនរិន្ទត្រូវបានលំអងផ្លុំត្រចៀករួចរាល់ហើយ ទើបបានគេឆេះដុំមិនខ្វំគិតយូរក៏ដើរមករកនារីស្នេហ៍ដើម្បីបញ្ជាក់ការពិត។

អង្គរក្សបង្កប់ប្រញាប់ឲ្យសញ្ញាទៅនាយKenភ្លាមដែរ។ បានដូចគិត គឺរាមនរិន្ទបានឈានមកដល់មាត់ទ្វារបន្ទប់កេតឌីម៉ា ចំពេលនាងកំពុងនិយាយទូរសព្ទដោយទឹកមុខផ្អែមល្ហែម។

-អត់ទេ! គ្រាន់តែថ្ងៃនេះគេនាំអូនទៅលេងបឹងសេតានី ហើយគេនិយាយថាចង់ឲ្យអូននៅចាយាពូរ៉ាជាមួយគេរហូតដល់ការងារគេចប់!

ឃ្លាឃ្លោងរបស់នារីបង្ហាញម៉ូតធ្វើឲ្យអ្នកប្រុសរូបសង្ហាទប់ជំហានង៉ក់នៅត្រឹមទីតាំងដែលល្មមឲ្យអ្នកស្តាប់ឮការសន្ទនាទាំងនេះបាន។ តាមពិតអ្វីៗត្រូវបានលំអង និងនាយ Birdរៀបចំជាស្រេចហើយ ដូច្នេះកេតឌីម៉ាគឺកំពុងប្រើវាចាផ្អែមល្ហែមតាមទូរសព្ទពីក្រោមក្រសែភ្នែកក្តៅ១៨០អង្សាររបស់រាមនរិន្ទ។

លំអងដែលទើបតែមកតាមពីក្រោយរាមនរិន្ទនៅឈរមើលពីក្នុងសួនទៅ ប៉ុន្តែនាងដឹងថា ជាមួយទឹកមុខនឹងថ្កល់តែសស្លេកដោយភ្លើងកំហឹងនោះ កេតឌីម៉ាមានមាត់១០ក៏ពិបាកជជែកការពារខ្លួនដែរ។ លំអងស៊ីញ៉ូឲ្យនាយBirdត្រៀមថតសកម្មភាពរាមនរិន្ទ ប៉ុន្តែអ្នកទាំងពីរត្រូវខកចិត្តខ្សុលដោយសារថាភ្លាមនោះ អភិជនរូបសង្ហាបែរបកត្រឡប់ក្រោយ និងបោះជំហានចាកចេញទៅវិញ។

"ដល់ថ្នាក់នេះហើយគេនៅមិនធ្វើអីកេតឌីម៉ាទៀត? "លំអងខ្ទប់មាត់ទាំងអារម្មណ៍វិលខ្វាល់ក្នុងពេល

នាយBirdទៅជាចំហមាត់ផ្លុង។

"រាមនរិន្ទស្រលាញ់កេតឌីម៉ាមែនទែនហើយ? "លំអងគិតមុនពេលស្ទុះចេញទៅតាមពីក្រោយរាមនរិន្ទ ដើម្បីឲ្យដឹងថាគេប្រុងធ្វើម៉េចចំពោះកំហឹងនេះ។ នាងឃើញបុរសមាឌធំមាំដែលកំពុងខូចចិត្តដោយសារត្រូវនារីមុខស្លូតម្នាក់លេងល្បិចបោកបញ្ឆោតនោះ ត្រឡប់ទៅក្នុងបន្ទប់ធំហើយចាក់ទឹកក្រេបក្អឹក។

"តាមពិតលោកចង់យកទឹកត្រជាក់មករំងាប់កំហឹងឬរាមនរិន្ទ? "លំអងគិតស្ងាត់ៗ។ នាងឈានទៅជិតគេសាជាថ្មីដើម្បីមើលឲ្យដឹងប្រតិកម្មរបស់គេ។ ប៉ុន្តែសូរព្រោកប្រាកម្យ៉ាងធ្វើឲ្យនាងត្រូវឱនទៅពិនិត្យតាមប្រភពសូរសំឡេង។ រាមនរិន្ទឈរបែរខ្នង ប៉ុន្តែលំអងអាចស្មានដឹងថាគេប្រហែលខឹងស្ទើរស្រក់ឈាមតាមភ្នែកហើយ  ព្រោះថាដៃគេដែលកាន់កែវទឹកនោះត្រូវមុតអំបែងហូរឈាមស្រម៉ក ប៉ុន្តែគេនៅមិនឃើញរំញោចឈឺចុកចាប់សោះ។

"លោកក៏ចេះឈឺចិត្តដល់ថ្នាក់នេះដែររាមនរិន្ទ? "លំអងគិតបណ្តើរ ដៃជើងចាប់ផ្តើមភ័យញ័រដោយសារនាងដឹងថារាមនរិន្ទទប់ចិត្តមិនបញ្ចេញប្រតិកម្មភ្លាមៗ តែកំហឹងនោះអាចឲ្យគេច្របាច់កែវទឹកអ៊ីតាលីមួយបែកខ្ទេចនៅនឹងកែវភ្នែកនាង ល្មមអាចឲ្យនាងដឹងប្រាកដហើយថា នាយKenគិតត្រូវដែលប្រើវិធីនេះ។

ក្នុងវិនាទីដែលលំអងកំពុងពិភាល់ សំឡេងរាមនរិន្ទលាន់មកត្រជាក់ស្រែងៈ

-ខ្ញុំទុកពេលឲ្យនាង១០នាទីចេញពីកន្លែងនេះលំអង! មុនពេលខ្ញុំដូរចិត្ត!

លំអងថយក្រោយក្រាក ប៉ុន្តែនាងនៅតែចង់ដឹងពីវាសនាកេតឌីម៉ា។ នាងនិយាយតិចៗរញ្ជីរញ្ជ័រ៖

-លោកប្រុសរាម! ចុះ...ចុះឌីម៉ា?

រាមនរិន្ទងាកមករកនារីបង្ហាញម៉ូត គេសើចដាក់នាងបន្តិច តែជាសំណើចដែលលំអងឃើញហើយថ្លោះទឹកមុខ។ បេះដូងនាងកំពុងលោតញាប់តែនាងនៅស្ដាប់ឮសម្ដីត្រជាក់ស្រឹបរបស់គេ៖

-គ្មានអ្នកណាអាចនាំស្រីម្នាក់ហ្នឹងចេញពីកន្លែងនេះបានទេ!

នាងដឹងថាគេចង់សំដៅលើសិទ្ធិគុណ ព្រោះក្នុងភ្នែកគេមានតែកំហឹងនិងការខូចចិត្ត។ លំអងមិនចម្លែកទេ ព្រោះថាជាលើកដំបូងដែលបុរសអភិជនប្រកបដោយកេរ្តិ៍ឈ្មោះបានស្ម័គ្រឱនមកមេត្រីស្រីអ្នកសិល្បៈម្នាក់ ដោយសារចាញ់ប្រៀបភាពស្លូតត្រង់ និងថ្លៃថ្នូររបស់នាង ប៉ុន្តែការទទួលអារម្មណ៍ភ្លាមៗថាចាញ់បញ្ឆោតគេ មិនមែនជារឿងល្អសម្រាប់មុខមាត់ប្រុសទ្រង់ប្រាំហត្ថម្នាក់ទេ។ រាមនរិន្ទចិត្តធ្ងន់យ៉ាងណាក៏ទប់ទល់ចំពោះកំហឹង និងភាពអាម៉ាស់នេះមិនជាប់ដែរ។

"ឯងអាចស្លាប់ដូចគេគម្រោងការណ៍របស់បងKenមែនដែរទេឌីម៉ា?"

នាងឈានជើងចាកចេញមួយៗព្រោះនាងមានពេលតែ១០នាទីប៉ុណ្ណោះ ប្រសិនមិនដូច្នេះទេរាមនរិន្ទអាចដូរចិត្តនាងក៏អាចរងទុក្ខពីបទរួមដៃបោកប្រាស់នាយដែរ។ ការខកចិត្តចំពោះព័ត៌មានឥន្ទបដិមាត្រូវបែកខ្ចរខ្ចាយដោយការក្បត់របស់កេតឌីម៉ាប្រាកដជាអាចរុញឲ្យរាមនរិន្ទធ្វើអ្វីម៉្យាងដែលគេមិនធ្លាប់ធ្វើពីមុនមក។ ដូច្នេះការនិទស្សន៍របស់Kenដែលថារាមនរិន្ទអាចនឹងមានពិរុទ្ធមុនពេលពិធីដេញថ្លៃមកដល់នោះ ប្រាកដជាអាចទៅរួច៩០%។ លំអងបែរក្រោយមករករាមនរិន្ទសាជាថ្មីទោះបីនាងគ្មានពេលច្រើនក៏ដោយ។ នាងនិយាយឡើងដោយទឹកមុខអង្វរករ៖

-លោកប្រុសរាម! បើលោកប្រុសចង់សងសឹក គួរតែសិទ្ធិគុណមិនមែនកេតឌីម៉ាទេ! ខ្ញុំសូមអង្វរ!

រាមនរិន្ទរក្សាផ្ទៃមុខស្មើ គេងាកទៅរកកងការពារពីរនាក់ដែលនៅរវោក្បែរនោះដោយទឹកមុខតក្កមាដូចគ្នា។

-នាំកេតឌីម៉ាទៅចាំខ្ញុំនៅបន្ទប់ខាងលើ! ហើយនាំស្រីនេះចេញពីកន្លែងនេះភ្លាម!

ម្នាក់ចាកចេញទៅតាមបទបញ្ជា ម្នាក់ទៀតស្ទុះមករកលំអង។ នាងដឹងថាគេឲ្យនាងទៅព្រោះនាងបានរាយការណ៍ប្រាប់គេថានាងត្រូវឌីម៉ាបង្ខំឲ្យធ្វើពុតជាត្រូវចាប់ជំរិត និងបាត់លិខិតឆ្លងដែនដើម្បីបានមកកាន់ទីនេះ។ បន្ទាប់មកឌីម៉ាបានផ្ដល់ដំណឹងទៅឲ្យសិទ្ធិគុណដែលជាគូស្នេហ៍លួចលាក់

របស់នាង។ គាប់ជួនរាមនរិន្ទចង់បញ្ជាក់ការពិតជាមួយឪម៉ាគេក៏ស្ទុះរឹងទៅរកនាងដល់បន្ទប់ ចំពេលនាងកំពុងផ្អែមល្ហែមតាមទូរសព្ទទៀត អន្ទាក់មួយនេះអាចទាក់បានបុរសមកពីគ្រួសារអ្នកនយោបាយដូចដែលបានគ្រោងទុកមែន។ ប៉ុន្តែដែលសំខាន់គឺពេលនេះលំអងបែរជាមិនដាច់ចិត្តឲ្យឪម៉ាស្លាប់ទេ។ មិត្តភាពស្មោះស្ម័គ្ររបស់នាងបានធ្វើឲ្យនារីមានពិសរំភើបចិត្ត តែប្រសិនបើលំអងមិនធ្វើតាមKenគម្រោងការណ៍ឥន្ទបដិមាក៏អាចថាមិនបានសម្រេច ម្ល៉ោះហើយនាងមានតែធ្វើតាមគម្រោងនេះ គ្រាន់តែបង្វែរសាច់រឿងឲ្យធូរស្រាលបន្តិច ដោយមានចេតនាឲ្យសិទ្ធិគុណជាអ្នករងគ្រោះធំជាងគេវិញ។

ទោះបីត្រូវទាញបង្ខំដោយកងការពារ ប៉ុន្តែនាងនៅតែជម្ទះនិយាយ៖

-លោកប្រុសរាម កេតឪម៉ានៅក្មេង ហើយល្ងង់ទៀត! ចាញ់បោកគេដោយសារប្រាជ្ញាគ្មាមិនដល់សិទ្ធិគុណ បានជាត្រូវគេបោកប្រើ! លោកប្រុសគួរតែចាត់ការសិទ្ធិគុណវិញ!

គេគ្មានសញ្ញាថាធូរស្រាលកំហឹងពីផ្ទៃមុខទេ។

លំអងចាកចេញទៅរកKenតាមគម្រោងដែលបានគ្រោងទុក ព្រោះនាងចប់ការងារហើយប៉ុន្តែអ្នកដែលនៅសល់គឺឪម៉ាដែលទើបតែរីករាយធូរស្រាលចិត្តបន្ទាប់ពីបាននិយាយសាសងតាមទូរសព្ទជាមួយប្រុសស្នេហ៍។ នាងត្រូវបានកងការពារតាមឲ្យទៅជួបរាមនរិន្ទ នាងក៏ចេញមកតាមបទបញ្ជាតែក៏មិនមានពិភាល់ថាខ្លួននិងអាចជួបរឿងអកុសលអ្វីនោះដែរ ព្រោះថាទើបតែជួបគ្នានៅបឹងសេនតានីមុននេះ គេក៏មិនឃើញមានអ្វីទោមនស្សចំពោះនាងផង។

មកដល់បន្ទប់ជាន់ខាងលើនៃបរិវេណផ្ទះហិណ្ឌូធំជង្គ្រោង នាងដើរចូលទៅរកគេដូចធម្មតាខណៈដែលរាមនរិន្ទនៅអង្គុយបង់ចំខែងនៅលើគ្រែផ្តៅ។ ទឹកមុខស្មើសស្លេករបស់គេ បានធ្វើឲ្យនាងចម្លែកចិត្ត ប៉ុន្តែប្រអប់ដៃស្តាំដែលហូរឈាមរឹមៗពាសពេញបាតដៃធ្វើអោយនាងទៅជារន្ធត់។

នាងដើរតម្រង់ទៅរកគេដោយមិនដឹងខ្លួន។ កែវភ្នែកអ្នកគ្រូបង្ហាញម៉ូតផ្តោតសម្លឹងទៅបាតដៃបុរសនោះ ក្នុងពេលក្រសៃភ្នែកមួហ្មងរបស់រាមនរិន្ទផ្តោតមកលើវង់ភក្ត្រនាង។ ស្រស់ស្រីកេតឪម៉ាដកភ្នែកចេញពីរបួសរបស់គេហើយងើបមុខចង់សួរគេថាហេតុអ្វីបានជាមានរបួស ប៉ុន្តែពេលមកប៉ះក្រសៃភ្នែកសម្លក់របស់គេ នាងទៅជាគាំងចលនា។

ស្គាល់រាមនរិន្ទប៉ុន្មានខែមកហើយ នេះជាលើកដំបូងដែលនាងឃើញពន្លឺភ្នែកគេកាចដល់ថ្នាក់នេះ។ ទើបតែបែកពីគ្នាប៉ុន្មាននាទីសោះ ហេតុអ្វីអារម្មណ៍គេផ្លាស់ប្តូរម្លឹងៗ? គេសម្លឹងមកនាងត្លៃមិន

ប៉ប្រិចភ្នែកហាក់កំពុងចាក់ទម្លុះកែវភ្នែកនាងដែលកំពុងប្រឈមគ្នា។ បបូរមាត់បុរសសង្ហា មិនមានស្នាមញញឹមទៀតទេ ហើយដង្ហើមរបស់គេប្រែទៅជាញាប់។

"គេមកពីខឹងឈ្លោះនឹងអ្នកណានេះ? "នាងដណ្ដឹងសួរខ្លួនឯង។

នាងបែរខ្លួនចាកចេញក្នុងបំណងរកឧបករណ៍ដោះស្រាយមុខរបួសជាចម្បងសិន ប៉ុន្តែត្រូវគេចាប់ដៃទាញមកវិញ។ ប្រអប់ដៃឆ្វេងដែលរឹងដូចដង្កាប់ក្ដាប់កំភួនដៃខ្លួនធ្វើឲ្យកេតឌីម៉ាឈឺដល់ថ្នាក់ភ្លាត់មាត់អូយហើយគេនៅតែមិន ពន្លែង បែរជាសម្លឹងមុខនាងថ្ងៃ។ តរុណីខំនិយាយទៅរកគេតិចៗទោះមិនស្រួលក្នុងចិត្តក៏ដោយៈ

- ខ្ញុំទៅរកថ្នាំមកលាបរបួសឲ្យទេតើ!

គេមិនត្រឹមមិនលែងដៃនាង តែបានប្រើកម្លាំងទាញខ្លួនប្រាណនាងទាំងស្រុងមកផ្ដួលលើទីដំណេក។

-វាមិនស្លាប់ទេត្រឹមរបួសប៉ុណ្ណឹងនោះ!

សំឡេងគ្រោតគ្រាតហាក់មិនមែនរាមនរិន្ទពីមុនមកសោះ បានធ្វើឲ្យនារីទៅជាស្រលាំងកាំង។ ទម្រាំនាងប្រមូលអារម្មណ៍បានមកវិញរាងកាយទាំងមូលកំពុងស្ថិតនៅក្រោមកម្លាំងសង្កត់របស់គេទាំងស្រុង ធ្វើឲ្យស្រស់ស្រីទៅជាភ័យរន្ធត់។ ផ្ទៃមុខសោះកក្រោះរបស់ នាយកំពុងនៅ ចំពីមុខកែវភ្នែកនាងជិតដល់ថ្នាក់សូម្បីខ្យល់ដកដង្ហើមរបស់គេក៏ភាយប៉ះច្រមុះនាង។នៅពេលដែលកេតឌីម៉ាបង្អួសក្រសៃភ្នែកមកប៉ះបបូរមាត់នាយ នាងដឹងថាបបូរមាត់ដែលធ្លាប់តែស្វាគមន៍មកកាន់នាងនូវស្នាមញញឹមស្រស់ សង្ហាកំពុងខាំស្ទើរដាច់ចេញជាឈាម ។ វាដូចជាមិនមែនជាសញ្ញាគគ្រឹតក្នាញ់ទេ ។

"តើយើងបានធ្វើ អីខុស"នាងសួរខ្លួនឯង។

ដង្ហើមអ្នកប្រុសកាន់តែញាប់ ហើយភ្នែកទាំងគូរប្រែទៅជាពណ៌ក្រហមបង្ហាញថាគេមិន អាចគ្រប់គ្រងខ្លួនឯងបានទៀតទេធ្វើអាយមាណវីជម្នះរុញរាងកាយធំមាំនោះចេញអស់មួយទំហឹង ប៉ុន្តែនាងកាន់តែរុញគេកាន់តែចចេស។

-នៅឲ្យស្ងៀមណ៎ាបើមិនចង់ឈឺខ្លួន!(គេនិយាយក្បែរស្លឹកត្រចៀកនាង)

"សូម្បីសំឡេងដែលបញ្ចេញ មកក៏ហាក់គ្មានមនោសញ្ចេតនាដែរយើងកំពុងត្រូវគេរំលោភបំពានច្បាស់ណាស់។ហេតុអ្វីសុខៗមនុស្សទន់ភ្លន់ម្នាក់ក្លាយទៅជាកម្រោលចូលទៅកើត? "

កេតឌីម៉ាស្រក់ទឹកភ្នែកច្រោកក្នុងពេលដែលនាងគ្មានកម្លាំងតស៊ូជាមួយកំហឹងរបស់រាមនរិន្ទ។ ប៉ុន្តែលើកនេះទឹកភ្នែករបស់នាងអត់មានប្រសិទ្ធភាពឲ្យគេទន់ចិត្តទេ។

សកម្មភាពនានារបស់នាងរាប់ចាប់តាំងពីពេលដើរចោលសិទ្ធិគុណនៅកោះបាលីក្នុងភោជនីយដ្ឋានការលេបថ្នាំងងុយដេកខ្លួនឯងនៅអាម៉ាន់ដារី ការយំសស្រាក់ហើយរត់មកប្រាប់ថាលំអងត្រូវគេចាប់ជំរិត និងចុងក្រោយនាងគោះទ្វារចូលទៅរកគេទាំងម៉ោងមួយរំលងអាធ្រាត្រដើម្បីសុំមកចាយាពូរាជាមួយ លេចឡើងភ្លឹបភ្លែតក្នុងអារម្មណ៍រាមនរិន្ទ។ គេចាត់ទុកថាទាំងនោះសុទ្ធតែជាឆាកល្ខោនដែលត្រូវបានរៀបចំឡើងតែប៉ុណ្ណោះហើយវាត្រូវបានដើរតួដោយអ្នកសម្ដែងអាជីពដែលធ្វើឲ្យសូម្បីរាមនរិន្ទក៏ចាញ់បោកបាន។ ទំហំចិត្តស្រលាញ់ធំប៉ុណ្ណា កំហឹងក៏មានធំប៉ុនគ្នារហូតដល់នរិន្ទភ្លេចខ្លួនថាគេកំពុងញាំញីនារី តូចខ្សោយដែលគ្មានមធ្យោបាយការពារខ្លួន។

-លោកប្រុសរាម! ខ្ញុំសូមអង្វរ! លែងខ្ញុំ...

ដូចដែលរាមនរិន្ទបានប្រាប់លំអងនៅជាន់ខាងក្រោមកាលពីមុននេះហើយ គ្មានអ្នកណាម្នាក់អាចយកកេតឌីម៉ាចេញពីភ្នក់ភ្លើងកំហឹងរបស់នាយឡើយ សូម្បីតែសម្ដីទន់អង្វររបស់ម្ចាស់ខ្លួនល្វតល្វៃនេះក៏ដោយ។

បបូរមាត់នាងដែលបង្ហើរចេញនូវពាក្យផ្អែមល្ហែមអួនបងដូចទឹកឃ្មុំតាមទូរសព្ទអម្បាញ់មិញនៅតែឮជាប់ក្នុងត្រចៀកបុរសម្ចាស់បន្ទប់។ នរិន្ទត្រូវគ្របសង្កត់ដោយក្ដីអាម៉ាស់ដែលថា ហេតុអីសូម្បីតែបានរាត្រីទីមួយពីនាងហើយនៅតែបណ្ដោយឲ្យបេះដូងនាងបានទៅប្រុសផ្សេងដែលល្បីឈ្មោះខាងច្រឡោងខាមនោះទៅវិញ?

"សិទ្ធិគុណវាទិញបេះដូងនាងបានដោយទឹកលុយប៉ុន្មានកេតឌីម៉ា? នាងមានជីវិតប៉ុន្មានដែលហ៊ានមកលេងសើចជាមួយខ្ញុំ?"

គេកាន់តែនឹកឃើញ ភ្លើងកំហឹងក៏កាន់តែផ្ទុះ។ គេប្រើដៃស្ដាំប្រឡាក់ឈាមរឹមៗក្រហមច្រាលលូកទៅទាញបណ្ដាច់សំពត់នាងអោយ របូតទៅលើកម្រាលតដ្ឋ។នារីដែលយំសស្រាក់រហូតដល់ទឹកភ្នែកប្រឡាក់ដាមដល់រាងកាយបុរសទៀតនោះប្រឹងយារ ដៃទះកំផ្លៀងបុរស ហិង្សាមួយទំហឹងប្រាថ្នាអោយគេភ្ញាក់ខ្លួនពីកាមារម្មណ៍មកវិញខ្លះប៉ុន្តែ វាហាក់ដូចជាយកពងមាន់ទៅ ជល់នឹងថ្មដែរ

គេមិន ត្រឹមតែមិនដកថយ ថែមទាំងលូកដៃមកច្បាមអាវនាងដែលជាវត្ថុគ្របបិទបាំងចុងក្រោយ។ ក្នុងគ្រាប្រថុចញ៉ុចរូបរាងពាណិជ្ជករដែកថែបបានលេចធ្លោក្នុងអារម្មណ៍កេតឌីម៉ា ក្នុងវិនាទីនេះនាងគិតថាទោះស្លាប់ក៏ត្រូវការពារភាពស្អាតស្អំរបស់ខ្លួនដែរ ដូច្នេះហើយបានជាស្រីហា វមាត់ខាំត្របាក់ដៃឆ្វេងគេដែលកំពុងក្តាប់ប្រុងទាញកន្ត្រាក់បំផ្លាញអាវនាងចេញនោះ។

ធ្មេញនាងមុតនិងកម្លាំងខាំខ្លាំង ធ្វើអោយគេឈឺដល់ហើយត្រូវតែពន្លែងដៃនោះចេញវិញ ប៉ុន្តែភ្លើងកំហឹងកាន់តែផ្ទុះឡើងរហូតដល់រាមនរិន្ទក្តាប់ដៃស្តាំដាល់សំដៅមុខសស្លាំងរបស់នារីរងគ្រោះ។

មួយប៉ប្រិចភ្នែកនោះ នាងយល់ថានាងមុខតែត្រូវសន្លប់ស្មៀមលែងដឹងឈឺចាប់លែង ដឹងទុក្ខ ព្រួយក្រោមកម្លាំងដៃដែលវាត់មួយទំហឹងនោះហើយ ម្ល៉ោះហើយបានជាស្រី ស្រស់បិទ ភ្នែករង់ចាំទទួលកណ្តាប់ដៃនោះតែម្តង។

កូនប្រុសអ្នកតំណាងរាស្ត្រប្រឹងណាស់ទើបអាចបង្អាក់កណ្តាប់ដៃអោយឈប់នៅក្បែរបបូរមាត់ញ័រទទ្រើករបស់នាងជាមួយនឹងសម្តីលាយសូរអង្រ្គឹតធ្មេញ៖

-ស្រីមានល្បិច!

ការឈឺចាប់ផ្លូវកាយទាំងប៉ុន្មានមិនស្មើនឹងពាក្យ ប្រមាថចុងក្រោយនេះទេ ស្រី ស្រស់បិទ ភ្នែកបណ្តោយអោយសំឡេងសោយសោកលាន់មកកំដរបុរសដែលកំពុងតែព្រៃផ្សៃបំផុតក្នុងបេះដូងនាងដោយ បណ្តោយអោយគេបញ្ចេញកំហឹងទៅលើរាងកាយដែលទន់ ដូចសម្លីតាមសន្ទុះ ចិត្តដែលគេចង់។នារីបង្ហាញម៉ូតក្លាយ ជាកម្មសិទ្ធិក្នុងរង្វង់ ដៃគេទាំងស្រុង។តើនាងមានអ្វីសម្រាប់ការពារខ្លួនបានទៀត?

ល្បែងស្នេហ៍រំលត់ភ្លើងកំហឹងដែលអ្នកប្រុសគ្រួសារអ្នកនយោបាយអន្ទ្រើសប្រព្រឹត្តិបានបញ្ចប់ទៅជាមួយនឹងភាពសោកសៅរបស់នារីរងគ្រោះ។

គេក្រោកចាកចោលនាងហើយតម្រង់ចុះទៅរកអាងទឹកនៅខាងក្រោយសួន។

ក្រោមពន្លឺខៀវស្រអាប់នៃរាត្រីកាល នរិន្ទទម្លាក់រាងកាយធំមាំរបស់គេទៅក្នុងអំណាចនៃលំហជលធារត្រជាក់ស្រេងក្រោមចំហាយហេមន្តរាយោ។

ឬមួយថាញ៉ាំញីនារីបង្ហាញម៉ូតហើយភ្លើងកំហឹងនៅតែមិនស្រាក់រហូតទាល់តែត្រូវមកធ្វើប្រាណក្នុងចំណោមទឹកដែលត្រជាក់ដូចទឹកកក?

**ភាគទី២៣**

ត្រឡប់មកពីក្រៅនាយរឿនជាមនុស្សជំនិតបានស្ទុះស្វែងរកថៅហ្វាយគ្រប់ទិសទីរហូតបានមក ឃើញគេកំពុងវក់វីផ្ងៃលឆ្ងាត់ក្នុងទឹកតែម្នាក់ឯងក្រោមផ្ទៃមេឃពណ៌ខៀវងងឹត។ បុរសជំនិតដែល ថែទាំនាយថៅហ្វាយតាំងពីក្មេងមក គេមិនមែនមិនដឹងទេថា រាមនរិន្ទប្រហែលជាបានជួបនូវរឿង ហេតុអ្វីមួយដែលធ្វើឲ្យខកចិត្តធ្ងន់ធ្ងរហើយ បានជាគេមានឫកពាបែបនេះ។ ដោយអ្នកបម្រើនៅជុំ វិញបរិវេណហែលទឹកត្រូវបានបុរសអភិជនដេញចេញអស់ផងនោះនាយរឿនដឹងថា ទុកពេលឲ្យ ថៅហ្វាយវ័យក្មេងបញ្ចេញកំហឹងសិនទើបល្អ។ គេនៅឈរសម្លឹងសកម្មភាពមុជងើបៗរបស់រាម នរិន្ទរហូតដល់ពេលវេលា៣០នាទីរំលងទៅទើបគេនិយាយពីលើទៅ។

-អ្នកប្រុស! បើទុកឲ្យផ្តាសាយ ស្អែកទៅដេញថ្លៃឥន្ទបដិមាមិនល្អមើលទេ!

រាមនរិន្ទយោងរាយកាយសង្ហារបស់គេមកក្បែររឿន ទន្ទឹមពេលដែលគេលូកដៃមកទទួលនាយ ថៅហ្វាយត្រឡប់មកលើវិញ។

បុរសជំនិតហុចអាវក្រៅពណ៌សឲ្យគេស្រោបដណ្តប់រាងកាយ និងហុចកែវទឹកក្រូចស្រស់ទៅអម ជាមួយវាចាមួយៗ៖

-មានរឿងអីទៅអ្នកប្រុស?

ទឹកក្រូចស្រស់មិនបានធ្វើឲ្យស្នាមញញឹមរបស់គេផុសឡើងវិញដូចរាល់ដងទេ។ ពន្លឺភ្នែកខូចចិត្ត របស់អ្នកប្រុសអភិជនអាចលាក់កំបាំងមនុស្សទាំងអស់បាន ប៉ុន្តែមិនមែននាយរឿនឡើយ។ គេ ឈ្ងោកមុខពិចារណានៅពេលដែលសៀងវាចាម្ចាស់ប្រុសលាន់មក៖

-ស្រីនោះជាមនុស្សបោកប្រាស់!

អង្គរក្សរឿនងើបមុខយ៉ាងរហ័ស។ ភ្នែកគេប្រែទៅជាក្រឡេបក្រឡាប់ ជាសញ្ញានៃការពិចារណាដ៏ រហ័សរហួនមួយ។ តែគេនៅតែនៅស្ងៀមរង់ចាំស្តាប់ពាក្យរាមនរិន្ទបន្ត។

-ស្រីនោះជាមនុស្សរបស់សិទ្ធិគុណមែន! ខ្ញុំខុសហើយដែលមិនព្រមស្តាប់ឯងរឿន!

រឿនដកដង្ហើមយូរហាក់ចង់សម្រាលអារម្មណ៍តឹងតែងរបស់ម្ចាស់ប្រុស។ និម្មិតនោះគេឮសម្តីបន្ថែម របស់រាមនរិន្ទ៖

-រឿងទាំងអស់តាំងពីនៅបាលីមក ជាឆាកល្ខោនដែលគេធ្វើមកដើម្បីស្វែងរកព័ត៌មានឲ្យប្រុសរបស់គេ ហើយទីបំផុតគេបានសម្រេចក្នុងការនាំអាម្សៀនោះមកដល់ចាយ៉ាពូរាតាមពីក្រោយយើង! ស្រីនោះសាហាវណាស់!

នាយរឿនចង់នៅស្ងៀមបន្តដើម្បីឲ្យថៅហ្វាយនាយបានបញ្ចេញឲ្យអស់កំហឹងតាមរយៈពាក្យសម្ដី ប៉ុន្តែសម្លឹងទៅបបូរមាត់ដែលក្រៀមក្រោះរបស់គេ នាយរឿនដឹងថា គេដូចជាមិនមែនកំពុងមានកំហឹងទេតែកំពុងមានទុក្ខ។ ហៀបនឹងហាលួងលោមម្ចាស់ប្រុសទៅហើយ ស្រាប់តែត្រចៀកឮសំឡេងរបស់រាមនរិន្ទបន្លឺមកបន្តស្រាលៗក្នុងន័យសោកស្ដាយ៖

-រឿន! មិញនេះ ទប់ចិត្តមិនបាន ខ្ញុំធ្វើបាបស្រីនោះជ្រុលបន្តិចហើយ!

ពាក្យ "ធ្វើបាប" ធ្វើឲ្យនាយរឿនបើកភ្នែកធំៗ។

-ឥឡូវកេតឌីម៉ានៅឯណាអ្នកប្រុស! (នាយអង្គរក្សស្ទុះមកនិយាយខ្សឹបៗទាំងស្លន់ស្លោ)

រាមនរិន្ទដឹងថាប្រហែលជាអង្គរក្សរឿនយល់ខុសថាខ្លួនសម្លាប់ ឬវាយដំនាងហើយ។ គេគិតថាគ្មានអ្វីគួរអៀនខ្មាស និងលាក់លៀមចំពោះមនុស្សជំនិតនេះឡើយ គេនិយាយប្រាប់ភ្លាម៖

-ក្នុងបន្ទប់គេងរបស់ខ្ញុំ!

នាយរឿនយល់ហើយ គេឱនសម្លឹងកម្រាលស្មៅសាជាថ្មីដោយសើចស្ទើៗ។

"តាមពិតលោកប្រុសមកច្រមុជទឹកដោយសារស្ដាយក្រោយដែលធ្វើបាបស្រីបង្ហាញម៉ូតរូបស្អាតម្នាក់នោះផ្ទុយពីចរិតប្រុសទ្រាំង៥ហត្ថ។ កេតឌីម៉ាអើយកេតឌីម៉ានាងមានអនុភាពដល់ថ្នាក់ហ្នឹងមកលើម្ចាស់ប្រុសខ្ញុំ ខ្ញុំត្រូវចុះចាញ់នាងតែម្ដងហើយ"។

អង្គរក្សវាងវៃហើយប្រកបដោយភក្ដីភាព និយាយតិចៗមករកនាយថៅហ្វាយដែលកំពុងអង្គុយសោះអង្គើយលើកៅអី៖

-អ្នកប្រុសស្រលាញ់ស្រីនោះហើយ!

រាមនរិន្ទគ្រវីក្បាល៖

-ខ្ញុំស្អប់នាង! ខ្ញុំមិនស្រលាញ់មនុស្សស្រីអាក្រក់ចិត្តពុតត្បុតទេ!

នាយរឿនសើចតិចៗហើយដេញដើងវិញ៖

-ពីមុនៗមកឃើញមានមនុស្សខ្លះធ្វើឲ្យអ្នកប្រុសស្អប់ដែរ តែមានតែអ្នកប្រុសគេចគេ មិនដែលឃើញទៅចាប់គេរំលោភទេ!

រាមនរិន្ទគិតថាកូនចៅកំពុងនិយាយជាន់កែងប៉ុន្តែតាមពិតអង្គរក្សរឿនគឺមានចេតនាក្រើនរំលឹកឲ្យរាមនរិន្ទទទួលស្គាល់ការពិតក្នុងចិត្តខ្លួន និងឈប់ព្យាយាមកុហកខ្លួនឯងទៀត។ ទោះល្បែងស្នេហ៍នៅខាងលើមុននេះជាល្បែងចាប់បង្ខំ ប៉ុន្តែរាមនរិន្ទនៅតែទទួលយកពាក្យថាចាប់រំលោភនេះមិនបានទេ។ គេនិយាយកាត់រដាក់រដុប៖

-មកពី....ស្រី..នោះ....

គេបញ្ឈប់ប្រយោគតាមសារជាតិមនុស្សដែលមិនធ្លាប់ប្រព្រឹត្តិអាក្រក់ និងមិនធ្លាប់ចេះនិយាយកុហកដោះសា។ ដោយខ្មាសមនុស្សជំនិតផង គេនិយាយបន្លប់វិញ៖

-ជួយយកស្រាឲ្យខ្ញុំបានទេ?

មេឃរងោកម្រិតនេះហើយ គេនៅតែមិនព្រមឡើងត្រឡប់ទៅរកបន្ទប់ទៀត ប្រហែលជាគេខ្លាចត្រូវប្រឈមសាជាថ្មីជាមួយនារីម្នាក់ដែលគេបានជ្រុលធ្ងន់ដៃចំពោះនាងហើយ។ គិតទៅទោះបីមនុស្សមាំទាំកម្រិតណា ឲ្យតែស្នេហាចូលខ្លួន ហើយប៉ះភ្លើងប្រចណ្ឌឆេះរោលផង គេក៏ធ្វើទង្វើឆ្កួតៗខុសពីចរិតដើមបាន។ នាយរឿនដឹងថាតួនាទីរបស់នាយក្នុងពេលនេះគឺជួយសម្រាលទុក្ខកង្វល់របស់ម្ចាស់ប្រុស។

-ខ្ញុំកំដរអ្នកប្រុស! តែយើងទៅបន្ទប់ទទួលភ្ញៀវទៅ?

រាមនរិន្ទដឹងថាមានតែនាយរឿនទេនៅទីបំផុតដែលយល់ចិត្តខ្លួនជាងគេ។ គេក្រោកក្រេសចាកចេញទៅសួនផ្កាតម្រង់ទៅកាន់បន្ទប់ទទួលភ្ញៀវតាមយោបល់មនុស្សក្រោមបង្គាប់។

អ្នកប្រុសរូបសង្ហាទម្លាក់ខ្លួនលើសាឡុងធំដោយក្រេបជាតិស្រវឹង ដែលមានមនុស្សក្រោមបង្គាប់នៅកំដរបន្ទប់ពីគេដេញអ្នកយាមកាមទាំងឡាយឲ្យចាកចេញអស់មិនឲ្យមករវីមរវាមក្បែរនេះ។

-បើស្រលាញ់នាង អត់ទោសឲ្យនាងម្តងទៅអ្នកប្រុស!

រឿននិយាយបណ្តើរ គេឱនរុំរបួសដៃឲ្យនាយចៅហ្វាយដោយផ្ចិតផ្ចង់។ សម្តីនេះលំអងបាននិយាយនៅទីនេះដែរកាលពីល្ងាចមុនពេលនាងត្រូវកងការពារអូសបណ្តេញចេញទៅ។ ឥឡូវរាមនរិន្ទមិនស្មានដល់ថា វាអាចហើរចេញពីមាត់អង្គរក្សម៉ត់ចត់បំផុតរបស់ខ្លួនសោះ។ គេជ្រួញចិញ្ចើមសម្លឹង

ទឹកមុខមាំទាំរបស់នាយរឿនដែលគ្មានសញ្ញាណាមួយបញ្ជាក់ថាគេកំពុងនិយាយឲ្យរួចតែពីមាត់នោះទេ។

-ខ្ញុំគ្រាន់តែចង់ឲ្យអ្នកប្រុសមានសេចក្ដីសុខ និងសប្បាយចិត្ត! បើអ្នកប្រុសមិនដែលស្រលាញ់ស្រីណាមកពីមុនផង! ខ្ញុំសប្បាយចិត្តដែរ ដែលលោកប្រុសក្លាយមកជាប្រុសធម្មតាដូចគេឯង!

រាមនរិន្ទសើចជូរចត់៖

-តែមនុស្សស្រីម្នាក់ហ្នឹងមិនសមឲ្យអ្នកណាស្រលាញ់ទេ! ត្រូវហើយខ្ញុំភ្លេច! គេប្រហែលជាមានសិទ្ធិគុណស្រលាញ់គេ ព្រោះអាក្រក់ស្មើគ្នា!

រឿនចងចិញ្ចើមតែគេមិនមានពេលសម្រាប់ពិចារណាពីពាក្យច្រណែនប្រចណ្ឌរបស់ចៅហ្វាយកម្លោះទេ ព្រោះគេរវល់ពិចារណាទៅដល់រឿងសំខាន់មួយផ្សេងទៀត។ ទន្ទឹមនឹងនោះសម្ដីរាមនរិន្ទលាន់មកសាជាថ្មី៖

-គេហ៊ានដល់ថ្នាក់ប្ដូរជីវិតចូលមកបង្កប់ខ្លួនជួយអាម្សៀក្មេងនោះ កោតតែខ្ញុំខ្វាក់ភ្នែកចាញ់បញ្ឆោតគិតថាគេជាមនុស្សស្លូតបូតត្រឹមត្រូវ!

នាយរឿននិយាយបញ្ឈប់ភាពរវើរវាយរបស់ចៅហ្វាយ៖

-ពីដំបូងខ្ញុំគិតថាគេធ្វើការឲ្យសិទ្ធិគុណ ប៉ុន្តែឥឡូវដូចជាមានកន្លែងគួរឆ្ងល់ច្រើន! បើកេតឌីម៉ាពិតជាមនុស្សដែលសិទ្ធិគុណបង្កប់មកមែន គេមានបំណងអីបានជាតាមអ្នកប្រុសដល់ទីនេះ?

រាមនរិន្ទឆ្លើយភ្លាម៖

-រឿងឥន្ទបដិមា!

នាយរឿនគ្រវីក្បាលយឺតៗ៖

-ដំបូងខ្ញុំ គិតអញ្ចឹងដែរ តែកាលពីរសៀលនេះ ដែលខ្ញុំចេញទៅបន្ទាន់ព្រោះថាមនុស្សរបស់យើងនៅចាយ៉ាពូរ៉ាបានបញ្ជីចុះឈ្មោះអ្នកចូលរួមដេញថ្លៃនោះក្នុងដៃ! តែក្នុងនោះខ្ញុំផែកអត់ឃើញមានឈ្មោះសិទ្ធិគុណទេ! មានន័យថាកូនប្រុសឧកញ៉ាឆាយណាគុណ មិនមែនមកចាយាពូរ៉ាដើម្បីឥន្ទបដិមាឡើយ!

រាមនរិន្ទងើបមុខសម្លឹងអង្គរក្សរឿន។ គេរវេភ្នែករិះគិតបន្ទាប់ពីឮសេចក្ដីរាយការណ៍។ គេនិយាយតិចៗ៖

-ចុះគេចង់បានអីពីយើង?

នាយរឿននិយាយភ្លាមៈ

-ខ្លាចក្រែងតែយើងយល់ខុសពីស្រីបង្ហាញម៉ូតនោះ!

រាមនរិន្ទគ្រវីក្បាលបដិសេធប្រយោគចុងក្រោយរបស់រឿនៈ

-ខ្ញុំឮគេនិយាយពាក្យផ្អែមល្ហែមជាមួយគ្នាតាមទូរសព្ទផ្ទាល់ត្រចៀក ហើយអ្វីៗទាំងអស់ គឺពួកម៉ាកគេ លំអងសារភាពប្រាប់ខ្ញុំ!

នាយរឿនមិនទាន់ឆ្លើយថាយ៉ាងណាផង ស្រាប់តែសំឡេងមួយលាន់មកពីមាត់ទ្វារៈ

-បងរឿនៗ

នាយរឿនងើបមុខសម្លឹងនាយថៅហ្វាយរួចទើបក្រោកចេញសំដៅទៅរកមនុស្សក្រោមបង្គាប់ដែលត្រហេបត្រហបរត់ចូលមក។ គេចេញទៅបន្សល់ឲ្យរាមនរិន្ទនៅអង្គុយម្នាក់ឯងក្រោមការហ៊ុមព័ទ្ធនៃអារម្មណ៍ខកចិត្ត។

"កេតឌីម៉ា ស្រីមិនចេះស្រឡាញ់ខ្លួន! នាងកើតមកមានរូបរាងស្រស់ស្អាត សម្ដីសំដៅល្មមសម្លាប់ចិត្តប្រុសៗបានតែនាងមិនចេះឲ្យតម្លៃសម្បត្តិពីធម្មជាតិរបស់ខ្លួនបែរជាសេពគប់មនុស្សចិត្តចោរ។ ទោះយើងបំពានលើរាងកាយនាងប៉ុណ្ណឹងទុកជាស្អីទៅ? បើធៀបនឹងគំនិតបោកប្រាស់ត្រជាក់ល្ហឹមរបស់នាង។"

ការវិលត្រឡប់ប្រញិបប្រញាប់របស់នាយរឿនកាត់ផ្ដាច់ចេតនារម្មណ៍មួហ្មងរបស់រាមនរិន្ទ។

-អ្នកប្រុស! ថៅកែសិទ្ធិគុណមកដល់ហើយៗ! គេចាំនៅសួនច្បារខាងក្រៅ ខ្ញុំមិនទាន់ឲ្យចូលមកទេ!

ទឹកមុខក៏ផ្លាស់ទៅជាក្រហមរាមនរិន្ទ។ នាយរឿនរត់ទៅទទួលអាវដំណោកពណ៌ត្នោតរលោងពីកូនចៅដែលទើបលើកមកដល់ហើយបំពាក់គ្របទៅឲ្យថៅហ្វាយប្រុស ដែលបម្រុងនឹងឈានជើងចេញទៅទទួលភ្ញៀវពិសេស។

នាយBirdដែលមាននាទីចាំតាមដានប្រតិកម្មហិង្សារបស់រាមនរិន្ទក្នុងគម្រោងការរបស់លំអងនោះបង្ហាញខ្លួនជាមួយវាចាស៊កសៀតបំផ្ទុះកំហឹងស្នេហ៍។ គេនិយាយតិចៗដាក់ត្រចៀកនរិន្ទដែលកំពុងឱនចងខ្សែក្រវាត់អាវរាត្រីៈ

-អ្នកប្រុស! ថៅកែសិទ្ធិគុណសួររកកេតឌីម៉ា!

រាមនរិន្ទសើចកខឹកដោយកំហឹង។

"ឯងមកឃើតពេលហើយអាចង្រៃ" គេនឹកក្នុងចិត្តហើយបោះជំហានធូន់ៗចេញទៅដោយមានមនុស្សជំនិតនៅពីក្រោយផង។ អ្វីដែលអ្នកប្រុសត្រកូលខ្ពស់នឹកឃើញមុនគេគឺថា ធីតាបង្ហាញម៉ូតដែលរងការបញ្ចេញកំហឹងមុននេះច្បាស់ជាបានទូរសព្ទទៅសុំជំនួយពីប្រុសស្នេហ៍លួចលាក់របស់នាងហើយ បានជានាយអភិជនវ័យក្មេងដ៏ក្អេងក្អាងបង្ហាញខ្លួនទាំងរាត្រីបែបនេះ។

កំហឹងផ្ទុះមកវិញព្រោះការប្រចៃប្រចណ្ឌ និងមិនសុខចិត្តធ្វើអាយគេមិនអាចពិចារណាអ្វីៗឲ្យបានគ្រប់ជ្រុងជ្រោយឡើយ។

តាមពិតសិទ្ធិគុណក៏មកដោយងងឹតងងល់ដូចគ្នា។ នៅក្នុងផែនការរបស់Kenដែលចង់ឲ្យយប់នេះរាមនរិន្ទត្រូវតែជាប់ពិរុទ្ធដោយសារការធ្វើទោសកេតឌីម៉ានោះ ពេលនេះបានជំនួសវិញដោយសារលំអងមិនដាច់ចិត្តពីមិត្តទើបនាងព្យាយាមបង្វែរអោយសិទ្ធិគុណក្លាយជាអ្នករងគ្រោះវិញ ដោយមុនពេលត្រូវរាមនរិន្ទបណ្តេញចេញនាងព្យាយាមនិយាយឲ្យរាមនរិន្ទទន់ចិត្តចំពោះកេតឌីម៉ា ហើយនាងចេញទៅរកសិទ្ធិគុណបន្ទាប់ពីនោះដោយកុហកគេថា កេតឌីម៉ាកំពុងរស់នៅដោយវេទនាក្នុងកណ្តាប់ដៃរាមនរិន្ទ។ ដោយឥទ្ធិពលនៃការលង់ចិត្តលើនារីបង្ហាញម៉ូត ថៅកែក្មេងឈាមរាវ អត់បានការដែលខំកាត់ពីបាលីរហូតដល់ប៉ាញួដើម្បីតែស្រង់ក្លិនបុប្ផានោះមិនអាចនៅសុខឡើយ កាលបើឮថាកេតឌីម៉ាត្រូវនៅជាមួយរាមនរិន្ទដោយបង្ខំ។ គេត្រូវមកបង្ហាញខ្លួននៅផ្ទះរាមនរិន្ទទាំងយប់ ដើម្បីរកមធ្យោបាយជួយនាង តែគេក៏មិនដឹងដែរថាគោលដៅរបស់លំអងគឺចង់ឲ្យរាមនរិន្ទទប់ចិត្តមិនបានប្រដៅគេ ដែលធ្វើឲ្យរាមនរិន្ទក៏ជាប់ពិរុទ្ធមិនបានចូលរួមពិធីធំនៅវេលាស្អែក។

មុនពេលចេញទៅដល់ទីដែលភ្ញៀវមិនគួរមកកំពុងមានវត្តមាន នាយBirdឆ្លៀតបន្ថែមល្បោយ៖

-តែកន្លះម៉ោងមុននេះ អ្នកនាងកេតឌីម៉ាស្ពាយកាបូបខោអាវចេញក្រៅបាត់ហើយទាន!

រាមនរិន្ទចងចិញ្ចើមទន្ទឹមនឹងពេលនាយរឿនបើកភ្នែកធំៗ។ គេយល់សាច់រឿងដែលថា រាមនរិន្ទប្រចណ្ឌដល់ថ្នាក់ចាប់បង្ខំនាងដោយកម្រោល ពេលនេះនាងរើអីវ៉ាន់ចាកចេញគ្មានអីចំឡែកទេ ប៉ុន្តែដែលសំខាន់ ហេតុអីគ្មានអ្នកណារាយការណ៍។ មានតែរឿនទេដែលដឹងថា ការចាកចេញរបស់នារីបង្ហាញម៉ូតនឹងធ្វើឲ្យម្ចាស់ប្រុសខ្លួនខូចចិត្ត។ គេងាកបន្ទោសតិចៗ៖

-ឯងម៉េចមិនប្រញាប់និយាយ? ឥឡូវកេតឌីម៉ាទៅដល់ណាហើយអ្ហា?

នាយBirdរត់មកយកចិត្តនាយរឿនភ្លាមៈ

-ខ្ញុំឃើញបងរឿន និងអ្នកប្រុសឃាត់មិនឲ្យអ្នកណាចូលរំខានបានជារកពេលចូលរាយការណ៍មិនកើត! តែខ្ញុំចាត់មនុស្សតាមអ្នកនាងឌីម៉ារហូត! គេប្រាប់មកថានាងកំពុងអង្គុយម្នាក់ឯងនៅឧទ្យានព្រីម៉ា។

រឿនលើកដៃមើលនាឡិកានៅពេលរាមនរិន្ទបញ្ចប់ការចងខ្សែអាវ។ រឿននិយាយដោយលួចមើលមុខចៅហ្វាយភ្លៀកៗៈ

-ឧទ្យានព្រីម៉ាថ្មើរណោះអ្ហេស៎? ស្មានថាចាយ៉ាពូវ៉ាមានសន្តិសុខបរិបូរណ៍ដូចសួនមុខវត្តបទុមអ្វី?

នាយBirdក៏លួចដៀងមើលរាមនរិន្ទដូចគ្នា មាត់ប្រឹងនិយាយៈ

-បងរឿនមិនបាច់ព្រួយទេ! មនុស្សយើងនៅទីនោះមាន! គ្មានអ្នកណាធ្វើអីអ្នកនាងឌីម៉ាបានទេ! តែ...ខ្ញុំនៅចាំបញ្ជាថា គួរនាំនាងមកវិញអត់? ឬមួយបណ្ដោយសិន...

រាមនរិន្ទលូកមាត់កាត់ៈ

-ប្រាប់សិទ្ធិគុណឲ្យចេញទៅរកស្រីស្នេហ៍គេនៅទីនោះទៅ! កុំមករញ៉េរញ៉ៃនៅទីនេះ!

គេបែរខ្លួនចោលគោលដៅដែលមុននេះចង់ចេញទៅរកចៅកៃក្មេង។ ឃើញដំណើរគេ ដែលឈានឡើងជណ្តើរឆ្ពោះទៅរកបន្ទប់សម្រាកវិញក៏ដឹងស្រេចហើយថាគេកំពុងហេងហាងដែលបាត់ស្រីស្អាតពីទ្រូង។

នាយរឿនងាកមករកនាយBirdដោយនិយាយបញ្ជាៈ

-ឯងចេញទៅជួបកូនប្រុសឧកញ៉ាឆាយណាគុណហើយប្រាប់គេទៅថាអ្នកប្រុសរាមមិននៅទេ! ហើយក៏គ្មានអ្នកណាមានពេលចេញទៅទទួលគេដែរ!

Birdភ្ញាក់ព្រើត។ គេងើបមុខសម្លឹងនាយរឿនភ្លឹះៗប៉ុន្តែក្នុងចិត្តកំពុងស្រងាក។

"បើអញ្ចឹងសាច់រឿងមិនប្ដូរសកម្មភាពទៅហើយ? យើងចង់ឲ្យសិទ្ធិគុណខឹងមកដេញដោលរកកេតឌីម៉ាដើម្បីបង្កើតជម្លោះជាមួយរាមនរិន្ទ ប៉ុន្តែល្ខោននេះគ្រាន់តែបាត់វត្តមានតួស្រី តួប្រុសក៏លែងមានកម្លាំងប្រយុទ្ធទៅហើយ? ឬមួយថា ព្រហ្មលិខិតកំណត់ឲ្យរាមនរិន្ទត្រូវតែមានឱកាសទៅកាន់កន្លែងដេញថ្លៃព្រឹកស្អែកនេះ?"

-ឯងនៅធ្មឹងធ្វើអី?

នាយរឿនគំហកកាត់ផ្តាច់អារម្មណ៍បាចសាចរបស់ជនបង្កប់ធ្វើឲ្យនាយBirdត្រូវតែបង្ខំចិត្តចាកចេញទៅទាំងមិនអស់ចិត្ត។

នាយរឿនតាមសម្លឹងក្រុមមនុស្សក្រោមបង្គាប់ដែលចេញទៅស្វាគមន៍ថៅកែក្មេងសិទ្ធិគុណសត្រូវបេះដូងនៃនាយថៅហ្វាយខ្លួន។ គេដកដង្ហើមធំរួចបំបែរទិសដៅដើរសំដៅមករកបន្ទប់កេតឌីម៉ាដែលនៅអាគារមួយផ្សេង។

ចូលមកដល់បន្ទប់ដែលម្ចាស់វាបានចាកចោលរួចទៅហើយ នាយរឿនរកឃើញសំបុត្រដៃមួយដែលនាងបានសរសេរទុកក្នុងវ៉ាលិសសំលៀកបំពាក់របស់លំអង។

"លំអង! ប្រុសអ្នកមាននោះគេខ្មោចចូលហើយ! គេធ្វើបាបគ្នា គេមិនបានទុកយើងជាមនុស្សម្នា គេមិនបានឲ្យតម្លៃយើងសូម្បីតែជាស្រីទន់ខ្សោយម្នាក់! គ្នាមិនអាចនៅទីនេះទៀតបានទេ! គ្នាខលរកឯងច្រើនដងហើយ តែមិនអាចទាក់ទងឯងបានទេ! គ្នាអត់ដឹងត្រូវទៅណាទាំងអស់ ព្រោះគ្នាអត់ស្គាល់អ្នកណាទាំងអស់! តែគ្នាចាំបាច់ត្រូវចេញពីកន្លែងរបស់គេ បើឯងឃើញសំបុត្រនេះហើយ ឯងត្រូវខលមកគ្នាភ្លាម។ ទោះគ្មានលិខិតឆ្លងដែនក៏ដោយ យើងរកវិធីជួយខ្លួនយើង យើងកុំចាំបាច់ទៅពឹងមនុស្សទាំងហ្នឹងទេ។ ឌីម៉ា មិត្តរបស់ឯង"។

អង្គរក្សវ័ឆ្លាតវៃភ្នែកសញ្ជឹងគិត។ គេយល់ថាមានប្រស្នាមិនប្រក្រតីមួយចំនួនដែលគេនៅតែស្រាយមិនចេញសោះ។ ប្រសិនបើកេតឌីម៉ាពិតជាមនុស្សបង្កប់របស់សិទ្ធិគុណ ហេតុអ្វីបានជានាងចេញពីទីនេះហើយមិនទៅរកអភិជនវ័យក្មេងនោះទៅ បែរជាបណ្តោយឲ្យបុរសនោះមកតាមរកដល់កន្លែងនេះ?

ហើយហេតុអ្វីបានជាលំអងមានគំនិតបកអាក្រាតមិត្តហើយបិទទូរសព្ទចោលស្ងាត់ច្រៀបបែបនេះ? តើអ្វីទៅជាបំណងពិតរបស់នារីទាំងពីរ?

គេលូកដៃស្រវាចាប់ទូរសព្ទហើយនិយាយបញ្ជា៖

-អាគង់ ឯងតាមរកមើលតើស្រីម្នាក់ទៀតឈ្មោះលំអងនោះពេលនេះកំពុងនៅឯណា? នាងនោះអត់មានប៉ាស្ព័រ ច្បាស់ជាមិនអាចចូលដេកនៅអូតែលធំៗទេ លើកលែងតែកន្លែងរកស៊ីលួចលាក់តូចៗ!

**ភាគទី២៤**

## វគ្គទី១២

## រវាងស្នេហ៍ពិតនិងស្នេហ៍ក្លែងក្លាយ

...នៅឯជាន់ខាងលើ បុរសកូនទោលនៃត្រកូលអ្នកនយោបាយ បោះជំហានត្រឹកៗឆ្ពោះទៅរក

បន្ទប់ដេកដោយទឹកមុខមួម៉ៅ។ ជាតិអាល់កុលពណ៌ក្រហមដែលអង្គរក្សជំនិតកំដរគេក្រេបមុននេះនៅតែមិនមានឥទ្ធិពលល្មមអាចបញ្ឈប់គេក្នុងការនឹកគិតទៅដល់កេតឪម៉ាឡើយ។

អ្នកប្រុសទម្លាក់ខ្លួនទៅលើគ្រែហើយគេងផ្កាប់មុខបណ្ដោយនាសាឲ្យស្និទ្ធជាមួយក្លិនក្លែបដែលនៅសេសសល់ក្រោយពីអវត្តមានម្ចាស់វា។

"ស្រីឆ្កួត! ពីថ្ងៃនេះទៅ នាងលែងនៅឲ្យយើងឃើញមុខហើយមែនទេ?"

គេនិយាយរអុះៗតែម្នាក់ឯង។ ពន្លឺភ្នែកល្ហល្ហេវរបស់នាយអាចបញ្ចេញដោយសេរី នៅពេលដែលគ្មានអ្នកណាផ្សេងបានឃើញ និងពេបជ្រាយ។ នរៈដែលមានឈ្មោះល្បីខាងបេះដូងដែក ក្ដាប់ដៃវាយកម្រាលពូកផូងហើយបណ្ដោយរាងកាយឲ្យនៅស្ងៀមគ្មានចលនានៅលើសយនា។

គេបិទភ្នែកសន្សឹមៗ តែក្នុងចិត្តខ្សឹបប្រាប់ខ្លួនឯងថា "មានអីអស្ចារ្យទៅ? ឆ្កួតបំផុតហើយដែលគិតថាយើងស្រលាញ់នាងនោះកេតឪម៉ា"។

សំណោកយំខ្សឹកខ្សួលរបស់ស្រីស្អាតតាមលងរហូតដល់ក្នុងសុបិនរបស់នាយ។ បបូរមាត់នាង និងស្នាមញញឹមក្រៀមក្រំរបស់នាងបានរលប់បាត់ក្នុងភាពស្រពិចស្រពិលជំនួសមកវិញនូវរូបរាងកម្សត់ស្គមស្គើងនៃអ្នកគ្រូបង្ហាញម៉ូតដែលអង្គុយសំកុកម្នាក់ឯងដោយគ្មានគោលដៅនៅឧទ្យានព្រីម៉ាដ៏ល្បីរបស់ក្រុងចាយ៉ាពូរ៉ា។

"យើងមិនបានដេញនាងទេ! គឺនាងទៅខ្លួនឯង! ស្រីល្ងង់"។

អ្នកប្រុសធំលង់លក់សន្សឹមៗទៅក្នុងរាត្រីដែលប្រែទៅជារងា និងឯកោមិនដែលមាន។ រហូតដល់ព្រះទិនករយាងមកបន្តវេនពីព្រះចន្ទវិញហើយគេ នៅតែមិនព្រមក្រោកចេញពីដំណេកឡើយ។ គេដឹងខ្លួនប៉ុន្តែនៅក្រាញលើទីដំណេកហាក់អស់កម្លាំងកាយក្នុងការយោងខ្លួនក្រោក។

ប៉ុន្តែនៅពេលនឹកឃើញដល់វត្ថុបំណងធំបង្អស់ក្នុងការមកកាន់ទីនេះ នាយអភិជនបើកភ្នែកគ្រលួងនិងស្ទុះក្រោកភ្លែត។

"យើងចោលឥន្ទ បដិមាដោយសារស្រីគ្មានតម្លៃម្នាក់ហ្នឹងកើតដែរ?"

គេស្ទុះរឹងទៅរកបន្ទប់ទឹកព្រោះថានៅសល់ពេលតែប៉ុន្មានម៉ោងទៀតប៉ុណ្ណោះ ការដេញថ្លៃនឹងចាប់ផ្តើមហើយ។

នៅជាន់ខាងក្រោមមនុស្សជំនិតនានាបានរៀបចំខ្លួនជាស្រេចក្នុងការដង្ហែនាយថៅហ្វាយទៅបង្ហាញ ខ្លួននៅក្នុងចំណោមសេដ្ឋីនានាដែលចាប់អារម្មណ៍ចំពោះភាពល្អវិចិត្រនិងអាថ៌កំបាំងនៃវត្ថុបុរាណក្នុងលោក។

-តោះយើង!

គេនិយាយដោយមិនងាកមុខសម្លឹងអ្នកហែហម ប៉ុន្តែទើបតែឈានចេញបានមួយជំហាន គេឮនាយរឿននិយាយឃាត់ដោយការគោរព៖

-អ្នកប្រុសមិនទាន់ស្រស់ស្រូបអាហារពេលព្រឹកទេទាន!

រាមនរិន្ទងាករកអង្គរក្សដ៏ចំណាប់។ ពន្លឺភ្នែកបានបញ្ជាក់ជាស្រេចហើយថាគេមិនចង់ប៉ុន្តែនាយនោះនៅតែនិយាយបន្ថែម៖

-យើងនៅសល់ពេលច្រើននៅឡើយ!

គេដឹងថាបុរសនេះកំពុងបារម្ភពីខ្លួនហើយបើខ្លួនមិនទៅតាមពាក្យគេដូចជាសារភាពថាខ្លួនកំពុងខូចចិត្តដល់ថ្នាក់ភ្លេចបាយភ្លេចទឹកអញ្ចឹងដែរ។ រាមនរិន្ទដើរត្រឹកៗទៅរកបន្ទប់អាហារ។ គ្មានកងការពារណាម្នាក់ចូលទៅតាមនាយឡើយ។ មានតែអង្គរក្សជំនិតដែលដើរមួយៗពីក្រោយដោយមានកាន់កុំព្យូទ័រនៅនឹងដៃ។

រឿនទាញកៅអីជូនថៅហ្វាយប្រុសដែលគ្មានស្នាមញញឹមលើផ្ទៃមុខ។ គេឥតស្តីមួយម៉ាត់ រៀមនរិន្ទក៏អត់ស្តីមួយម៉ាត់ធ្វើឲ្យបរិយាកាសទៅជាស្ងាត់ជ្រងំ។

កែវទឹកក្រូចស្រស់មួយត្រូវបានហុចមកពីមុខបុរសអភិជន គេលូកដៃទទួលបណ្តើរ ភ្នែកផ្តោតរកអេក្រង់កុំព្យូទ័របណ្តើរ។ ប៉ុន្តែដូចជាម្រាមដៃអ្នកដែលកាន់កែវទឹកក្រូចអម្បាញ់មិញមិនដូចជាម្រាមដៃមនុស្សប្រុស ជាហេតុធ្វើឲ្យគេត្រូវតែងាកមុខមកវិញភ្លាម។

ពីចំហៀងខាងស្តាំ ស្រីស្អាតម្នាក់ដែលប្រកបដោយភាពក្រៀមក្រំតាមពន្លឺ ភ្នែកកំពុងសម្លឹងមករកគេដូចគ្នា។ នាងគ្រងដោយសម្លៀកបំពាក់ដូចរង់ចាំទៅចូលរួមពិធីធំដុំអ្វីមួយ ប៉ុន្តែលើដៃកំពុងទ្រចានអាហារមួយទៅវិញ។

"កេតឌីម៉ា?"

គេសួរខ្លួនឯងដោយអារម្មណ៍វិលខ្វាល់។ នារីដកក្រសែភ្នែកចេញពីម្ចាស់ប្រុស ដែលមានអំណាចជាងគេនៅទីនេះ។ នាងដាក់ចានអាហារទៅឲ្យគេដែលមានទាំងនំប៉័ង និងសាច់ចំណិតតាមបែបបស្ចិម។ វត្តមាននាងធ្វើឲ្យបុរសដែលកំព្រាបេះដូងពេញមួយរាត្រីបែរជាអរភើតក្នុងចិត្ត ប៉ុន្តែគេនៅតែរក្សាទឹកមុខស្មើគេចចេញពីខ្សែភ្នែកនាងដោយឱនមកមើលចានម្ហូបជំនួស។

នៅឯណោះធីតាបង្ហាញម៉ូតគិតម្នាក់ឯងដោយតូចចិត្ត៖

"កេតឌីម៉ា! រាល់ដងឲ្យតែពេលគេឃើញឯងម្ដងណា ក៏គេតែងតែដើរមកឱបចង្កេះ និងញញឹមទទួល។ តែលើកនេះសូម្បីតែមើលមុខឯងក៏គេមិនចង់ដែរ។ គេដាច់ចិត្តណាស់"។

បុរសអភិជនដែលតែងតែនិយមអាហារប្រភេទងាយៗនេះ បែរជាងាកមករកនាយអង្គរក្សដែលនៅពីក្រោយខ្នង ហើយពោលបន្ទោសដោយសព្ទសំឡេងមួយៗ៖

-រឿន! របស់អស់នេះខ្ញុំលេបអត់ចូលទេ! ទ្រលាន់!

គេក្រោកចោលកៅអីហើយចាកចេញទៅ ក្រោមកែវភ្នែករលោងស្រិលរបស់កេតឌីម៉ា។ នាងឈ្ងោកមុខអត់ធ្មត់កុំឲ្យទឹកភ្នែកធ្លាក់ស្រក់ ប៉ុន្តែវាបានលេចចេញមកព្រិលរកាំដល់ថ្នាក់សូម្បីតែសម្លឹងដំណើរគេពីក្រោយក៏មើលមិនឃើញដែរ។

កាលពីយប់មិញនេះ ពេលនាងកំពុងអង្គុយសោយសោកម្នាក់ឯងនៅលើឧទ្យានព្រីម៉ាអង្គរក្សដែលធ្លាប់តែស្អប់នាងបានបង្ហាញខ្លួន។ នាយរឿនដែលធ្លាប់តែហាមឃាត់នាងមិនឲ្យចូលចិត្តអ្នកប្រុសធំរបស់គេ បែរជាសំណូមពរឲ្យនាងត្រឡប់ទៅវិញ។

គេបានប្រាប់នាងថាការចាកចេញមិនមែនជាមធ្យោបាយទេ ព្រោះថានាងកំពុងត្រូវបានគេគិតខុស បើនាងចង់បានភាពស្អាតស្អំមកវិញនាងត្រូវតែបញ្ជាក់វាមិនមែនរត់គេចទេ។ នាងបានតវ៉ាថា នាងមិនអាចនៅក្បែរមនុស្សកម្រោលដែលចាប់បង្ខំសូម្បីតែមនុស្សទន់ខ្សោយទេ ហើយមួយជីវិតនេះទោះយកកាំភ្លើងភ្ជង់ទៀតក៏នាងមិនព្រមត្រឡប់ទៅនៅជិតប្រុសម្នាក់នោះវិញដែរ។ ដោយទ័លច្រកនាយរឿនបានប្រាប់នាងថា រាមនរិន្ទតាមពិតប្រហែលជាស្រលាញ់នាងពេលបានជាដល់ថ្នាក់ប្រចណ្ឌ និងធ្វើទង្វើដែលខុសពីចរិតដើមទាំងស្រុង។ ហើយគេបានប្រាប់នាងទៀតថាមិត្តរបស់នាង គឺលំអងដែលជាអ្នកនិយាយប្រាប់រាមនរិន្ទពីទំនាក់ទំនងរបស់នាងនិងសិទ្ធិគុណ។

កេតឌីម៉ាដែលមិនជឿរឿងនេះដាច់ខាតបានបន្ទោសថានាយរឿនប្រឌិតរឿងដើម្បីឲ្យនាងបែកបាក់មិត្ត ប៉ុន្តែនាយរឿនបានបន្ថែមថា បើនាងចង់ដឹងពិតមិនពិតគួរហៅលំអងមកតទល់គ្នា។

កេតឌីម៉ាមិនអាចសូម្បីតែទាក់ទងលំអងវិញនោះបានបន្ទោសថាក្រុមនាយរឿនកំពុងលេងល្បិចនាំលំអងទៅលាក់បង្ខាំង ហើយប្រឌិតរឿងការពារអំពើហិង្សាដោយកម្រោលដែលថៅហ្វាយខ្លួនកំពុងបានប្រព្រឹត្តិចំពោះខ្លួនកាលពីល្ងាច។ អស់តម្រិះ នាយរឿនបានចាក់បណ្ដោយហើយគំរាមនាងថា បើនាងគិតថាលំអងកំពុងក្នុងដៃក្រុមខ្លួននាងរឹតតែត្រូវវិលទៅវិញផ្គាប់បម្រើថៅហ្វាយប្រុសខ្លួនឲ្យបានល្អ បើពុំនោះទេ នាងមិត្តនាងនឹងជួបវិបត្តិ។ អង្គរក្សរឿនធ្វើដូច្នេះព្រោះគេដឹងថានាងកំពុងតែមានអត្ថន័យសំខាន់ម្យ៉ាងក្នុងជីវិតថៅហ្វាយខ្លួនដែលមិនដែលមានពេលសម្រាប់ស្នេហា។ គេមិនជឿថា រាមនរិន្ទមិនអាចយកបានបេះដូងស្រីម្នាក់នេះឡើយ ពិសេសមួយទៀតគឺគេកំពុងចង់ស្រាយចំណោទដែលថាហេតុអីបានជាលំអងបង្កើតរឿងកេតឌីម៉ា និងសិទ្ធិគុណនេះឡើងបើតាមពិនិត្យទៅវាមិនមានតម្រុយណាបញ្ជាក់ថាសម្ដីនាងជាការពិតផង។

កេតឌីម៉ា ស្រីកម្សត់ដែលតែងតែលង់ក្នុងកលល្បិចនានាដោយងាយ នៅតែត្រូវបង្ខំចិត្តវិលមកវិញហើយបង្ហាញខ្លួនជានារីក្រោមបង្គាប់បុរសម្នាក់ដែលធ្វើឲ្យនាងឈឺចាប់។

ព្រឹកនេះ ជាការចាប់ផ្ដើមនៃជីវិតផ្គាប់ផ្គុនដែលក្នុងគោលបំណងតែម្យ៉ាងគត់ គឺការពារសុវត្ថិភាពលំអងដែលនៅតែបាត់ខ្លួន។ តែនាងមិនស្មានដល់ទេថា បុរសដែលបានធ្វើបាបនាងគួរឲ្យឈឺចាប់មិនត្រឹមមិនដឹងកំហុស គេថែមទាំងបង្ហាញអាកប្បកិរិយាសោះអង្គើយ និងស្អប់ខ្ពើមនាងផង។

ការចាកចោលចានអាហាររបស់រាមនរិន្ទ បានធ្វើឲ្យធីតាកាន់តែអស់កម្លាំងចិត្តក្នុងការតស៊ូជាមួយហេតុការណ៍អយុត្តិធម៌ទាំងអស់ដែលខ្លួនបានជួប។ នាងឈរទ្រឹងកណ្ដាលបន្ទប់អាហារបណ្ដោយអោយទឹកភ្នែកហូរមកតាមអំពើចិត្ត។ ប៉ុន្តែអង្គរក្សរឿនបែរជាពោលលួងលោមនាងតិចៗ៖

-កេតឌីម៉ា! លួងមនុស្សប្រុសមិនមែនជារឿងពិបាកទេ! បើនាងមានចិត្តស្មោះ ហើយបើនាងមិនមែនអាក្រក់ដូចគេថាទេនោះ!

នារីឆ្លើយតបដោយរអាក់រអួល៖

-រឿន! ថៅហ្វាយលោកគេមិនត្រូវការឲ្យខ្ញុំបម្រើទេ តើលោកបង្ខំខ្ញុំធ្វើអី? លោកដោះលែងខ្ញុំ និងលំអងទៅ!

គ្មានពេលនិយាយច្រើនទៀតទេ នាយរឿនចាកចេញទៅតាមពីក្រោយនាងថៅហ្វាយដោយបោះសម្ដីមកជាចុងក្រោយ។

-បើមិនចង់ខ្មាសគេទៅជូតទឹកភ្នែកឲ្យស្អាតទៅកេតឌីម៉ា! ខ្ញុំចាំនាងនៅខាងក្រៅ!

រាមនរិន្ទនៅអង្គុយចុចកុំព្យូទ័រក្នុងឡានដែលបញ្ឈប់ចាំមនុស្សជំនិត។ តាមកញ្ចក់ខាងមុខគេឃើញនារីរូបស្អាតឈានដើរយឺតៗចូលទៅក្នុងរថយន្តផ្សេងមួយទៀតដែលមាននាយរឿនបើកទ្វារឲ្យ។

ពេលនាយរឿនដើរចូលមកអង្គុយក្នុងឡានជិតអ្នកបើកបរ រាមនរិន្ទសួរភ្លាម៖

-រឿនឯងឲ្យកេតុឌីម៉ាមកធ្វើអី?

នាយរឿនញញឹមងាកមកតបនិងថៅហ្វាយដែលកំពុងនិយាយខុសពីចិត្ត៖

-ភ្ញៀវទាំងអស់នៅកន្លែងដេញថ្លៃនោះ អ្នកណាក៏មានស្រីស្អាតទៅបង្អួតគេដែរអ្នកប្រុស!

រាមនរិន្ទឆ្លើយវិញភ្លាម៖

-តែយើងចាំបាច់អីធ្វើដូចគេ?

នាយរឿនវាចាតបនឹងទឹកមុខស្មើរបស់ថៅហ្វាយ៖

-បើនាងប្រាកដជាមនុស្សបង្កប់អោយសិទ្ធិគុណ យើងចាំមើលទៅថានាងធ្វើម៉េចពេលជួបម្នាក់ហ្នឹង?

ទីបំផុត អ្វីដែលគេរង់ចាំបានមកដល់។ នោះគឺពិធីដេញថ្លៃដែលមុននេះបណ្ដាលឲ្យកើតឡើងនូវល្បិចល្បងយ៉ាងចម្រូងចម្រាស។...សម្រិបជើងស្រាលៗជាទម្លាប់របស់ក្រុមអភិជន បានឈានជាបន្តបន្ទាប់មកលើកម្រាលព្រំក្រហមនៃសណ្ឋាគារWinter Jayapura ដែលក្រាលទទួលភ្ញៀវកិត្តិយសនៃពិធីដេញថ្លៃវត្ថុបុរាណដ៏ធំមានសរុប៣៦មុខ។

បុរសមកពីប្រទេសកម្ពុជាដែលអមដំណើរដោយកងហែហម ទោះបីជាគេមានមុខមាត់ភ្លឺថ្លាកាយសម្បទាសង្ហាមាំទាំល្មមឲ្យអ្នកផងងាកមកចាប់អារម្មណ៍ ប៉ុន្តែប្រហែលជានារីរូបស្អាតដែលមកជាមួយគេនោះវិញទេដែលកំពុងធ្វើឲ្យបុរសទាំងឡាយក្នុងសាលនេះមិនអាចធ្វើពើជាមិនឃើញបាន។

ដោយងាកទៅទិសណាក៏ឃើញតែគ្រាប់ភ្នែកត្របាញ់បោលសំដៅមករកនារីបង្ហាញម៉ូត រាមនរិន្ទដៀងភ្នែកមកមើលប្រតិកម្មរបស់នាង។

ដូចរាល់ដង នាងមានភាពស្រងូត និងហាក់មិនចាប់អារម្មណ៍ពីចេតនាប្រតិព័ទ្ធរបស់កន្លង់ទាំងឡាយឡើយ។

"គ្រាន់តែរងកំហឹងខ្ញុំម្ដង នាងធ្វើដូចជាមានទុក្ខធ្ងន់ណាស់អញ្ចឹងកេតឌីម៉ា? "រាមនរិន្ទគិតក្នុងចិត្តរួចទើបរេភ្នែកស្វែងរកអភិជនវ័យក្មេងម្នាក់ទៀតដែលជាសត្រូវស្នេហារបស់ខ្លួន ព្រោះ១០០%គឺគេកំពុងក្ដៅចិត្តថាដែលកេតឌីម៉ាមិនញញឹម មិនចេះយកចិត្តគេដូចស្រីឯទៀត ក៏ដោយសារនាងឲ្យបេះដូងទៅសិទ្ធិគុណបាត់ទៅហើយ។ ប្រការដែលគួរឲ្យក្ដៅចិត្តជាងនេះទៅទៀតគឺនាងបានប្រើប្រាស់ចិត្តសប្បុរសរបស់ខ្លួនជាចំណុចខ្សោយដើម្បីបោកប្រាស់យកព័ត៌មានស្ដីពីការតាំងពិព័រណ៍នេះ។

-អ្នកប្រុសអញ្ជើញអង្គុយ!

គេដាក់បង្គុយចុះតាមពាក្យអង្គរក្សរឿន ដែលមានកេតឌីម៉ាអង្គុយចុះក្បែរគ្នាដែរ។

"ហោចណាស់រឿនក៏យល់ចិត្តយើងជាអ្នកណាៗ! គេពិតជាមិត្តល្អដែលយើងមានក្នុងជីវិតមែន" រាមនរិន្ទគិតបណ្ដើរ ដៀងភ្នែកទៅរកធីតារូបឆោមដែលនៅក្បែរកាយ។ អ្នកនឹកដល់កែវទឹកក្រូច និងចានអាហារពេលព្រឹកដែលមុននេះនាងបានផ្ដាប់បម្រើ ប៉ុន្តែត្រូវអ្នកបដិសេធដោយជូរចត់។ កាលដែលនាងធ្វើមុខស្រងូតមិនមែនជារឿងប្លែកទេ ប៉ុន្តែដែលប្លែកនោះគឺថានៅតែមិនទាន់ឃើញសិទ្ធិគុណបង្ហាញមុខ។ គេនឹកភ្លែតដល់សម្ដីអង្គរក្សរឿនកាលពីយប់៖

"មនុស្សរបស់យើងនៅចាយ៉ាពូរ៉ាបានបញ្ជីចុះឈ្មោះអ្នកចូលរួមដេញថ្លៃនោះក្នុងដៃ! តែក្នុងនោះខ្ញុំផែកអត់ឃើញមានឈ្មោះសិទ្ធិគុណទេ! មានន័យថាកូនប្រុសឧកញ៉ាឆាយណាគុណ មិនមែនមកចាយាពូរ៉ាដើម្បីឥន្ទបដិមាឡើយ!"។

រាមនរិន្ទនៅចាំថា ពេលនោះអង្គរក្សជំនិតទើបតែនិយាយបានពាក់កណ្ដាល ស្រាប់តែសិទ្ធិគុណបង្ហាញវត្តមាន ដែលធ្វើឲ្យការសន្ទនាត្រូវកាត់ផ្ដាច់។ ដោយសារមួហ្មងដែលឮសូរថាកេតឌីម៉ាចាកចេញពីផ្ទះនេះ គេបោះបង់ចោលការចេញទីទទួលសិទ្ធិគុណហើយឡើងទៅក្រាបគេងក្នុងបន្ទប់រហូតទល់ភ្លឺ។ មិនដឹងហេតុអីស្រាប់តែនារីនេះបង្ហាញខ្លួនសាជាថ្មីក្នុងបន្ទប់អាហារជាមួយកាយវិការផ្ដាប់បម្រើខុសពីពេលមុនល្មមឲ្យគេទន់ចិត្តដែរ ប៉ុន្តែនឹកឃើញពីសន្ដានចិត្តក្បត់មិនស្មោះត្រង់របស់នាងទោះនាងធ្វើអាហារទិព្វមកពីសួគ៌ាទទួលគេ ក៏គេលេបមិនចូលដែរ។

ឥឡូវមកដល់កន្លែងនេះ គេនៅតែចិញ្ចឹម ចិត្តចាំមើលប្រតិកម្មនាងពេលជួបសិទ្ធិគុណ ប៉ុន្តែអត់បានឃើញសញ្ញាណាមួយបង្ហាញថាបុរស ក្មេងនោះនឹងមកចូលរួមដេញថ្លៃឥន្ទបដិមានឹងគេដែរសោះ?

គេងាកទៅរកមនុស្សក្រោមបង្គាប់បម្រុងពិភាក្សាស្រាប់តែចំពេលនាយរឿនងាកមករាយការណ៍ល្មមៈ

-ថៅកែKenម៉េចក៏មកដល់ទីនេះដែរអញ្ចឹងទាន?

រាមនរិន្ទងាកមុខទៅរកគោលដៅដែលមនុស្សជំនិតកំពុងបង្ហើបប្រាប់។ គេឃើញបុរសសម្បុរសម្នាក់ហែហមដោយក្រុមអង្គរក្ស កំពុងបោះជំហានចូលមកពីក្រោមក្រសែភ្នែកចាប់អារម្មណ៍របស់មនុស្សម្នា។

ពាណិជ្ជករកូនកាត់ខ្មែរចិនដែលកាន់កាប់ទីផ្សារលោហធាតុនៅកម្ពុជា បានឱនកាយគោរពរាមនរិន្ទពីចម្ងាយជាមួយស្នាមញញឹមចិញ្ចាចរួមទាំងជំហានមាំមួន និងស្មើផេងតម្រង់មកផងដែលប្រការនេះចាំបាច់ត្រូវឲ្យអ្នកប្រុសធំនៃត្រកូលអ្នកនយោបាយក្រោកឈរទទួលដំណើរគេជាកិច្ចស្វាគមន៍តប។

-ជម្រាបសួរបងរាម!

សំឡេងគួរសមរបស់ពាណិជ្ជករក្មេង បានធ្វើឲ្យរាមនរិន្ទលូកដៃទៅស្វាគមន៍គេដោយរាក់ទាក់ ប៉ុន្តែបានធ្វើឲ្យធីតាបង្ហាញម៉ូដដែលនៅកៀកបង្កើតចាប់ញ័រដៃជើង។ ទោះបីកន្លងមកនាងដឹងគេមកដល់បាលី និងមានបំណងតាមដានសកម្មភាពរបស់រាមនរិន្ទជាសម្ងាត់ ប៉ុន្តែនាងមិនដែលដឹងទេថាគេក៏ចង់ចូលរួមពិធីដេញថ្លៃនេះ។ គេមកJayaPuraតាំងពីពេលណាក៏នាងមិនបានដឹង ហើយហេតុអីពេលនេះ គេហ៊ានបញ្ចេញមុខដោយចំហក៏នាងគិតមិនយល់ដែរ។ ពិសេសហេតុអ្វីគេដឹងថារាមនរិន្ទមកកាន់ទីនេះ បើចាប់តាំងពីចេញមកដល់ក្រុងថ្មី នាងមិនដែលបានផ្តល់ដំណឹងអ្វីទៅឲ្យគេផងនោះ?

នាងធ្វើម៉េចយល់ដល់ថា តាមពិតតាំងពីពេលដែលនាងត្រូវថ្នាំសន្លប់ និងបានដេកស្តាប់ឮអំពីព័ត៌មានរបស់ឥន្ទបដិមា គឺនាយKenទុកថាបានសម្រេចផែនការ៨០%ហើយ។ នាងលែងជានុយសម្រាប់ស៊ើបព័ត៌មានឲ្យគេទៀតហើយ ប៉ុន្តែជានុយសម្រាប់សុំរាមនរិន្ទឲ្យលំអងបានមកតាមដែរតែប៉ុណ្ណោះ ព្រោះលំអងរហ័សជាង និងឆ្លាតវាងវៃជាងក្នុងការបញ្ជូនព័ត៌មានទៅKen។

នាងឃើញរាមនរិន្ទរលាក់ដៃKenដោយទឹកមុខនឹងន។ សំឡេងគេលាន់មកច្បាស់ថែសនៅក្បែរនាង៖

-សុខសប្បាយទេKen? តាំងពីជួបគ្នាម្តងនៅNew Yorkគិតទៅជាងមួយឆ្នាំហើយមិនដែលមានពេលបានជួបជជែកលេងរឿងរកស៊ីសោះ!

Kenធ្វើជាមិនឃើញនារីរូបស្អាតដែលអ្នកណាៗក៏ចាប់អារម្មណ៍។ គេញញឹមតបសម្តីបុរសគូប្រជែង៖

-បងរាមទេដែលរវល់! ចំណែកប្អូនធ្វើការតែកំប៉ិកកំប៉ុក ចង់តែជួបនឹងអាលបានឲ្យបងរាមណែនាំរឿងរកស៊ីនឹងគេខ្លះ!

គេដៀងភ្នែកទៅរកនារីដែលខ្លួនបានប្រើឲ្យទៅបង្កប់។ កេតឌីម៉ានៅឈរជ្រងោទាំងសាច់ទាំងឈាមមានន័យថាផែនការចុងក្រោយរបស់គេត្រូវរលាយដូចអំបិលត្រូវទឹក ឬក្រមួនត្រូវថ្ងៃហើយ។ នាងអត់បានស្លាប់ទេ ក៏បានន័យថារាមនរិន្ទមិនបានប្រព្រឹត្តិហិង្សា ដែលជាហេតុឲ្យគេនៅតែអាចមានវត្តមាននៅសមរភូមិចុងក្រោយនេះ។ ចំណែករាមនរិន្ទដែលកំពុងឆ្ងល់ថាហេតុអីពិធីដេញថ្លៃតន្ទបដិមាអាចមានវត្តមានសេដ្ឋីខ្មែរម្នាក់ថែមទៀតហួសពីការរំពឹងទុកនោះត្រូវភ្ញាក់អារម្មណ៍មកវិញនៅពេលដែលគេឮសំឡេងពាណិជ្ជករដែកថែបនិយាយស្រាលៗ៖

-សួស្តីអ្នកនាងឌីម៉ា! សុខសប្បាយទេ?

**ភាគទី២៥**

រាមនរិន្ទងើបមុខប្រទះឃើញអត្ថន័យម្យ៉ាងផុសចេញពីក្រសែភ្នែកពាណិជ្ជកររូបសង្ហាដែលនៅកៀកនឹងខ្លួនបង្កើយ។ អ្នកយល់ថាកាលដែលគេស្គាល់កេតឌីម៉ាអត់មានអីចម្លែកទេ ព្រោះនាងជាមេក្រុមបង្ហាញម៉ូតដែលត្រូវប៉ាន់ក្នុងចំណោមទីផ្សារផ្សព្វផ្សាយពាណិជ្ជកម្ម ប៉ុន្តែក្រសែភ្នែករបស់នាយKenចេះតែធ្វើឲ្យគេមិនអស់ចិត្ត។

ជំនួសឲ្យសម្តីតប កេតឌីម៉ាញញឹមគួរសមដាក់បុរសដែលនាងមានរូបគេពេញបេះដូងហើយដែលនាងមិនមានលទ្ធភាពសូម្បីតែទាក់ទងទៅរកគេ ព្រោះចាប់ពីពេលដែលនាងត្រូវរងកំហឹងរបស់រាមនរិន្ទ នាងយល់ថាខ្លួនឯងប្រឡាក់ប្រឡូសរហូតដល់ថ្នាក់គ្មានមុខអីទៅស្រលាញ់គេទៀតឡើយ។ ចុងក្រោយទៀតដែលនាយរឿនទៅនាំនាងមកវិញ គេក៏បានដកហូតទូរសព្ទនាងអស់ ដែលធ្វើឲ្យទំនាក់ទំនងរវាងនាង និងនាយKenព្រមទាំងលំអងផងត្រូវកាត់ផ្តាច់ទាំងស្រុង។

ស្នូរទះដៃលាន់ឡើងជាសញ្ញាថា ពិធីតាំងបង្ហាញ និងដេញថ្លៃបានចាប់ផ្តើមហើយ។ Kenត្រូវបង្ខំចិត្តថយទៅកាន់ទីកន្លែងគួរសម ចាកចេញចោលផ្ទៃមុខក្រោមស្លូតរបស់ធីតាកេតឌីម៉ា។ រាមនរិន្ទដាក់បង្គុយមកវិញ គេឱនមុខរៀបរយសម្លៀកបំពាក់ប៉ុន្តែក្នុងចិត្តកំពុងត្រិះរិះថាបុរសពាណិជ្ជករដែកថែបដែលបង្ហាញខ្លួនគួរឲ្យភ្ញាក់ផ្អើលនៅចាយ៉ាពូរ៉ា ធ្វើម៉េចអាចទទួលបានដំណឹងពីការដេញថ្លៃនេះកើតបើខ្លួនគេមានមនុស្សដូចស្រមោចផងនៅតែធ្វើការនេះយ៉ាងលំបាក?

គេសម្លឹងសាជាថ្មីទៅកាន់នាយKenដែលនៅតុងជួរម្ខាងលាយឡំជាមួយពាណិជ្ជករបរទេសនានា។ ទឹកមុខម៉ឺងម៉ាត់នៃអង្គរក្សនាគខ្លា(នាយហ៊ូ និងនាយឡុង) ដែលនៅពីក្រោយខ្នងគេហាក់បង្ហាញស្រាប់ហើយថា ពាណិជ្ជករកូនកាត់ចិនមិនមែនគ្មានគោលដៅច្បាស់លាស់ក្នុងការមកកាន់ទីនេះទេ បើមិនអញ្ចឹងគេក៏មិនចាំបាច់មានកងការពារមកតាមដែរ។ ឬមួយថាគេក៏ចង់បានឥន្ទបដិមា?

ការដេញថ្លៃវត្ថុបុរាណជាច្រើនបានរំលងទៅយឺតយ៉ាវណាស់បើធៀបទៅនឹងសន្ទុះចិត្តរង់ចាំចង់ឃើញឥន្ទ បដិមារបស់បុរសទាំងទ្វេ។ ចំណែកសិទ្ធិគុណនៅតែមិនឃើញសូម្បីតែស្រមោល។ នាយKenហាក់មិនបានបង្ហាញការចាប់អារម្មណ៍អ្វីសូម្បីតែបន្តិចចំពោះរតនវត្ថុនានា ដែលកាន់តែធ្វើឲ្យនាយរឿន និងរាមនរិន្ទប្រាកដចិត្តថាឥន្ទបដិមានរាធិបតិន្ទទើបជាវត្ថុបំណងពិតប្រាកដរបស់គេ។

ស្លូវក្អកតិចៗរបស់នារីបង្ហាញម៉ូតធ្វើឲ្យរាមនរិន្ទដកការគិតចេញពីឥន្ទបដិមាហើយងាកមករកនាង។ ស្នូរដង្ហើមរបស់នាង និងសញ្ញាក្រហមលើបបូរមាត់ក៏ដូចគ្រាប់ភ្នែកក្រៀមក្រំបញ្ជាក់ស្រេចហើយថានាងកំពុងមានបញ្ហាសុខភាព។

ការសំកុកដាក់ទណ្ឌកម្មខ្លួនក្រោមផ្សែងអ័ព្ទត្រជាក់នាសួនឧទ្យានព្រីម៉ាដល់រំលងអាធ្រាត បានធ្វើទុក្ខទោសនាងបន្ថែមពីលើទណ្ឌកម្មផ្លូវចិត្ត និងកាយដែលមុននេះរាមនរិន្ទបានធ្វើ។ ទោះអាណិតនាងព្រួចតែគេនៅតែងាកមុខមកវិញធ្វើដូចស្ពាន់ត្រូវភ្លើងនៅតែមិនដឹងក្តៅ។ រាមនរិន្ទ ដឹងប្រាកដថាចិត្តខ្លួនបែរទៅជាទន់ជ្រាយយ៉ាងរហ័សចំពោះមុខស្រីម្នាក់ ដែលមុននេះ មិនធ្លាប់មានថ្ងៃណាដែលនឹកនាដល់នាងបន្តិចណាសោះ។ បើថាព្រោះតែរូបសម្ផស្សដ៏ស្រទន់នោះ ក៏មិនមែនថាព្រោះតែអ្នកស្រណោះដល់រាត្រីដំបូងជាមួយនាងក៏មិនត្រូវតែបើសំអាងលើឫកពាប្លែករបស់ឌីម៉ាប្រហែលត្រូវជាង ព្រោះកន្លងមកនរៈយើងមិនធ្លាប់ជួបនារីណាដែលមានអត្តចរិតបែបនេះចំពោះមុខខ្លួនទេ ...។កាលពីល្ងាចម្សិលគេខឹង ចិត្តខ្លាំងបំផុត គឺពាក្យពេចន៍ផ្អែមល្ហែមមិនធ្លាប់បានលឺនៅចំពោះមុខខ្លួនបែរជាពុនាងបញ្ចេញតាមទូរស័ព្ទទៅកាន់ប្រុសផ្សេងទៅវិញ។

-វត្ថុបុរាណចុងក្រោយគេដែលនឹងបង្ហាញចេញក្នុងពេលនេះ គឺ ឥន្ទប្បដិមា នរាធិបតិន្ទ!

សូរប្រកាសរបស់អ្នករៀបចំកម្មវិធីធ្វើអោយរាមនរិន្ទភ្ញាក់ចេញពីអារម្មណ៍បាចសាច។ គេរវៃភ្នែកទៅម្ខាងឃើញនាយKenកំពុងញញឹមចិញ្ចាចមករកខ្លួនជាថ្មី។ គេហាក់មិនខ្លាចក្រែងក្នុងការបង្ហាញថាគេពិតជាមកកាន់ចាយ៉ាពូរ៉ាដើម្បីតែវត្ថុនេះ ហើយគេក៏មិនខ្លាចក្នុងការប្រជែងដោយចំហជាមួយអ្នកប្រុសធំមកពីគ្រួសារតំណាងរាស្ត្រដែរ។

រាមនរិន្ទញញឹមគួរសម តបទៅកាន់បុរសពាណិជ្ជករដែកថែបរួចងាកមករកប្រអប់កញ្ចក់ភ្លឺរន្ទាលដែលទើបតែត្រូវបានរុញចេញមកដោយនារីពីរនាក់។

"លោកពុក! កូនត្រូវតែកាន់ឥន្ទប្បដិមា នរាធិបតិន្ទត្រឡប់ទៅវិញទោះយ៉ាងណាក៏ដោយ! "គេប្រាប់ខ្លួនឯងស្ងាត់ៗព្រោះគិតស្រេចហើយថាត្រឹមពាណិជ្ជករកូនកាត់ខ្មែរ ចិននោះគ្មានអ្វីអាចសំអាងមកប្រជែងជាមួយខ្លួនក្នុងពេលនេះឡើយ។

សំឡេងអ្នកប្រកាសបន្តមកនូវប្រយោគដែលធ្វើឲ្យអ្នកផងកាន់តែចាប់អារម្មណ៍៖

-សូមស្វាគមន៍ដល់លោក រ៉ាទូ ដែលជាម្ចាស់ឥន្ទប្បដិមា នរាធិបតិន្ទ!

ស្នូរទះដៃកាន់តែលាន់ឮរំពង ហើយបុរសខ្មៅទាប និងធាត់កន្ទុកម្នាក់បោះជំហានចេញមកដោយទឹកមុខអំនួត។ នៅពេលដែលស្នូរទះដៃរលត់ទៅហើយនៅក្នុងសាលទាំងមូលនៅសល់តែស្នូរដង្ហើមអភិជនស្រីប្រុសដែលអន្ទះសាចង់ឃើញវត្ថុសេសសល់ដ៏កម្រពីបុព្វកាលសម័យរបស់ព្រះរាជាណាចក្រដ៏រុងរឿងមួយនៅភូមិភាគអាស៊ី បុរសមាឌទាបប្រឹងគ្រហែមទាញអារម្មណ៍សាលទាំងមូលមកវិញ។ គេនិយាយមួយៗលាន់ឮយ៉ាងរំពងជ្រែកកាត់ភាពស្ងប់ស្ងាត់៖

-ឥន្ទប្បដិមា នរាធិបតិន្ទដែលកំពុងស្ថិតនៅចំពោះមុខភ្ញៀវកិត្តិយសនេះមានប្រវត្តិនៅចន្លោះឆ្នាំ៨១០-៨៤៥គ.ស។ តាមដឹងតៗមកគឺបុរាណវត្ថុដ៏ប្រណិតនេះមានប្រភពមកពីប្រទេសឡាវហើយត្រូវបានរសាត់អណ្តែតជាច្រើនកន្លែងរហូតមកដល់ទីនេះ។ មានការបកស្រាយច្រើនគ្នាពីអាថ៌កំបាំងនៃការធ្វើចរាចរណ៍របស់ ឥន្ទប្បដិមា នរាធិបតិន្ទដោយសារមានអ្នកខ្លះគេគិតថាវាជាស្នាដៃសិល្បៈមហាសាលរបស់មនុស្សជាតិដែលមានអាយុកាលជាង១០០០ឆ្នាំ ខ្លះថាជាវត្ថុបង្កប់ជាមួយនូវវេទមន្ត និងភាពជាសេរី ចុំថ្កើង។ វត្ថុបុរាណមួយនេះបានរសាត់មកដល់កោះស្មៅសៀងរបស់យើងកាលពីឆ្នាំមុន។ នៅថ្ងៃនេះយើងសម្រេចចិត្តដាក់ឲ្យដេញថ្លៃឥន្ទប្បដិមា ដោយសារថាយើង

ចង់ឲ្យវត្ថុនេះបានដល់ដៃអ្នកដែលមានលទ្ធភាពក្នុងការថែរក្សា និងជាការលើកស្ទួយតម្លៃរបស់អ្នកដែលខំបង្កើតឲ្យមានឥន្ទប្បដិមាមកលើផែនដីនេះ!

នាយKenដៀងភ្នែកមករកវាមនរិន្ទដែលកំពុងអង្គុយនឹងថ្កល់ស្តាប់បុរសមកពីកោះស្មៅលឿងលើកឡើងពីប្រវត្តិបុរាណវត្ថុចុងក្រោយ។ តាមពិតគឺកំពុងរង់ចាំមើលប្រតិកម្មរបស់នរៈយើងថាតើគេចាប់អារម្មណ៍យ៉ាងណាដោយសារថា ម្ចាស់បុរាណវត្ថុដែលខទ្វេសនាមថាឥន្ទប្បដិមាមានប្រភពមកពីប្រទេសឡាវបានធ្វើអោយគេស្រងាកចិត្តបន្តិចដែរ។ តែក្រឡេកមកមើលអ្នកប្រុសមកពីគ្រួសារតំណាងរាស្ត្រដែលហាក់មិនបញ្ចេញនូវមនោរម្មណ៍អ្វីសោះធ្វើអោយពាណិជ្ជករដែកថែបកាន់តែអន្ទះសា។ គេក្រឡឹងគ្រាប់ភ្នែកសម្លឹងមនុស្សជុំវិញខ្លួន ល្មមពេលត្រចៀកស្តាប់ឮបុរសរាងទាបតឿនិយាយបន្ត៖

-ឥន្ទប្បដិមា នរាធិបតិន្ទរសាត់អណ្តែតរាប់ពាន់ឆ្នាំ អាចបង្ហាញថាអ្នកដឹងប្រវត្តិវត្ថុនេះ បានព្យាយាមថែរក្សាដោយឆ្លងកាត់សម័យនានាស្ទិតស្វាញណាស់។សូមភ្ញៀវកិត្តិយសអោយតម្លៃសំខាន់មួយដល់វត្ថុបុរាណមួយនេះ ហើយចាប់ដេញថ្លៃពី១០០លានRupiahs ឡើងទៅ!

នាយKenនៅសំងំស្ងៀមប៉ុន្តែគេលួចសៅហ្មងក្នុងចិត្ត។គេគិតតែម្នាក់ឯងថា៖

-ចាប់ផ្តើមពីលុយជាងមួយសែនដុល្លារឡើងទៅ? ចុះបើរបស់នេះមិនមែនជា ឥន្ទប្បដិមា នរាធិបតិន្ទពិត?

ភាសាអង់គ្លេសរបស់សេដ្ឋីឥណ្ឌាមួយលាន់ឡើងរំពង កន្ត្រាក់អារម្មណ៍ភ្ញៀវទាំងឡាយ ដែលកំពុងរក្សាភាពស្ងប់ស្ងាត់៖

-លោកវ៉ាទូ! មានពិធីដេញថ្លៃណាដែលកំណត់តម្លៃមុនពេលបានឃើញរបស់នោះ?

ត្រូវហើយ! Kenពេញចិត្តចំពោះនៃនេះបំផុតព្រោះគេកំពុងចង់ដឹងដោយអន្ទះសាថា ឥន្ទប្បដិមា នរាធិបតិន្ទដែលគេកំពុងប្រជែងយកជាមួយបុរសកូនតំណាងរាស្ត្រនោះ មានរូបរាងពិតរបៀបណាដែរ? គេសម្លឹងទៅក្រណាត់កាំម្ទីក្រហមរលោងដែលក្រាលគ្របទៅលើបុរសមកពីកោះស្មៅលឿងសើចក្អាកក្អាយមិន ខ្វល់ខ្វាយចំពោះក្រសែភ្នែកទើសចិត្តនៃអភិជនទាំងឡាយឡើយ។ គេនិយាយដោយទឹកមុខក្រអឺត៖

-មនុស្សច្រើនពេកហើយ! ខ្ញុំសុំត្រឹមតែអ្នកដែលចាប់អារម្មណ៍ ឥន្ទប្បដិមា នរាធិបតិន្ទប៉ុណ្ណោះដែលគួរនៅមើលរូបរាងពិតរបស់វត្ថុនេះ! បានន័យថាអ្នកដែលហ៊ានចាប់ផ្ដើមដេញថ្លៃទើបអាចមានសិទ្ធិនៅ!

Kenចងចិញ្ចើមនៅពេលដែលរបៀបរបបដេញថ្លៃរបស់នេះមានភាពខុសប្លែកពីគេ ប៉ុន្តែក្នុងភាពជាសុភាពបុរស និងជាអ្នកសម្រេចការធំ គេនៅថែរក្សាទឹកមុខនិងមិនមានប្រតិកម្មអ្វីទាំងអស់។ ប៉ុន្តែសេដ្ឋីឥណ្ឌាមិនមានភាពអត់ធ្មត់ដូចអភិជនកម្ពុជាទាំងពីរឡើយ។ គេក្រោកឈរស្រែកឡូឡាដោយមានអង្គរក្សក្រោកឆ្វេចឆ្វាចការពារផង៖

-ឯងឆ្កួតទេដែលចង់ឲ្យយើងបិទភ្នែកទិញរបស់?

បញ្ចេញសម្ដីអសុរសហើយគេងាកដើររ៉ុយចេញចោលពិធីកណ្ដាលភាពខ្សឹបខ្សៀវរវីកកងរំពង។

-ដេញថ្លៃ មុនមើលរបស់យ៉ាងម៉េចនៀក?

-អីក៏ចម្លែកម៉េះ?

-តាហ្នឹងដូចជាក្រអឺតក្រអោងមែនវ៉ុ!

នៅពេលពាក្យរអ៊ូកាន់តែលាន់ឮខ្សៀវខ្សារ កេតឌីម៉ាដែលនៅសម្ងំស្ងៀមដោយការធ្វើទុក្ខបុកម្នេញសុខភាពដៀងភ្នែកមករកបុរសក្បែរកាយ។ នាងក៏ចង់ដឹងដែរថា តើគេមានគំនិតសៅហ្មងដូចបុរសឥណ្ឌាឬយ៉ាងណា ប៉ុន្តែមិនទាន់បានឃើញមុខគេផងក្រសែភ្នែកវាក់ទៅនឹងពាណិជ្ជករម្ចាស់ចិត្តដែលសម្លឹងមកពីនាយ។ ពន្លឺភ្នែករបស់Kenហាក់ចង់សួរថា តើនាងដឹងទេថារាមនរិន្ទគិតយ៉ាងម៉េច ប៉ុន្តែស្រស់ស្រីបានត្រឹមដកខ្សែភ្នែកមកវិញ ព្រោះដឹងថាខ្លួនគ្មានលទ្ធភាពអីនឹងឆ្លើយតបសំនួរគេឡើយ។

តរុណីដែលមានវិបត្តិពេលឃើញមុខសង្សារសម្លាញ់ចិត្តកាលណា ចេះតែមានអារម្មណ៍ថាបានធ្វើខុសឆ្គងចំពោះគេ ដោយសារថានាងមិនត្រឹមតែជាស្រីខ្វះភាពបរិសុទ្ធ ថែមទាំងមកប្រឡាក់ប្រឡូសលើកទី២ជាមួយរាមនរិន្ទទៀត តើឲ្យនាងមានទំនុកចិត្តអ្វីក្នុងការប្រឈមមុខជាមួយKen។ ពេលនេះទៀតកណ្ដាលចំណោមមនុស្សម្នា នាងគួរតែមានវត្តមានជិតប្រុសកំពូលស្នេហ៍ តែបែរជាដើរមកអមបុរសផ្សេងក្នុងនាមជាស្រីកំដរគេ។ នាងគិតម្នាក់ឯងទាំងញាប់ញ័រក្នុងទ្រូង៖

"បងKen! យប់មិញ នៅព្រៃម៉ាហ្គាឌិន អូនគិតច្បាស់ណាស់អូនមិនទាក់ទងទៅបងព្រោះអូនអស់មានអីដែលជាទីសង្ឃឹមក្នុងការផ្ញើមនឹងបងទៀតហើយ! បងល្អ ហើយខ្ពស់កប់ពពក អូនទាប ហើយ

កខ្វក់! អូនបានត្រឹមតែកាត់ចិត្ត ហើយបំភ្លេចបង! បងនឹងសក្តិសមជាមួយស្រីអភិជនដែលល្អបរិសុទ្ធដូចគ្នា! អូនសូមទោសដែលបានធ្វើខុសចំពោះចិត្តស្នេហ៍របស់បង! អូននឹងលែងជួបបងរហូត! ដើម្បីអោយបងKenបំភ្លេចអូនដូចគ្នា״។

មានអារម្មណ៍ថា បើនៅតែអញ្ចឹងទឹកភ្នែកដែលរកកលនឹងហូរចេញមកនោះនឹងធ្វើអោយរាមនរិទ្ធដឹងខ្លួនមិនខាន។ រួចនិយាយតិចៗដាក់នរិទ្ធដែលនៅក្បែរះ

-លោកប្រុសរាម ខ្ញុំសុំទៅបន្ទប់ទឹកសិន!

នរិទ្ធមិនតបនឹងស្រស់ស្រីតែគេងាកទៅរករឿននៅខាងឆ្វេងដៃះ

-ទៅជាមួយឪម៉ាទៅ!

មិនដឹងថាគេអោយអង្គរក្សជំនិតទៅតាមនាងព្រោះតែបារម្ភឬមួយ តាមឃ្លាំមើលនាងនោះទេ។ តរុណីក្រោកសន្សឹមៗ ប៉ុន្តែនាងស្រាប់តែចាប់អារម្មណ៍ថាក្បាលធ្ងន់ពាប់ ហើយវិលមុខខ្វាល់។ ចំហាយក្តៅភាយៗនៃជំងឺគ្រុនផ្តាសាយដែលធ្វើទុក្ខបុកម្នេញដោយសារការនៅក្រោមសន្សើមត្រជាក់ពេញមួយយប់ បានបញ្ចេញឥទ្ធិពលពេញរាងកាយពីក្បាលដល់ចុងជើងធ្វើឲ្យស្រស់កល្យាណមិនអាចទប់ជំហរបាន ទៅជាទ្រេតទ្រោតរួចដួលទ្រោបទៅលើបុរសមានអំណាចតែម្តង។

ក្នុងពេលដែលបរិយាកាសទៅជាងងឹតនាងទទួលអារម្មណ៍ថាបាតដៃក្តៅអ៊ុនៗ និងទន់ល្មើយកំពុងក្តោបចង្កេះទប់ជំហរនាង។ ប្រាកដជាបាតដៃដែលនាងធ្លាប់ស្គាល់។

សព្ទសំឡេងសេដ្ឋីម៉ាការម្នាក់ដែលនៅអង្គុយជួរខាងមុខនាងនិយាយខ្លាំងៗបំបាត់ភាពអនាធិបតេយ្យក្នុងពិធីដ៏ចំឡែកះ

-១៥០លាន!

ផ្ទុយពីអ្នកផងដែលត្រូវភ្ញាក់ផ្អើលដោយការចាប់ផ្តើមដេញថ្លៃដោយមិនទាំងបានឃើញរបស់ផងនោះ រាមនរិទ្ធបែរជានិយាយតិចៗមកក្បែរត្រចៀកះ

-នាងយ៉ាងម៉េចហើយ?

ស្រីស្រស់ដឹងថានាងកំពុងបង្កើតបញ្ហាក្នុងថេរវេលាដ៏សំខាន់របស់ពួកគេ នាងប្រឹងប្រមូលកម្លាំងទប់ខ្លួនក្រោករួចចាកចេញពីរង្វង់ដៃគេ ទាំងនិយាយតបខ្សឹះ

-សូមទោស!

នាងដើរឃើតៗចេញទៅដោយដកដៃចេញពីប្រអប់ដៃគេ ប៉ុន្តែគេនៅតែមិនដាច់ចិត្តលែងកដៃនាងសោះ។ ដោយមាននាយអង្គរក្សរឿនក្រោកមកជិត រាមនរិន្ទទៅរកគេ៖

-រឿន! កេតឌីម៉ាក្តៅខ្លួនណាស់!

គេលែងដៃនាងសន្សឹមឲ្យនាងចាកចេញទៅដោយមានមនុស្សជំនិតដើរទៅតាមពីក្រោយ។ នៅគ្រប់ជំហាន ដែលសឹងថាគ្មានកម្លាំងក្នុងការឈោន នារីបង្ហាញម៉ូតចាប់ផ្តើមមានអារម្មណ៍ចម្លែក។

"ហេតុអ្វីមុននេះយើងដូចជាគ្មានកម្លាំងខ្សោះខ្លួនហើយដួលទាំងជំហរលើគេ? ហេតុអ្វីពេលគេលូកដៃមកទប់ចង្កេះយើង យើងមានអារម្មណ៍កក់ក្តៅ និងរឹងប៉ឹងឡើងវិញលឿនម្ល៉េះ? ហេតុអ្វីក៏បាតដៃគេដូចជាស្និទ្ធស្នាលធ្លាប់ស្គាល់គ្នាយូរមកហើយអញ្ចឹង? សម្តីគេចុងក្រោយតើគេយកចិត្តទុកដាក់នឹងយើងមែនឬមួយគេមានបំណងអ្វី?"។

សំឡេងមួយផ្សេងទៀតលាន់ឡើងរំពងសាលដេញថ្លៃ៖

-ខ្ញុំ Ema Lee ខ្ញុំគាំទ្រសម្តីលោករាទូ! របស់ល្អសម្រាប់តែអ្នកដែលហ៊ានថ្លៃទេ! ខ្ញុំឲ្យ ២០០លានរូពី! ខ្ញុំអាចនៅមើលបានទេ!

តរុណីដើរបណ្តើរគិតបណ្តើរ៖

-ពួកអ្នកមានអត់ការធ្វើ! សព្វបើរបស់មួយដែលគ្រាន់តែឮគេនិយាយមិនទាន់បើកឲ្យមើលផង គេហ៊ានយកលុយរាប់សែនមកដេញថ្លៃបង្អួតគ្នាទៅហើយ? តើយើងពិតជាដើរមិនទាន់ពិភពលោកនេះ ឬមួយពួកគេសុទ្ធតែជាមនុស្សមានបញ្ហាខួរក្បាល?

ប៉ុន្តែសំឡេងបុរសម្នាក់ដែលនាងចងចាំបានច្បាស់លាន់ឡើងស្មើផេងតែខ្លាំងៗ៖

-ខ្ញុំអោយ៥០០លានRupiahs !

នារីនៅទុចដំណើរខណៈនាយរឿនងាកក្រោយវឹង។ ដោយសារគេនៅជិតៗនាង ម្លោះហើយនាងអាចស្តាប់ឮពាក្យរអ៊ូរបស់គេភ្លាមៗនោះដែរ៖

-អ្នកប្រុសប្រញាប់អីម្លេះ?

នារីរូបល្អបែរក្រោយសន្សឹមៗព្រោះថាតម្លៃចុងក្រោយដែលរបូតចេញពីមាត់រាមនរិន្ទខ្ពស់ហួសពីអ្នកផង។ មានន័យថាគេជាមនុស្សឆ្កួតបំផុតក្នុងចំណោមពួកអ្នកឆ្កួតនឹងទឹកប្រាក់នៅទីនេះតើមែនទេ?

ក្រសែភ្នែកទាំងអស់បោលសម្រុកមករករាមនរិន្ទក្នុងពេលដែលឌីម៉ាសម្គាល់ឃើញថាពាណិជ្ជករដែកថែបKenក៏ភ្ញាក់សឹងថារបូតធ្លាក់កាយពីកៅអី។

ស្នូរផ្ទុះផ្លូង បានបញ្ចប់បរិយាកាសដ៏រំភើបនៃការដេញថ្លៃដែលចម្លែកគ្មានពីរលើលោកជំនួសមកវិញនូវសម្រែកខ្សៀវខ្សារដោយការភ័យខ្លាចសេចក្ដីមរណរបស់បណ្ដាអភិជនទាំងឡាយដែលកំពុងមានវត្តមាននៅទីនេះ។

ភ្លើងរលត់ភ្លឹប....ហើយបរិយាកាសប្រែជាលែងអាចគ្រប់គ្រងបាន...។ ខ្យល់ដង្ហើមចាប់ផ្ដើមហ៊ុមព័ទ្ធដោយក្លិនរំសេវ...

សូម្បីតែនាយរឿនដែលនៅតែចម្ងាយមិនដល់កន្លះម៉ែត្រពីកាយក៏កេតឌីម៉ាមើលលែងឃើញហើយដែរ។ ទ្រូងនាងចាប់ញ័ររន្ធត់ក្រោយពេលឮសម្រែកខ្លាំងៗរបស់បុរសឈ្មោះរ៉ាទូ៖

"យកតន្ទបដិមាទុក! មានរឿងមិនស្រួលហើយ!"

ធីតាចាប់ផ្ដើមស្លន់ស្លោនៅពេលដែលនាងលែងរកឃើញច្រកចេញហើយផ្សេងបានសម្រុកមករំខានការដកដង្ហើម។ រំពេចនោះភ្លើងក្រហមគ្រាអាសន្នរបស់សណ្ឋាគារបានបំភ្លឺភ្លឹបបង្ហាញចេញនូវបរិវេណដេញថ្លៃដែលប្រែទៅជាច្របូកច្របល់។

តុកៅអីដួលច្រងាង ហើយមនុស្សម្នាដណ្ដើមគ្នារត់បញ្ច្រាសទិសគ្នា។ នាងរវៃភ្នែកសម្លឹងជុំវិញខ្លួនព្រោះថាមិនដឹងត្រូវចេញទៅតាមទិសណាមួយឡើយដោយសារការវង្វេងដោយអារម្មណ៍ស្លុងស្លុត។ ដោយសារសុខភាពកំពុងខ្សោយស្រាប់នៅក្នុងបរិវេណដែលនាងគិតថាគ្មានអ្នកណានៅឈរនឹងថ្កល់ដូចនាងទៀតនោះ នាងស្រាប់តែប្រទះឃើញមានគេម្នាក់កំពុងឈរទ្រឹងហើយសម្លឹងមកនាងវិញ។ ទោះបីយ៉ាងណានាងហាក់អរភើតពេលឃើញគេ ហើយគេក៏ស្ទុះមករកនាងក្នុងពេលតំណាលគ្នា។ បុរសនោះលូកដៃចាប់កដៃនាងជាប់រួចអូសទាញចេញទៅតាមទិសខាងឆ្វេងដៃដោយមានបុរសជំនិតខ្ពស់ស្រាវរត់មកតាមផង។

នាយរឿននិយាយក្នុងសភាពប្រញិបប្រញាប់៖

-អ្នកប្រុស! យើងចុះតាមជណ្ដើរជើងវិញ!

**ភាគទី២៦**

រាមនរិន្ទបង្វែរទិសតាមយោបល់នាយជំនិតដោយមានទាំងស្រី ស្អាតក្នុងដៃទៅជាមួយផង។ មកដល់ជណ្ដើរខាងក្រៅបន្ទប់អ្នកទាំងបីរត់ចុះប្រញិបប្រញាប់ពេលសន្ទឹកគ្រាប់ផ្ទុះឡើងជាលើកទី២លាន់រំពងជាងមុន។ នៅក្រោមឥទ្ធិពលនៃភាពតក្កមាដែលគ្របដណ្ដប់ដោយសម្រែកខ្សៀវខ្សារជុំទិស ឌីម៉ាទៅជាទន់ជង្គង់ និងល្វើយក្រោមឥទ្ធិពលផ្សែងងងឹតស្លុប។ នាងប្រឹងរលាស់ដៃពីរាមនរិន្ទដោយសារចាប់អារម្មណ៍ថាខ្លួនប្រាណនាងមិនអាចអណ្ដែតទៅបន្តទៀតតាមបុរសទាំងពីរទៀតឡើយដោយសារមានអ្វីមួយកំពុងចងរឹតជើងនាងឲ្យនៅទ្រឹងមួយកន្លែង។ រាមនរិន្ទបញ្ឈប់ចលនាហើយងាកមកមើលមាណវីដែលកំពុងជំនះទាញជាយសំពត់ចេញពីផ្នាក់ដៃជណ្ដើរ។ ផ្នាក់ដៃធ្វើពីឈើដែលបានបែកបាក់ដោយអន្លើព្រោះជញ្ជាំងថ្មត្រូវបន្ទុះបាក់ជំហរសង្កត់នោះបានកៀបទាញសំពត់នារីកាន់កៀកបន្តិចម្ដងតាមកម្លាំងទ្រេតដែលចេះតែធ្ងន់ឡើងៗជាលំដាប់នោះឲ្យរាមនរិន្ទអាចទាយដឹងស្រេចហើយថាមិនយូរទេបង្កាន់ដៃឈើនេះនឹងទាញរបូតរ៉ូបស្បៃវែងរបស់នាងតែម្ដង។ គេលែងដៃពីស្រស់ស្រីដែលភ័យស្លេកមុខ ហើយឱនមកពិនិត្យកន្លែងដែលទាក់នោះក្រែងមានមធ្យោបាយអាចស្រាយចេញ ប៉ុន្ដែជញ្ជំងថ្មដែលកាន់តែទ្រេត និងហុយសំពោងបានរារាំងការងារនេះ។ មនុស្សម្នាដែលនៅទើរជណ្ដើរកាន់តែប្រជែងគ្នាចុះទៅខាងក្រោមរុញទាំងអង្គរក្សរឿនឲ្យឃ្លាតកាន់តែឆ្ងាយពីអ្នកទាំងពីរ។

គេស្រែកកាត់ភាពខ្សៀវខ្សារមកកាន់មនុស្សដ៏សំខាន់បំផុតរបស់គេ៖

-អ្នកប្រុស! ចុះមក! ជញ្ជាំងបាក់អីឡូវហើយ!

រាមនរិន្ទងើបមុខសម្លឹងនារីបង្ហាញម៉ូតដែលមុខប្រែទៅជាក្រហមដូចងើកភ្លើង។ គេដឹងថានាងមានបញ្ហាសុខភាពតាំងពីមុននេះម្ល៉េះនៅក្នុងស្ថានភាពបែបនេះទៀតនាងមិនអាចទ្រាំទ្របានយូរឡើយ។ គេស្ទុះក្រោកនិយាយតិចៗដោយសម្លឹងភ្នែកនាង៖

-ឌីម៉ា? មានខោអាវខាងក្នុងទេ? សំពត់នេះដោះចេញបានទេ?

រ៉ូបចងពុងវែងអន្លាយ បើដោះចោលដើម្បីជីវិតរស់មានអីខុសប្លែកពីព្រមអាក្រាតកាយនោះ? នារីគ្រវីក្បាលញាប់ស្ទេរះ

-អត់ទេ! អត់ទេលោកប្រុសរាម!

ពន្លឺភ្នែកវេញត្របាញ់ចូលគ្នា ទោះមិនបាច់និយាយច្រើនក៏រាមនរិន្ទដឹងថានាងគ្មានផ្លូវជ្រើសយកវិធីនេះឡើយ។ ចំណែកគេត្រូវតែធ្វើអ្វីម្យ៉ាងក្នុងពេលនេះ។

-ចាំនៅហ្នឹង! កុំរើឲ្យសោះ!

បន្ទាប់ពីវាចាពីឃ្លានេះ គេបែរក្រោយស្ទុះត្រឡប់ទៅជាន់ខាងលើបញ្ច្រាស់ពីក្រុមអ្នកភ័យស្លន់ស្លោដែលកំពុងរត់សម្រុកចុះមក។ ក្រសែភ្នែកនាយរឿនដែលត្រូវកៀងដោយក្រុមមនុស្សនៅជាន់ខាងក្រោមបង្ហាញចេញនូវភាពហួសចិត្ត។ ឯកេតឌីម៉ាស្រក់ទឹកភ្នែកសស្រាក់ដោយសារបង្កាន់ដៃឈើកំពុងរេចលនាទាញសំពត់នាងកាន់តែកៀកឡើងៗរហូតដល់នាងរើលែងរួចតែម្តង។ ស្ទួរជញ្ជាំងថ្មដែលត្រូវរងកម្លាំងរំសេវយ៉ាងដំណំនៅតែបន្តសូរប្រេះប្រសរកកលនឹងរលំ។ មួយវិនាទីនោះនាងដឹងថា ប្រសិនបើរាមនរិន្ទមិនត្រឡប់មកវិញទេនាងនឹងត្រូវសង្កត់នៅក្រោមនោះជៀសមិនរួចឡើយ។

ស្រមោលអ្នកណាម្នាក់ធំខ្ពស់បានរត់មកកាត់ពីមុខនាង។ គ្រាន់តែឃើញដំណើរគេក៏នាងដឹងថាជាអ្នកណា។ នាងភ្លាត់មាត់តាមអារម្មណ៍ត្រេកអរ៖

-បងKen!

ពាណិជ្ជករលោហធាតុនៃសហគ្រាសCam Steelដែលបានមើលឃើញស្ថានភាពនាងតាំងពីគេមិនទាន់រត់មកដល់នេះផង គេងាកមកមើលនាងដោយភាពរលះរលាំងលើផ្ទៃមុខ តែគេមិនបានទុចដំណើរទេ។ កាលដែលនាងយល់ថា Kenនឹងនៅប្តូរជីវិតជួយនាងតាមនិស្ស័យជាគូរស្នេហ៍នោះគឺខុសស្រលះហើយ ព្រោះសម្រាប់ Ken ពិភពលោកនេះនៅមានវត្ថុមានតម្លៃជាច្រើនណាស់ដែលគេត្រូវយកមកគ្រប់គ្រងឲ្យបាន ដូច្នេះគេគ្មានហេតុផលអ្វីត្រូវមករវីរវល់នឹងរឿងបេះដូងស្នេះរបស់ស្រីៗទេ ចំណែកក្នុងកាលៈទេសៈនេះទៀតសោត គឺរឹតតែសូន្យតែម្តង។

កេតឌីម៉ាអរភើតនៅពេលដែលកែវភ្នែកទាំងគូរកំពុងជំពាក់ជាមួយភ្នែកបុរសដែលនាងមានគេពេញបេះដូង។ បបូរមាត់នាងផុសចេញនូវស្នាមញញឹមទាំងទឹកភ្នែកកំពុងស្រក់។ នាងនិយាយទាំងរអាក់រអួល៖

-បងKen! ជួយផង!

បុរសសង្ហាមិនចេញស្តី តែឱនសម្លឹងជាយសំពត់នាង និងជញ្ជាំងថ្មនៅនឹងបង្អើយដែលរកកលនឹងរលំមកក្នុងពេលបន្តិចទៀតនេះ។ គេក្តាប់ដៃបោះជំហានចុះទៅក្រោមបន្តក្រោមក្រសែភ្នែកស្រឡាំងកាំងរបស់នាងក្រមុំឆោតល្ងង់។

ភាពតក់ក្រហល់ ខ្វល់ខ្វាយពីសេចក្តីស្លាប់ លែងមានទៀតហើយ។ ភាពភ័យខ្លាច និងស្លន់ស្លោត្រូវរលត់បាត់ទៅជាមួយនឹងភាពភ្ញាក់ផ្អើល ប៉ុន្តែមិនមែនភ្ញាក់ផ្អើលល្អទេ គឺអស់សង្ឃឹម។

"នេះឬមនុស្សប្រុសដែលយើងបានស្រលាញ់ និងបានធ្វើអ្វីៗទាំងអស់ដើម្បីគេ?"នាងសួរខ្លួនឯងទាំងឈរទ្រឹង។

ពន្លឺភ្នែកគេដែលធ្លាប់តែស្រទន់ និងបបូរមាត់ដែលធ្លាប់តែបញ្ចេញភាសាផ្អែមល្ហែម ទីបំផុតមិនបាននិយាយតបនាងសូម្បីតែមួយម៉ាត់ឡើយនៅគ្រាដែលនាងកំពុងត្រូវការនាយបំផុត។ ស្រស់ស្រីនៅឈរទ្រឹងលែងរវល់នឹងអ្វីសូម្បីតែរាមនរិន្ទរត់មកដល់ជាមួយកូនកាំបិតក្នុងដៃក៏នាងមិនបានដឹងរហូតដល់នរៈឱនកាត់ចោលចំណែកសំពត់ស្បៃរបស់នាងដែលនៅជាប់គាំងនោះរួចរាល់ហើយក៏នាងមិនបានដឹង។

រាមនរិន្ទដែលទើបតែមកដល់មិនបានដឹងពីហេតុផលក្នុងការធ្វើឲ្យនាងក្រមុំទៅជាបាត់វិញ្ញាណដូច្នេះទេ គេងើបមុខសម្លឹងព្រោះថាមិនឃើញនាងឈានជើងទៅមុខសោះ ប៉ុន្តែកំណាត់ឈើនៃស៊ុមរូបគំនូរប្រវែងប្រមាណមួយទំហឹងដៃមនុស្សចាស់ដែលមុននេះប៉ើងទៅទើរលើបង្កាន់ដៃផ្នែកខាងលើកំពុងរមៀលធ្លាក់មកសន្សឹមៗឯណោះទេដែលធ្វើឲ្យគេទ័លច្រក។

មធ្យោបាយដែលអ្នកប្រុសធំត្រកូលអ្នកនយោបាយអាចធ្វើបានមានតែមួយគត់គឺស្ទុះក្រោកហើយប្រើដៃស្តាំដ៏ធំមាំរបស់គេរងរាជំនួសស្រីឆ្កួតស្នេហ៍ដែលកំពុងឈរទ្រឹងបាត់ម្ចាស់ការ។

ស៊ុមគំនូរដែលបោកទង្គិចនឹងខ្នងដៃបុរសអភិជនប៉ើងខ្ទាតទៅម្ខាងល្មមពេលគេប្រើដៃឆ្វេងទាញរាងកាយនារីបង្ហាញម៉ូតឲ្យបន្តដំណើរចុះទៅខាងក្រោមទាំងត្រដាបត្រដួសព្រោះថានាងកាន់តែភន្ត័ភាំងពេលឃើញសកម្មភាពតទល់នឹងគ្រោះថ្នាក់របស់រាមនរិន្ទ។

មកដល់ជាន់ខាងក្រោមនរិន្ទរាក់អើនឹងនាយរឿនដែលកំពុងឈររង់ចាំដោយស្លឹតស្លក់ក្នុងចំណោមហ្វូងមនុស្សកកកុញក្រៅរបងសមត្ថកិច្ចចាយ៉ាពូរ៉ា។

សណ្ឋាគារក្នុងរចនាបថបែបបុរាណWinter Jayapuraកំពុងរកកលប្រែទ្រង់ទ្រាយបន្តិចម្តងៗក្រោមឥទ្ធិពលនៃបន្ទុះ២ដងផ្ទួនគ្នាដែលធ្វើឲ្យពាក្យចចាមអារ៉ាមស្តីពីការគំរាមកំហែងផ្នែកសន្តិសុខរបស់ក្រុងនេះក្លាយទៅជាការពិតក្នុងគំនិតអភិជនខ្មែររាមនរិន្ទ។

គេបន្សាត់ខ្លួនមកដល់កៀកនឹងអង្គរក្សរឿនកាលណា ក៏រុញនារីបង្ហាញម៉ូតទៅឲ្យនាយនោះ រួចបញ្ជា៖

-នាំកេតឌីម៉ាចេញទៅឡានមុន! ខ្ញុំចូលទៅតាមលោករ៉ាទូ!

អង្គរក្សជំនិតដែលមិនអាចចូលមកបានដោយមានប៉ូលិសឥណ្ឌូណេស៊ីម្នាក់កំពុងរុញទ្រូងជាប់នោះហាក់កញ្ជ្រោលជាមួយនឹងការមានះរបស់ចៅហ្វាយដែលនៅតែមិនបោះបង់ចោលគំនិតចង់បានឥន្ទបដិម៉ា នរាធិបតិន្ទ។

-អ្នកប្រុស! គ្រោះថ្នាក់ណាស់!

រាមនរិន្ទគ្រវីក្បាលតិចៗ។ គេមិនបាននិយាយតែគេកំពុងហុចកដៃកេតឌីម៉ាទៅឲ្យអង្គរក្សមុនពេលបែរខ្លួនចេញត្រឡប់ក្រោយ។ ដឹងចិត្តនាយចៅហ្វាយថាខ្លួនគ្មានលទ្ធភាពក្នុងការឃាត់នាយបានអង្គរក្សជំនិតបែរមករកធីតាដែលនៅបង្អើយភ្លាមៈ

-កេតឌីម៉ា! ឃាត់អ្នកប្រុសភ្លាម! គាត់របួសហើយ! នារីរូបល្អឱនសម្លឹងដៃគេដែលប្រែទៅជាហើមខៀវពីកដៃដល់កំភួនដៃបន្ថែមពីលើរបួសប្រអប់ដៃកាលពីល្ងាច។ របួសថ្មីដែលមានជាប់ជាមួយនូវកម្ទេចកំទីឈើ និងឈាមក្រហមហូរមករឹមៗប្រហែលជាកំពុងធ្វើទុក្ខបានជាគេហាក់គ្មានកម្លាំងលើកដៃម្ខាងហ្នឹងសោះ។ នាងងើបមើលមុខគេសន្សឹមៗ ប៉ុន្តែគេនៅតែមិនឃើញមានសញ្ញាបាត់បង់ភាពស្វាហាប់ និងម៉ត់ចត់ទេ។

គេបែរខ្លួនចេញទៅដោយលែងដៃពីនាងទាំងស្រុង។ ក្នុងមួយវិនាទីនោះនាងមិនដឹងត្រូវធ្វើយ៉ាងណាមានតែស្រវាចាប់ដៃគេជាប់សាជាថ្មី។

-លោកប្រុសរាម! លោកកុំទៅ!

តែនាងគួរតែយល់ហើយថាគ្មានអ្នកណាអាចឃាត់រាមនរិន្ទឲ្យលះបង់វត្ថុបំណងគ្រប់គ្រងវត្ថុបុរាណដ៏អាថ៌កំបាំងនោះបានឡើយ។ គេដៀងភ្នែកសម្លឹងនាង ដែលជានិច្ចកាលពន្លឺភ្នែកអង្វរកររបស់នាងតែងតែមានប្រៀបលើបេះដូងនាយ ប៉ុន្តែដូច្នេះហើយ នាយត្រូវតែងាកមុខចេញវិញជាបន្ទាន់មុនពេលទន់ចិត្ត។ បុរសមានការងារធំជាប់ប្រាណបេះដៃនាងទម្លាក់ចេញរួចឈានជើងចេញទៅ។

-ចាំខ្ញុំក្នុងឡានកេតឌីម៉ា! ខ្ញុំមកវិញឥឡូវហើយ! នាំនាងទៅរឿន!

នាយរឿនស្រវាចាប់ដៃកេតឌីម៉ាជាប់ដោយភ្នែកតាមសម្លឹងដំណើរបុរសជានាយចៅហ្វាយដែលប្រើដៃឆ្វេងលើកទ្រដៃស្តាំឡើងៗឆ្ពោះទៅក្នុងសណ្ឋាគារបញ្ច្រាស់គ្នាជាមួយមនុស្សម្នាដែលរត់ចេញមកប្រសាច។

ឌីម៉ាណាធ្ងន់ក្បាលបញ្ហាសុខភាព ណាមួយតក់ស្លុតនឹងហេតុការណ៍អកុសលមិនធ្លាប់ជួបនាងធ្មេចភ្នែកមួយខណៈដើម្បីប្រមូលកម្លាំងចិត្ត កម្លាំងកាយឡើងវិញក្នុងពេលដែលទទួលអារម្មណ៍ថារាងកាយកំពុងត្រូវបានទាញចេញក្រៅបរិវេណហ៊ុមព័ទ្ធនោះដោយដៃអង្គរក្សជំនិត។

គេអូសនាងទៅកាន់រថយន្ត ប៉ុន្តែមុនពេលចេញទៅដល់គោលដៅ គេទុចបន្តិចធ្វើឲ្យនាងត្រូវបើកភ្នែកមកវិញ។ ទិដ្ឋភាពដំបូងដែលនាងប្រទះឃើញ គឺនៅចំពោះមុខប្រមាណជា១០ម៉ែត្រនាងឃើញនាយKenកំពុងឈរសម្លឹងភ្លឹកភ្លាំងទៅក្នុងរបាំងការពាររបស់ប៉ូលិស។ ចុះហេតុអ្វីបានជានាយរឿនឃើញគេហើយក៏បញ្ឈប់ចលនា?

នារីសម្លឹងតាមខ្សែភ្នែកអភិជនដែកថៃប។ នាងទើបតែដឹងថាបុរសដែលមានចិត្តមិនស្មោះ កំពុងតាមសម្លឹងរាមនរិន្ទភ្លឹកភ្លាំងព្រោះគេប្រហែលគិតមិនដល់ទេថា រាមនរិន្ទបកក្រោយត្រឡប់ឡើងទៅលើវិញ។

ប្រហែលជាទើបតែចាប់អារម្មណ៍ថានាង និងអង្គរក្សរឿនបានឃើញគេហើយ បានជាគេដកភ្នែកពីរាមនរិន្ទហើយងាក មកសម្លឹងនាក់ទាំងពីរវិញម្តង។

កេតឌីម៉ាសម្លឹងនាយKenភ្នែរស្ទើរស្រក់ទឹកភ្នែក។ នាងដឹងហើយ ក្នុងចិត្តពួកគេ គឺមានតែវត្ថុបុរាណនោះ ហើយនាងក៏ដឹងត្រឹមពេលនេះថា នាងត្រូវគេបោកប្រាស់។

ក្នុងចិត្តពួកគេ គឺនាងគ្មានតម្លៃអ្វីក្រៅពីជាមនុស្សស្រីសម្រាប់ប្រើប្រាស់ និងសម្រាប់កម្សាន្តសប្បាយនោះទេ។

នាងឈ្ងោកមកវិញ ព្រមពេលសន្ទឹកជើងអង្គរក្សរាមនរិន្ទនាំគ្នារត់មកដល់។

-បងរឿន!? អ្នកប្រុសនៅក្នុងម្នាក់ឯង?

អង្គរក្សរឿននិយាយតបយ៉ាងរហ័ស៖

-នាំនាងទៅចាំក្នុងឡាន! ខ្ញុំចូលទៅតាមអ្នកប្រុស!

អង្គរក្សរឿនចាកចេញទៅ។ ឌីម៉ាត្រូវបានគេនាំមកកាន់រថយន្តដែលបញ្ឆេះចាំជាស្រេច។ នាងចូលអង្គុយហើយទើបតែប្រទះឃើញថាសំពត់វែងរបស់ខ្លួនត្រូវដាច់ដោចអស់គ្មានសល់ទេ។ ប្រសិនបើរាមនរិន្ទមិនអាចរកកាំបិតនោះបានក្នុងថេរវេលាដ៏ខ្លីនាងប្រាកដជាត្រូវកៀបជាប់ក្រោមជញ្ជាំង

នោះ។ នាងស្រក់ទឹកភ្នែកច្រោកព្រោះស្រមោលអពមង្គល និងរូបភាពទឹកមុខគ្មានឈាមរបស់បុរសឈ្មោះ Kenបានអណ្ដែតមកវិញសាជាថ្មី...

"ឪម៉ា? ស្រីឆ្កួត! មនុស្សប្រុសអ្នកមានដូចគេនោះហ្អេះដែលមកស្រលាញ់ឯង?"

នាងលើកដៃជូតជលនេត្រហើយបិទភ្នែក បណ្ដោយខ្លួនឲ្យទោរទន់ទៅតាមភាពអស់សង្ឃឹម។ ពេលវេលាប្រហែលជាវំលងទៅយឺតណាស់ប្រៀបទៅនឹងទំហំចិត្តរង់ចាំរបស់ក្រុមកងការពារ រហូតដល់ស្នូរបិទទ្វារឡានបានទាញនាងឲ្យភ្ញាក់មកវិញ។ នាងញីភ្នែកសម្លឹងជុំវិញខ្លួន។ បរិយាកាសកំពុងរត់ថយក្រោយ ហើយរថយន្តរបស់រាមនរិន្ទនៅពីមុខនាងបានចាកចេញទៅមុន នាងដឹងថារឿនបាននាំថៅហ្វាយប្រុសគេត្រឡប់មកវិញដោយសុវត្ថិភាពហើយ។

**វគ្គទី១៣**

**ទៅមុខ ឬបកក្រោយ**?

....ពេលវេលាដ៏រន្ធត់នៅ Winter JayaPuraបានកន្លងទៅប៉ុន្មានម៉ោងហើយ...

តាំងពីយប់ម្សិលមិញដែលរាមនរិន្ទត្រូវខូចចិត្តរឿងជនបង្កប់រាយការណ៍ដំណើរខ្លួនទៅសិទ្ធិគុណទោះបីជាមិនទាន់ជឿរឿងនេះ១០០% ប៉ុន្តែអង្គរក្សរឿនបានប្រើវិធីបង្ការទប់ជាមុនមួយគឺចាប់ផ្ដើមដកហូតមធ្យោបាយទំនាក់ទំនងទាំងអស់ពីមនុស្សក្នុងក្រុមខ្លួនរួមទាំងកុំព្យូទ័រ និងទូរសព្ទដៃផង ធ្វើឲ្យនាយBirdលែងមានមធ្យោបាយក្នុងការទាក់ទងទៅថៅហ្វាយពិតរបស់ខ្លួន។ ម្ល៉ោះហើយនៅពេលដែលរាមនរិន្ទបណ្ដើរកេតឪម៉ាទៅកាន់ពិធីដេញថ្លៃបានធ្វើឲ្យនាយKenកាន់តែឆ្ងល់ចុងច្រមុះ។

នៅពេលរាមនរិន្ទនាំធីតាបង្ហាញម៉ូតមកដល់ទីសុវត្ថិភាពហើយខ្លួនគេផ្ទាល់បានបកទៅរកបុរសម្ចាស់កោះស្មៅលឿងវិញនាយKenដឹងថាឥន្ទបដិមា គឺជាហេតុផលសំខាន់នៃការប្រថុយនោះដូច្នេះរហូតដល់រាមនរិន្ទចេញពីជួបបុរសម្ចាស់ឥន្ទបដិមាឈ្មោះវ៉ាទូនោះវិញហើយក្ដីក៏គេមិនអាចទទួលដំណឹងមានអ្វីកើតឡើងនៅខាងណោះដែរធ្វើឲ្យគេកាន់តែប្រាស់ប្រាលចាត់មនុស្សមកតាមឃ្លាំមើលជុំវិញផ្ទះឈើស្មេកស្កុះ។

តែអ្នកដែលពិតជាអន្ទះសាជាងនាយKenទៀតនោះគឺកូនចៅជំនិតរបស់គេ "នាយBird"។

-អ្នកប្រុសរាមសម្រេចចិត្តចេញទៅតាមតាកន្ទាត់នោះដល់កោះស្មៅលឿងអ្វីបងរឿន? (នាយBird សួរបញ្ជាក់ទៅកាន់មេអង្គរក្សដោយបើកភ្នែកគ្រលួង)

នាយរឿននៅស្ងៀមគិតពីចុចប៊ូតុងSearch លើកុំព្យូទ័របណ្ដោយឲ្យបុរសបង្កប់ខ្លួនសួរបន្តនូវសំនួរទី២៖

-បងឯងចង់និយាយថាពេលអ្នកប្រុសត្រឡប់ទៅក្នុងវិញជួបតាកន្ធាត់វ៉ាទូនោះសុំទិញវត្ថុបុរាណនោះពីគាត់ គាត់ដូរចិត្តលែងលក់វិញមែនទេ?

នាយរឿននៅតែមិនឆ្លើយបណ្ដោយឲ្យនាយBirdនិយាយបន្ត៖

- របស់ក៏នៅមិនទាន់បានឃើញផង! ពិតមិនពិតមានពីណាដឹង! អ្នកប្រុសមិនចាំបាច់ផ្សងគ្រោះថ្នាក់ទៅដល់កន្លែងដាច់សង្វែងហ្នឹងទេ!

នាយរឿនបញ្ចប់ការងារដោយលើកដៃចុចបិទឧបករណ៍កុំព្យូទ័រដោយនិយាយតប៖

- ទៅរកកាណូតលឿននោះមក! កុំនៅចេចចាចច្រើន!

នាយBirdដឹងខ្លួនមកវិញថាអាកប្បកិរិយាអន្ទះសាររបស់ខ្លួនអាចនាំឲ្យនាយប្រមុខអង្គរក្សមានការសង្ស័យម្ល៉ោះហើយក៏រៀបសម្រួលទឹកមុខដកថយតាមយុទ្ធសាស្ត្រ។

វេនរសៀលចូលមកកំដរក្រុងចាយ៉ាពូរ៉ា។ អ្នកប្រុសនៃត្រកូលអ្នកនយោបាយកំពុងអង្គុយស្ដាប់សេចក្ដីបរិយាយរបស់មនុស្សក្រោមបង្គាប់ដែលគ្មានអ្នកទី៣ត្រូវបានអនុញ្ញាតអោយចូលមកក្បែរ។ ដូចរាល់ដងគឺគេជាអ្នកលាបថ្នាំ និងរុំរបួសឲ្យចៅហ្វាយដែលគេគោរព និងភក្ដី។ របួសធំដល់ថ្នាក់នេះ អភិជននានាត្រូវតែជួបពេទ្យជាចាំបាច់ ប៉ុន្តែរាមនរិន្ទ គឺគ្មានពេលវេលាសម្រាប់រឿងនេះទេ ក្នុងបេះដូងគេក៏មានតែរឿងឥន្ទបដិមា។ គេរវើរវាយភ្នែកសញ្ជឹងគិតនៅពេលដែលសម្ដីនាយជំនិតនៅតែលាន់មកជាបន្តបន្ទាប់៖

- ពីនេះទៅកោះស្មៅលឿងយ៉ាងហោចណាស់ប្រើពេល ២ទៅ៣ថ្ងៃដែរ! មធ្យោបាយមានតែមួយគត់ គឺតាមផ្លូវទឹក! អាBirdរកបានកប៉ាល់កម្សាន្តលក្ខណៈផ្ទាល់ខ្លួនដែលថ្លៃជិត៥០០០៣ន់ដុល្លារសម្រាប់រយៈពេលមួយខែ!

រាមនរិន្ទដឹងហើយថាមនុស្សក្រោមបង្គាប់មិនពេញចិត្ត និងអត្រាចំណាយដ៏ខ្ពស់ទាំងឡាយនៅក្នុងទីក្រុងដ៏គ្មានសុវត្ថិភាពនេះ ប៉ុន្តែគេនៅតែសើចលួងចិត្តនាយ៖

- យើងមិនមែនខ្វះខ្វាយទេរឿន តែលើកនេះយើងនៅតែត្រូវចំណាយ! ឲ្យគេធ្វើការទៅ! ព្រឹកស្អែកចេញដំណើរភ្លាម!

នាយរឿនដកដង្ហើមយូរប្រឹងបំបាត់ភាពតឹងចិត្ត។ គេសម្លឹងថៅហ្វាយដែលក្រោកឈរព្យាយាមពត់ដៃចុះឡើងទោះបីទើបតែរុំរបួសហើយថ្មីៗក៏ដោយ។ គេដឹងថា គេគ្មានវិធីឃាត់នាយទេទោះបីចិត្តចង់ពន្យាររង់ចាំនាយជារបួសសិនក៏ដោយ។

**ភាគទី២៧**

សំឡេងនាយថៅហ្វាយលាន់ឮមកកាត់ផ្ដាច់អារម្មណ៍ត្រិះរិះរបស់បុរសជំនិត៖

-ខ្ញុំចង់ធ្វើដំណើរឲ្យបានមុនគេ! ព្រោះប្រហែលជាមានអ្នកចង់ទៅកោះនោះច្រើនដែរ!

នាយអង្គរក្សយល់ហើយថារាមនរិន្ទកំពុងចង់សំដៅពីសត្រូវបេះដូង គឺនាយសិទ្ធិគុណដែលផ្ទុយស្រឡះ និងការយល់ឃើញរបស់ខ្លួន។ គេនិយាយតបមួយៗដោយក្រោកទៅឈរពីក្រោយថៅហ្វាយ៖

-អ្នកប្រុស! អ្នកដែលត្រូវគិត គឺថៅកែKenមិនមែនសិទ្ធិគុណទេ!

រាមនរិន្ទងក់ក្បាលផ្ងក់ៗ ព្រោះចាប់តាំងពីពេលដែលគេចាប់អារម្មណ៍ឃើញថាសិទ្ធិគុណមិនបានបង្ហាញខ្លួននៅឯការដេញថ្លៃ គេបានដឹងជាស្រេចហើយថា ថៅកែក្មេងដែលល្មោភស្រីស្រស់នោះមិនបានមកកាន់Jayapuraព្រោះតែតន្ទបដិមាឡើយ។ ផ្ទុយទៅវិញការបង្ហាញខ្លួនដ៏គួរឲ្យភ្ញាក់ផ្អើលរបស់ពាណិជ្ជករលោហធាតុ Cam-Steelទេ ដែលជាចំណុចស្នូលនៃរឿងទាំងអស់។

-កេតឌីម៉ាក៏មិនមែនជាអ្នកធ្វើឲ្យបែកការណ៍ពីដំណើររបស់អ្នកប្រុសមកJayapuraដែរ!

រាមនរិន្ទសម្លឹងទៅរូបថតប៉ុន្មានសន្លឹកដែលត្រូវបានហុចមកឲ្យខ្លួន។ គេលូកដៃទទួលហើយយកមកពិនិត្យម្ដងមួយសន្លឹក ម្ដងមួយសន្លឹក។ គេវេញ្ញកសញ្ជឹងគិតហើយសើចចុងមាត់ដោយយល់ការណ៍។ឯនាយជំនិតនិយាយបន្ត៖

-អាគង់បានតាមដានលំអង! ពេលចេញពីកន្លែងយើង ស្រីនោះបានចេញទៅ Cita Resort ! គឺទៅជួបថៅកែKen!

មិនបាច់និយាយក៏រាមនរិន្ទបានយល់ពីអ្វីដែលនាយរឿនកំពុងចង់និយាយដែរព្រោះសន្លឹករូបថតដែលគេកំពុងកាន់បានបង្ហាញពីទំនាក់ទំនងស៊ីជម្រៅរវាងនារីនោះ និងពាណិជ្ជករKen ជាស្រេចទៅហើយ។ គេក៏ដឹងច្បាស់ពេលនេះដែរថា ការសង្ស័យដែលថាថៅកែ Kenដ៏ស្អាតសង្ហាបានប្រើកលឧបាយកេងចំណេញលើការងាររបស់ខ្លួនពីទីងងឹតនោះបានក្លាយជាការពិត១០០%។

-យើងគិតថាលាក់បានជិត! តែតាមពិតមានគេឆ្លាតជាងយើងមែន!

នាយរឿនមិនលាក់លៀមទៀតទេ គេនិយាយតាមសន្ទុះចិត្តខឹង៖

-គេមិនមែនឆ្លាតទេ តែគេខូច! គេប្រើប្រាស់ចិត្តសន្តោស និងភាពមេត្តារបស់អ្នកប្រុស! គេប្រើល្បិចពិសេស គេប្រើស្រីៗឲ្យជួយធ្វើការ!

រាមនរិន្ទបែរជាយល់ត្រង់ថានេះគឺនាយរឿនចង់បន្ទោសខ្លួនដែលចិត្តទន់ និងមានស្នេហាកណ្ដាលបេសកកម្ម។ នាយបែរខ្នងសម្លឹងបុរសជំនិតហើយញញឹមទៅរកគេ៖

-រឿន! ខ្ញុំសូមទោសរឿងកេតឌីម៉ា! ខ្ញុំមានៈ អត់ស្ដាប់អ្នកណានិយាយទាំងអស់ បានជាយើងជួបបញ្ហាដល់ថ្នាក់នេះ!

អង្គរក្សជំនិតបែរជាពន្យល់វិញភ្លាម៖

-តែកេតឌីម៉ាដូចជាអត់មានទាក់ទងជាមួយរឿងល្បិចកលនេះទេអ្នកប្រុស!

រាមនរិន្ទសម្លឹងមុខគេដោយក្រសែភ្នែកស្រទន់។ ចង់មិនចង់អ្នកណាក៏ដោយដែលរំលឹកពីនាងទោះល្អក្ដីអាក្រក់ក្ដី អ្នកប្រុសកាន់តែមានអារម្មណ៍ថានឹកនាងណាស់។ ជាពិសេសនៅពេលដែលប្រុសម្នាក់ត្រូវរបួស និងបរាជ័យការងារ គេក៏កាន់តែចង់ឃើញនារីដែលគេស្រលាញ់មកបង្ហាញខ្លួននៅចំពោះមុខគេ លួងលោម និងថ្នាក់ថ្នមគេដោយសភាវៈទន់ភ្លន់ដែលគេត្រូវការធាតុទាំងនេះជាចាំបាច់ក្នុងការបបោសអង្អែលជីវិតក្នុងភាពជាបុរសរបស់ខ្លួន។

ឃើញគេនៅស្ងៀមរឿននិយាយបន្ថែម៖

-កេតឌីម៉ាល្ងង់យ៉ាងនេះនាងប្រហែលជាត្រូវគេប្រើប្រាស់! រហូតដល់ពេលនេះនាងដូចជាអត់បានដឹងផងថាលំអងទៅណា នៅជាមួយអ្នកណានៅJayapuraនេះ! ដំបូងខ្ញុំគិតថានាងជាមនុស្សរបស់សិទ្ធិគុណ ព្រោះក្រោយពេលយើងមកដល់ភ្លាមក៏ឃើញម្នាក់នោះបង្ហាញខ្លួន ប៉ុន្តែក្រោយមកពេលលំអងប្រាប់អ្នកប្រុសពីទំនាក់ទំនងពួកគេខ្ញុំចាប់ផ្ដើមឆ្ងល់ថាបើកេតឌីម៉ាល្អជាមួយនាងម្លឹងៗហេតុអ្វីនាងចាំបាច់មកសារភាពប្រាប់អ្នកប្រុស។ យប់មិញនៅឧទ្យានព្រីម៉ា ខ្ញុំឃើញកេតឌីម៉ានៅអង្គុយយំម្នាក់ឯង! តាមពិតនាងអត់មានកន្លែងត្រូវទៅទេ! មានន័យថានៅ? ទីនេះនាងអត់ស្គាល់អ្នកណាទាំងអស់! ខ្ញុំហៅនាងត្រឡប់មកវិញ ប៉ុន្តែនាងបដិសេធ! នាងនិយាយពាក្យច្រើនណាស់ដែលមានន័យថានាងបារម្ភពីសុវត្ថិភាពលំអង ហើយនាងគិតថា លំអងប្រហែលជានៅក្នុងដៃយើងទៅវិញ!

បញ្ជីអ្នកចុះឈ្មោះចូលរួមដេញថ្លៃតន្ទបដិមាដែលមនុស្សរបស់យើងនៅទីនេះរកបានមកឲ្យ អត់ឃើញមានឈ្មោះកូនពៅឧកញ៉ាឆាយណាគុណទេសូម្បីតែថៅកែKenក៏អត់ឃើញដែរ! តែក្រោយមកបានខ្ញុំដឹងថា គេប្រើឈ្មោះឈ្មោះផ្សេងដោយសារគេមានកាន់លិខិតឆ្លងដែនAustraliaព្រោះគេមានសញ្ជាតិអូស្ត្រាលី។ បានន័យថា ថៅកែKenមានគម្រោងម៉ត់ចត់ណាស់ក្នុងការបង្ហាញខ្លួនមិនឲ្យអ្នកណាស្មានដល់ក្នុងការដេញថ្លៃ។ រឿងដែលខ្ញុំនៅស្រពិចស្រពិល គឺហេតុអ្វីបានជាកេតឌីម៉ាសុខចិត្តជួយលំអង តើនាងដឹងពីរឿងថៅកែKenដែរអត់? បើដឹងហេតុអីនាងនៅតែធ្វើអញ្ចឹងទៀត? ហើយហេតុអ្វីពេលគេដឹងថាបានមកដល់គោលដៅហើយ បែរជានិយាយប្រាប់អ្នកប្រុសថានាងជាសង្សាររបស់សិទ្ធិគុណ! ឬមួយនាងអស់តម្លៃប្រើបាន គេចង់ខ្ចីដៃអ្នកប្រុសបំបិទមាត់នាង?

រាមនរិន្ទនៅស្ងៀមប៉ុន្តែគេកំពុងសញ្ជឹងគិត។ ចង់មិនចង់ការរកឃើញរបស់នាយរឿនដែលទោះមិនអាចបញ្ជាក់រឿងទាំងអស់ឲ្យច្បាស់ដូចថ្ងៃបាន ប៉ុន្តែក៏ល្មមអាចបញ្ជាក់រឿងមួយបានថា កេតឌីម៉ានិងសិទ្ធិគុណគ្មានទំនាក់ទំនងនិងគ្នា ដូចពាក្យលំអងទេ ឯលំអងប្រឌិតរឿងនេះមក ក៏ដើម្បីអ្វីវិញ?

ចំណែកនាយKenបុរសខ្មែរដែលមានកំណើតមកពីប្រទេសអូស្ត្រាលីហាក់មិនធ្លាប់មានគំនុំអ្វីជាមួយខ្លួនទេពីមុនមក ប៉ុន្តែតន្ទ បដិមាអាចជាមូលហេតុមួយសំខាន់ក្នុងការធ្វើឲ្យគេសុខចិត្តចំណាយពេលវេលាធ្វើរឿងច្រើនយ៉ាងនេះប្រឆាំងនឹងខ្លួន។ អាចទេដែលថាកេតឌីម៉ាមិនស្គាល់គេតែគេស្គាល់នាងច្បាស់ព្រោះថានាងជាកូនអុកមួយនៅក្នុងគម្រោងការណ៍នោះ? អញ្ចឹងហើយបានជានៅឯពិធីដេញថ្លៃគេនិយាយស្វាគមន៍នាងដោយក្រសែភ្នែកចម្លែក។

ក្នុងពេលកំពុងសញ្ជឹងគិតគេឮនាយអង្គរក្សនិយាយបន្ថែម៖

-កេតឌីម៉ានៅជាមួយអ្នកប្រុសនៅឡើយ! មុន និងក្រោយអ្នកប្រុសអាចរកបានចម្លើយពិតពីនាង! រាមនរិន្ទសើចស្ងួត គេឱនសម្លឹងដៃដែលមានរបួសហើយនិយាយតិចៗ៖

-គេមកJayapuraដើម្បីតែមិត្តគេទេរឿន! បើដឹងការពិតហើយ គេព្រមនៅជាមួយយើងទៀតដែរ?

នាយអង្គរក្សនិយាយតបវិញភ្លាម៖

-អញ្ចឹងហើយបានជាឧទ្យានព្រីម៉ា ខ្ញុំបានដាក់លក្ខខណ្ឌជាមួយនាង! បើនាងទៅណាចោលអ្នកប្រុសទៀត លំអង និងមានរឿង!

រាមនរិន្ទហួសចិត្ត។ ដូច្នេះហើយបានជាព្រឹកឡើងនាងស្រាប់តែបង្ហាញខ្លួននៅឯតុអាហារ ជាមួយកាយវិការផ្គាប់បម្រើដ៏ចម្លែក ពិសេសទោះនាងត្រូវទទួលទៅវិញនូវកាយវិការសោះកក្រោះក៏នាង

នៅតែសុខចិត្តចេញទៅតាមនាយនៅឯពិធីដេញថ្លៃតុក្រុក។ នាយចៅហ្វាយស្រស់សង្ហាយល់ហើយថាហេតុតែបំពេញចិត្តស្នេហារបស់ខ្លួនទើបរឿនជ្រើសយកវិធីនេះ ប៉ុន្តែគេក៏មិនចង់បានឲ្យនារីនោះមកនៅជាមួយខ្លួនដោយរបៀបបង្ខំដូច្នេះដែរ។ គេនិយាយមួយៗ៖

-ធ្វើរឿងអញ្ចឹងធ្វើអីរឿន? នាំគេកាន់តែស្អប់យើងថែមតែប៉ុណ្ណឹង! ហើយយើងក៏មិនទៅធ្វើរឿងបង្ខាំងមនុស្សរឿងអីអស់ហ្នឹងដែរ! បើចិត្តគេអត់នៅនឹងយើងទៅហើយ ខ្ញុំលែងត្រូវការហើយ!

គេមិននិយាយបន្តបន្ថែមទេថាមានប្រុសអាថ៌កំបាំងម្នាក់ដែលបាននិយាយទូរសព្ទជាមួយនាងកាលពីម្សិលរហូតដល់គេឮហើយក៏ទ្រាំមិនបាននោះ ប៉ុន្តែគេនៅតែច្បាស់ក្នុងចិត្តថា មនុស្សក្នុងបេះដូងនាងមិនមែនគេឡើយ។

គេបែរខ្លួនហៀបនឹងបោះជំហានចេញទៅប៉ុន្តែត្រូវអង្គរក្សពោលឃាត់៖

-អ្នកប្រុស!

រាមនរិន្ទងាកក្រោយសម្លឹងមុខមនុស្សជំនិត។ អ្នកឃើញគេលេបសម្ដីមកវិញហាក់ទាក់ទើរក្នុងការបន្តឃ្លាសន្ទនាប៉ុន្តែក្រសែភ្នែកពោរពេញដោយភាពស្មោះត្រង់របស់គេហាក់ធ្វើឲ្យអ្នកកក់ក្ដៅក្នុងការពោលលើកទឹកចិត្ត៖

-និយាយទៅ!

នាយរឿនដើរមកជិតចៅហ្វាយជាមួយប្រយោគតិចៗល្មមតែឮបានពីរនាក់៖

-មនុស្សស្រីណាក៏មានអតីតកាលដែរ! អ្នកប្រុសទុកពេលឲ្យគេបន្តិចទៅ! ហើយទុកឱកាសមួយឲ្យខ្លួនឯងផង! បើពេលនេះមិនបង្ខំឲ្យគេនៅជិតយើង ពេលណាគេអាចយល់ចិត្តអ្នកប្រុសទៅ?

នាយរឿនដឹងថារាមនរិន្ទដែលកើតមកក្នុងឆាកជីវិតក្រាលដោយជើងពាន និងព្រំក្រហមគេមិនដែលស្គាល់ពាក្យថាចង់បានអ្វីហើយមិនបានដូចចិត្តនោះទេ។ សូម្បីស្រលាញ់ស្រីម្នាក់ គេនៅតែចង់ឲ្យស្រីនោះស្រលាញ់ខ្លួនវិញដោយមិនចាំបាច់ធ្វើអ្វីសោះ។ ហើយបើមើលទៅគឺនាងគ្មានសន្ដានចិត្តតបក៏គេគិតថានឹងលះបង់ចោលតែម្ដងដោយមិនចង់ចំណាយពេលព្យាយាមអ្វីទាំងអស់។ ប៉ុន្តែស្នេហាគឺផ្ទុយពីសម្ភារៈបើមិនព្យាយាមខ្លះធ្វើម៉េចអាចទទួលលទ្ធផលចុងក្រោយបាន?

ចំណែករាមនរិទ្ធមិនមែនមិនដឹងទេថា ការរស់នៅរសាត់អណ្តែតរបស់អង្គរក្សរឿនក្នុងស្ដមខាងក្រៅធ្វើឲ្យគេមានបទពិសោធន៍ជីវិតក្រាស់ក្រែលជាងខ្លួនពិសេសក្នុងរឿងស្រីៗដូច្នេះហើយបានជាជានិច្ចជាកាលគេគឺជាទីប្រឹក្សាដ៏ល្អ និងគួរឲ្យទុកចិត្តជាងគេ។

ប៉ុន្តែអ្នកនៅតែមិនទទួលយកគំនិតរបស់គេក្នុងការរក្សាកេតឌីម៉ា។

-កន្លែងដែលយើងត្រូវទៅនៅវែងឆ្ងាយ! មានរឿងអីខ្លះក៏មិនដឹង! បើមាននិស្ស័យចប់ការងារចាំជួបគ្នាក៏បាន! រៀបចំជូនគេទៅភ្នំពេញវិញទៅ ប្រាប់គេពីរឿងមិត្តស្រីដ៏ល្អរបស់គេផង កុំឲ្យគេចាញ់បោកអ្នកណាទៀត!

សម្ដីរបស់នរិទ្ធទោះយ៉ាងណានៅតែជាបទបញ្ជា។ រឿនចង់ប្រាប់គេណាស់ថាបេសកកម្មដែលមានដំណើរវែងឆ្ងាយមានស្រីម្នាក់តាមថ្នាក់ថ្នមលួងលោមចិត្តមានអីមិនល្អទៅ ប៉ុន្តែគេមិនហ៊ាននិយាយអ្វីបន្ថែមទេព្រោះចៅហ្វាយបានចាកចេញទៅជាសញ្ញាថានាយលែងចង់ឲ្យមានការជជែកទាក់ទងពីប្រធានបទនេះទៀតហើយ។

មិនមែនបេះដូងរបស់រាមនរិទ្ធអាចបំភ្លេចកេតឌីម៉ាបានងាយស្រួលដូចដែលនាយរឿនបានគិតនោះទេ។ ទោះបីធ្លាប់ឆ្លងកាត់នារីជាច្រើន ប៉ុន្តែកេតឌីម៉ាជាស្នេហាដំបូងរបស់អ្នក ទោះអង្គរក្សជំនិតឆ្លាតនិងពូកែយល់ចិត្តគេយ៉ាងណា ក៏មិនអាចស្មានយល់ដល់ទំហំចិត្តដែលបុរសអភិជនមានចំពោះនារីល្វតល្វន់ម្នាក់នោះដែរ។ គេតាមពិតដឹងខ្លួនច្បាស់ណាស់ថាចង់បំភ្លេចនាង គឺពិតជាពិបាកហើយព្រោះមួយដង្ហើមណាក៏ចាប់ផ្ដើមនឹកដល់នាងជានិច្ចចាប់តាំងពីពេលមកជាន់ដីក្រុងចាយ៉ាពូរ៉ាពេលណា។ ប្រការសំខាន់គឺកាន់តែស្រលាញ់កាន់តែត្រូវនៅឲ្យឆ្ងាយប្រសិនបើនៅជិតហើយ គេមិនមានចិត្តឲ្យខ្លួនដដែលវានាំតែឈឺចាប់លើសដើមតែប៉ុណ្ណោះ។

អ្នកប្រុសនៃត្រកូលអ្នកនយោបាយបោះជំហានចាកចេញទៅទាំងធ្ងន់កណ្ដុកក្នុងទ្រូង។ យ៉ាងហោចណាស់ក៏សប្បាយចិត្តក្នុងការស្គាល់ស្រីម្នាក់ដែលនាងបានជួយឲ្យអ្នកយល់ពីអ្វីទៅជាសេចក្ដីស្នេហារបស់មនុស្សលោក ប៉ុន្តែអ្នកក៏ត្រូវទទួលមកវិញនូវរសឈឺចាប់ទន្ទឹមគ្នាជាសំណងពីសេចក្ដីស្នេហានេះ។

"សម្រាប់ឯងស្នេហាពិតជាការឈឺចាប់មែនទេរាមនរិទ្ធ?"អ្នកសួរខ្លួនឯងនៅពេលឡើងមកដល់បន្ទប់គេង។ គេលើកកែវទឹកក្រេបក៏នឹកឃើញដល់កែវទឹកមានថ្នាំសណ្ដំដែលនារីបង្ហាញម៉ូតរៀបចំទទួលអ្នកនៅសណ្ឋាគារអាម៉ាន់ដារី។ លូកដៃរៀបចំវ៉ាលិសខោអាវអ្នកក៏នឹកឃើញទៅដល់គ្រា

ដែលនាងគេចចេញពីរង្វង់ដៃអ្នករហូតដល់ដួលថ្លោះកជើង។ ក្រឡេកទៅកម្រាលពូក អ្នកស្រមៃឃើញតែទឹកភ្នែកនាងដែលស្រក់មកគ្រប់គ្រានៅក្រោមលង្វែកទ្រូងអ្នក។

"ទីបំផុត ឯងរកឃើញចម្លើយហើយ! គេមិនដែលមានឯងក្នុងបេះដូងទេ! ឈប់ឆ្កួតតែម្នាក់ឯងទៅ!"

បុរសអភិជនឈានទៅរានហាលខាងក្រៅសម្លឹងហួសទៅរកស្រមោលពណ៌ខៀវនៃបឹងសេនតានីដែលនៅឆ្ងាយស្រអាប់ក្រោមស្រទាប់ព្រិលត្រជាក់នាពេលអស្តង្គត។

បរិយាកាសកាន់តែត្រជាក់សម្រាប់បុរសរងាបេះដូង ហើយរបួសលើដៃក៏ចាប់ផ្តើមចេញចំហាយក្តៅភាយ និងចុកចាប់។ គេបែរក្រោយត្រឡប់ចូលទៅក្នុងបន្ទប់រួចមកប្រះផ្អែកខ្លួនទៅលើកៅអីវែងនៅចុងដំណេកហើយទ្រេតខ្លួនបោះចោលជំហរមាំទាំជាមួយទឹកមុខក្រៀមស្រពោន។ បុត្រទោលនៃអ្នកតំណាងរាស្ត្រលូកដៃបញ្ឆាទូរទស្សន៍ឲ្យបើកហើយព្យាយាមដាក់អារម្មណ៍ទៅក្នុងចំណីចក្ខុនានា ប៉ុន្តែសំឡេងម្យ៉ាងពីក្នុងបន្ទប់ទឹកធ្វើឲ្យអ្នកប្រុសចងចិញ្ចើមងឿងឆ្ងល់។ គេដៀងភ្នែកទៅរកប្រភពនៃសូរស័ព្ទដែលប្រាកដថាមិនមែនលាន់ឮចេញពីទូរទស្សន៍ដាច់ខាត។

មាត់មិនទាន់ហើបសួរថាយ៉ាងណាផង កែវភ្នែកបែរជានៅទ្រឹងកាលបើឃើញស្រីម្នាក់ដែលបេះដូងកំពុងទាមទារ និងមានរសឈើផៀបផងនោះប្រាកដកាយនៅទីជាប្រភពនៃសូរសំឡេង។ នារីចូលទៅកាន់ទីនោះតាំងពីពេលណាមកក៏មិនដឹង ប៉ុន្តែនាងទើបតែបង្ហាញខ្លួន។ ពេលឃើញវត្តមាននាយកំពុងទ្រេតខ្លួនលើសាឡុងវែងហើយ សម្លឹងមកខ្លួន ធីតាក៏ដើរសំដៅមកដោយបង្ហាញស្នាមញញឹមស្លួតលើផ្ទៃមុខ។

អ្នកប្រុសរូបល្អផ្តោតភ្នែកលើផ្ទៃមុខស្រស់ស្អាតតែក្រៀមស្រពោននៅកៀកនឹងខ្លួនបង្អើយព្រោះថាពេលនេះនាងបានអង្គុយទល់នឹងមុខអ្នកតែម្តង។

ដោយសារនាងបានទទួលបទពិសោធន៍ដ៏ឈឺចាប់នៅទីនេះម្តងហើយកាលពីយប់មិញ ធីតានិយាយដោយញញើតញញើមមកកាន់ប្រុសសង្ហា៖

-លោកប្រុសរាម! ទឹកក្តៅរៀបចំរួចហើយ!

គេសម្លឹងនាងជាប់មិនដាក់ភ្នែក។ ទោះបីធីតាខំគេចចេញពីខ្សែភ្នែកគេ ប៉ុន្តែនាងនៅតែទទួលបានថាពន្លឺភ្នែកបុរសមានឋានៈ ថ្ងៃនេះហាក់ក្រៀមក្រំម្លេះ។

"នាងដល់ថ្នាក់ចូលមកសំងំលាយទឹកក្នុងអាងឲ្យខ្ញុំងូតកេតឌីម៉ា? "គេលួចសួរខ្លួនឯងស្ងាត់ៗក្នុងចិត្ត។ មានតែហេតុផលពីរប៉ុណ្ណោះដែលរាមនរិន្ទរកឃើញគឺថានាងកំពុងចង់សងវិញឲ្យចប់នូវគុណ

ដែលអ្នកទើបតែបានជួយជីវិតនាង និងទីពីរគឺនាងត្រូវនាយរឿនគម្រាមពីសុវត្ថិភាពមិត្ត ចំណែកហេតុផលដែលថានាងចូលមកដោយចិត្តស្រលាញ់ និងឈឺឆ្អាលនោះគឺគ្មានទេ។

នារីឈ្ងោកមុខហើយលូកដៃដោះឡេវអាវឲ្យគេ ដោយសារនាងគិតថាគេមិនអាចធ្វើរឿងនេះបានដោយខ្លួនឯង។ ប្រហើរគន្ធនៃកេសាធីតាផាត់ប៉ះនាសាបុរសដែលកំពុងលង់ស្នេហ៍ធ្វើឲ្យគេមានមោទនភាពដូចកំពុងបានឡើងសួគ៌ា។ គេសម្លឹងម្រាមដៃទន់ល្វន់ដែលកាលពីម្សិលប្រឹងមានះប្រានតវ៉ា និងការរំលោភបំពាន តែទីបំផុតនៅតែមិនអាចជម្នះពីទណ្ឌកម្មនោះបាន។ ហើយក៏ម្រាមដៃដដែលដែលបានទ្រចានអាហារពេលព្រឹកមកផ្តាប់ផ្តុនអ្នកតែត្រូវអ្នកបដិសេធគួរឲ្យអាណោចអាធ័ម។ អ្នកអាណិតនាងព្រួច ដោយភ្លេចអាណិតទាំងចិត្តខ្លួនឯងដែលកំពុងវេទនាដោយសារស្នេហាគ្រាដំបូង។

បុរសរងរបួស និយាយតិចៗក្បែរត្រចៀកស្រីស្រស់៖

-សូមទោសឱម៉ា!

នារីនៅទ្រឹងចលនា។ នាងមិនងើបមុខសម្លឹងគេតែនាងរលីងរលោងទឹកភ្នែក។ ស្រីស្អាតដឹងហើយថាគេកំពុងសំដៅដល់រឿងមួយនោះ ព្រោះនៅជិតគេដល់ថ្នាក់នេះ នាងក៏ពិបាកបំភ្លេចហេតុការណ៍អកុសលនោះដែរ។ ការដែលគេដាច់ចិត្តធ្វើយ៉ាងនោះចំពោះនាង ជារឿងដែលនាងមិនធ្លាប់ស្មានទុកមកទេព្រោះតាំងមុនមកទោះបីថានាងមិនបានស្រលាញ់គេ ប៉ុន្តែនាងហាក់មានអារម្មណ៍ទុកចិត្តថាគេដែលតែងតែញញឹម តែងតែទន់ភ្លន់ នឹងមិនធ្វើបាបនាងឡើយ។ ប៉ុន្តែហេតុការណ៍កាលពីល្ងាចម្សិលបានធ្វើឲ្យនាងវិលវល់។ មនុស្សកំពុងល្អស្រាប់តែប្រែទៅជាអាក្រក់ភ្លាមៗហើយប្រព្រឹត្តនូវអំពើបង្ខំចិត្តដែលគ្មាននារីណាម្នាក់លើលោកនេះចង់បាននោះ។

នាងនៅស្ងៀមតាមទម្លាប់ តែគេមិននៅស្ងៀមទេ។ សំឡេងគេបន្តមកស្រាលៗ៖

-ម៉ោពីប្រចណ្ឌណ៎ា! ដឹងអត់?

នាងក្រមុំដៀងភ្នែកសញ្ជឹងគិត។ ស្អីទៅតែបណ្តាលឲ្យគេនិយាយពាក្យនេះចេញមកកើត? គ្រាន់តែស្រីម្នាក់ដែលគេទំនុកបម្រុង អាចឲ្យគេប្រចណ្ឌដល់ថ្នាក់ហ្នឹង? នាងនៅតែរក្សាភាពស្ងៀមស្ងាត់ធ្វើឲ្យបុរសទៅសៅហ្មងដោយតូចចិត្ត។

គេចង់និយាយប្រាប់នាងថាបើចូលដោយបង្ខំចិត្តនាងមិនបាច់ចូលមកទេ ប៉ុន្តែគេទប់ចិត្តមិននិយាយដោយគ្រាន់តែសម្លឹងនាងរហូតស្ទើរមិនព្រិចភ្នែកព្រោះគេដឹងថាចាប់ពីស្អែកទៅគេមិនបានសម្លឹងនាងជិតសែនជិតដូច្នេះទៀតឡើយ។

ឪម៉ាដោះអាវនរិន្ទចេញស្រាលៗហើយសម្លឹងមុខគេដែលនៅទ្រឹងមិនធ្វើចលនា។ ភ្នែកគេសម្លឹងមកក្នុងភ្នែកនាងរហូតដល់នាងត្រូវពន្លឺភ្នែកនោះស្រូបទាញ។ហាក់មានសំនួរជាច្រើនណាស់ដែលបញ្ចេញមកតាមពន្លឺភ្នែកនោះ គ្រាន់តែម្ចាស់ប្រុសវាមិនព្រមហារមកទៀតប៉ុណ្ណោះ។ នាងគេចខ្សែភ្នែកមកវិញនៅពេលដង្ហើមទៅជាលោតញាប់។ ម៉េចក៏ស្រាប់តែមានអារម្មណ៍ចម្លែកពេលភ្នែក និងភ្នែកប្រសប់គ្នាដូច្នេះ?

នាងដកភ្នែកដោយនិយាយបន្លប់៖

-ខ្ញុំគ្រាលោកទៅ!

នារីឱនទៅកាន់តែកៀកនឹងទ្រូងនាយដើម្បីជួយគ្រានាយឲ្យក្រោកប៉ុន្តែត្រូវនាយនិយាយបន្ទោសមកវិញតិចៗក្បែរសោតា៖

-ឈឺដៃតើ មិនមែនឈឺជើងទេ!

នាងស្មានថាគេចង់មានន័យថាគេអាចដើរខ្លួនឯងបាន ទើបតរុណីបែរខ្លួនចាកចេញលែងរវល់គ្រាគេ ដឹងអីបុរសជំពប់ស្នេហ៍លូកដៃឆ្វេងក្រសោបនាងពីក្រោយ រួចប្រើកម្លាំងទាញកល្យាណីមកផ្អឹបក្បែរទ្រូងតែម្តង។ នារីក្រៅពីភាន់ភាំងនាងទៅជារើចេញវិញ ប៉ុន្តែនាយក៏មិននៅស្ងៀមដែរ គេផ្អឹបបបូរមាត់ជាប់នឹងត្រចៀកស្រីរូបល្អជាមួយវាចាតម្អូញ៖

-កំពុងឈឺណ៎ា! កុំរើមើល៍!

តរុណីផ្អាកចលនាដោយទឹកមុខឆ្អែឆ្ងា។ នាងកំពុងស្ថិតនៅរវាងចន្លោះចង់បណ្តោយតាមចិត្តគេដែរព្រោះអាណិត តែក៏ភិតភ័យថានឹងទទួលរឿងដូចពីយប់មិញទៀតដែរអត់។ តែវិនាទីនោះរាមនរិន្ទមិនបានបណ្តោយឲ្យរំលងទៅដោយគ្មានប្រយោជន៍ទេ។ គេទ្រេតខ្លួនទទួលយកភាពកក់ក្តៅពីការស្និទ្ធស្នាលជាមួយនារីដែលខ្លួនទន់ចិត្តហើយអ្នកពេញចិត្តណាស់ពេលនាងលែងរើដោយសម្ងំស្ងៀមក្នុងដៃអ្នក។

ភាពសុខសាន្តបណ្តោះអាសន្នរំលងទៅបានតែប៉ុន្មាននាទី ការពិតចំពោះមុខបានលេចឡើងមកវិញក្នុងអារម្មណ៍បុរសម្ចាស់បន្ទប់។

“រាមនរិន្ទ គេមិនស្រលាញ់ឯងទេ!ឯងចង់បានធ្វើស្អីស្នេហារបៀប ដែលមានតែម្ខាងហ្នឹង? ”ការស្តីបន្ទោសនៃសម្បជញ្ញៈមានឥទ្ធិពលឲ្យនរិន្ទងើបមុខចេញពីភាពទន់ជ្រាយដោយរោគបេះដូង។ គេនិយាយមួយៗទៅកាន់មាណវីដែលទ្រោបធ្មេចភ្នែកដោយទុក្ខព្រួយ៖

-ឈប់ចាញ់បោករឿនទៅ! គេអត់បានចាប់លំអងទេ ហើយក៏គ្មានអ្នកណាគិតថារករឿងមីងកុឡាបដែរ! យើងនឹងមានសេរីភាពពេញលេញហើយ! ចង់ចេញពីកន្លែងនេះពេលណាក៏បានដែរ!

នារីបើកភ្នែកដែលពោរពេញដោយជលនេត្រ ល្មមពេលរាមនរិន្ទនិយាយបន្ថែមដោយតឹងទ្រូង៖

-លំអងកំពុងនៅជាមួយKen! ឈប់គិតពីគេទៅ គេគ្មានកើតអីទាំងអស់!

តាមពិតតាំងពីពេលថ្ងៃត្រង់ដែលត្រឡប់មកពីពិធីចេញថ្លៃម្ល៉េះដែលនាយរឿនបានចូលទៅប្រាប់នាងពីរឿងនេះ។ គេបង្ហាញរូបថតហើយសួរនាងថាស្រីក្នុងរូបថតជាលំអងមែនឬអត់? ពេលនោះហើយដែលនាងត្រូវបានគេបកស្រាយឲ្យយល់ថា លំអងមិនបានត្រូវនរណាចាប់ជំរិត ក៏មិនបានបាត់លិខិតឆ្លងដែនអ្វីទាំងអស់។ ស្រស់ស្រីរំលឹកឡើងវិញនូវគ្រាដែលមិត្តនារីខ្លួនតែងតែដាស់តឿនឲ្យខ្លួនទៅជួបរាមនរិន្ទទាំងនៅអាម៉ាន់ដារីរហូតដល់តាមមកចាយ៉ាពូរ៉ា និងចុងក្រោយ លំអងបានបាត់ខ្លួនដោយមិនព្រមនិយាយលាសូម្បីតែមួយម៉ាត់។ នាងចាប់ផ្តើមទទួលអារម្មណ៍ថាហួសចិត្ត។ ហេតុអ្វីភាពល្ងីងជួរចត់ក្នុងជីវិត ដូចគ្នាក្នុងរឿងល្ខោនម្ល៉េះ? បន្ថែមពីលើការឈឺចាប់ដែលទើបតែដឹងពីសារជាតិក្បត់ស្នេហ៍ និងភាពអាត្មានិយមរបស់នាយKen កេតឌីម៉ាកាន់តែយល់ច្បាស់ថាតាំងពីដើមមកនាងជាកូនអុករបស់ប្រុសស្រីពីរនាក់នោះទេប៉ុណ្ណោះ។ បានន័យថាតាំងពីដើមមក គ្មានទេពាក្យថាស្នេហារវាងនាង និងនាយKen។ នាងស្រក់ទឹកភ្នែកពេលនេះមិនមែនសោកស្តាយ ឬឈឺចាប់ចំពោះវិបត្តិបេះដូងទេ តែគឺនាងកំពុងសោយសោកអាណិតខ្លួន ដែលគ្មានទាំងមិត្ត និងគ្មានទាំងម្ចាស់ស្នេហ៍ បែរជាចាញ់បញ្ឆោតគេមកតែលតោលដល់តំបន់ឆ្ងាយយ៉ាងនេះ។

- អត់ទោសឲ្យខ្ញុំណាកេតឌីម៉ា!

នរៈវាចាដោយឱនមកសម្លឹងរង្វង់មុខតូចច្រឡឹង។ នាងមិនចេញស្តីមួយម៉ាត់ តាមចរិតលក្ខណៈស្លូតត្រង់ ដែលកំពុងត្រូវញាំញីដោយការខូចចិត្ត ប៉ុន្តែអ្នកដែលឈឺចាប់មែនទែនគឺរាមនរិន្ទ។ គេពោលបន្ថែម៖

- ស្អែកមានគេជូនយើងត្រឡប់ទៅភ្នំពេញវិញហើយ! តទៅត្រូវចេះគិតពីខ្លួនឯង ហើយរៀនប្រើបញ្ញាផង! ឮអត់?

គេលែងដៃពីរាងកាយនាង ព្រោះមិនចង់បន្តការឈឺចាប់ផ្លូវចិត្តសម្រាប់ការលាបែកនាគ្រានេះទេ។ នរៈបោះជំហានមាំទាំរបស់គេចេញទៅកាន់បន្ទប់ទឹកធ្វើឲ្យនារីរូបល្អតាមសម្លឹងពីក្រោយដោយចម្លែកចិត្ត។ ជាលើកទី១ដែលនាងចាប់អារម្មណ៍ថាគេហាក់ស្រងូត និងបាត់បង់ឫកពាដ៏មានអំណាចដែលធ្លាប់តែធ្វើឲ្យនាងភ័យស្លុត។ គេត្រូវរបួសតែដំណើរនៅតែស្មើ នៅតែសង្ហា គ្មានភាពទន់ជ្រាយ និងគ្មានល្បិចកលទេ។ គេនិយាយតិច ប្រយោគនីមួយៗខ្លី ប៉ុន្តែហេតុអ្វីដូចជាមានបង្កប់នូវភាពឈឺឆ្អាលយកចិត្តទុកដាក់ម្ល៉េះ?។

**ភាគទី២៨**

នាងរវេភ្នែកសម្លឹងទៅរកវ៉ាលិសខោអាវដែលបញ្ឈរចោលនៅជ្រុងម្ខាងដោយដណ្ដឹងសួរក្នុងចិត្ត។

"ដើម្បីតែវត្ថុបុរាណដែលមិនទាន់ទាំងបានឃើញរូបរាងពិតនោះ គេសុខចិត្តចេញទៅកោះស្មៅលឿងដូចពាក្យដែលអង្គរក្សគេបាននិយាយប្រាប់នាងមែន? បើគេរស់ក្នុងអំណាច និងទ្រព្យធនដល់ថ្នាក់នេះហើយ ក៏នៅតែមានចិត្តស្រើបស្រាល និងសម្ភារៈនានាអីដល់ម្លឹងរហូតដល់ប្រមាថទាំងសុខភាពខ្លួនដែលកំពុងទន់ខ្សោយដោយមុខរបួស?"

នារីក្រោកទៅជិតវ៉ាលិសដែលមិនទាន់បានបិទសម្រេចដោយសារកុំព្យូទ័រយួរដៃរបស់គេមិនទាន់ដាក់ចូលហើយចោលនៅម្ខាងក្បែរនោះ។នាងហួសចិត្តដែលអ្នកប្រុសគ្រួសារតំណាងរាស្ត្រមានអ្នកបែហាមឆ្វេងស្ដាំតែមិនមានមនុស្សស្រីតាមបម្រើថ្នាក់ថ្មម ដោយត្រូវរៀបចំសូម្បីតែសម្លៀកបំពាក់ខ្លួនឯង។ នាងលើកកុំព្យូទ័រយួរដៃរៀបចំឲ្យមានសណ្ដាប់ធ្នាប់រួចទើបបិទបញ្ចប់វ៉ាលិសសម្លៀកបំពាក់។

នៅឯណោះបុរសអភិជនសម្ងំត្រាំខ្លួនទៅក្នុងផើងទឹកក្ដៅដែលត្រូវបានសម្រិតសម្រាំងដោយដៃនារីម្ចាស់ចិត្តជាលើកដំបូង និងចុងក្រោយបង្អស់។ អ្នកធ្មេចភ្នែកបន្ទោសខ្លួនឯងរាល់ពេលរំលឹកដល់អំពើហិង្សាដែលបានប្រព្រឹត្តិលើនាងកាលពីរាត្រីម្សិលមិញដោយភ្លើងប្រចណ្ឌ។ បន្ថែមពីភាពរងគ្រោះដោយល្ងោនកេងចំណេញរបស់ស្ត្រីឈ្មោះកុលាប ក្នុងការលះបង់ព្រហ្មចារីឲ្យទៅបុរសដែលខ្លួនមិនដែលស្គាល់ពីមុនមក តើនាងត្រូវឈឺចាប់យ៉ាងណាក្នុងការដែលត្រូវទទួលការប្រមាថកិត្តិយសជាលើកទី២ទៀតនោះ?។

គេបន្ទោសខ្លួនឯងទាំងមិនហ៊ានបើកភ្នែកសម្លឹងជុំវិញខ្លួន៖

"ឯងមានចរិតហិង្សាអញ្ចឹងបានជាគេមិនស្រលាញ់ឯង!"

អ្នកនឹកទៅដល់រាត្រីទីមួយដែលអ្នកបានជួបនាងសាជាថ្មីដោយចៃដន្យនៅកោះបាលី ដោយសន្ទុះចិត្តមានៈចំពោះភាពឆ្មើងឆ្មៃរបស់នាង អ្នកបានអនុញ្ញាតឲ្យកូនចៅប្រើដៃជើងលើស្ត្រីមេអណ្ដើកនៅចំពោះមុខនាងព្រោះមិនដែលគិតថា និងមាននាងក្នុងបេះដូងជ្រៅដល់ថ្នាក់នេះទេ តែសកម្មភាពនោះបានធ្វើឲ្យនាងចាត់បញ្ចូលអ្នកទៅក្នុងចំណោមមនុស្សអាងអំណាច និងសម្ភតស្រីរួចទៅហើយ។ កាន់តែគិត កាន់តែអៀនខ្មាស បុរសអភិជនបណ្ដោយខ្លួនឲ្យធ្មេចភ្នែកគេចចេញពីការបិទរហូតដល់លង់លក់តែម្ដង។ ពេលវេលាកន្លងទៅយូរប៉ុណ្ណាទេ អ្នកស្រាប់តែត្រូវភ្ញាក់ក្រញ៉ាងមកវិញដោយសន្ធឹកគោះទ្វារបន្ទប់ទឹកយ៉ាងរន្ថើន។

រាមនរិន្ទបើកភ្នែកមមីងមមាំង ហើយលើកដៃម្ខាងដែលនៅរុំរបួសនៅឡើយពីក្រៅផើងទឹកមកពិនិត្យមើលមុនពេលផ្ទង់ស្ដាប់ឮសំឡេងស្រែកហៅពីខាងក្រៅ។

-លោកយ៉ាងម៉េចហើយ?

រាមនរិន្ទងាកសម្លឹងជុំវិញខ្លួនដោយមមីមមើ។ គេទើបតែដឹងថាខ្លួនបានលង់លក់ក្នុងផើងទឹករហូតដល់ធ្វើឲ្យស្រីស្រស់ដែលនៅខាងក្រៅនៅឡើយ រង់ចាំយូរហើយស្រមៃផ្ដេសផ្ដាសថាអ្នកអាចនឹងត្រូវរអិលដួលឬសន្លប់តែម្នាក់ឯង។

គេមិនឆ្លើយតបតែច្រត់កាយក្រោកចេញពីទីនោះហើយលើកអាវកន្សែងមកពាក់ទើបបោះជំហានមួយៗចេញមកប្រឈម និងនាង។

កេតឌីម៉ាដែលមានភាពភ័យព្រួយពេញក្នុងរង្វង់ភ្នែកមូលក្រឡង់ តាមសម្លឹងផ្ទៃមុខនរិន្ទឥតព្រិច។ កែវភ្នែកនាងហាក់ចង់សួរ គេស្រេចហើយថា មានរឿងអីបានជានៅក្នុងនោះយូរដល់ថ្នាក់នេះ។

បុរសដែលផ្ទៃមុខទៅជាហើមពោរដោយលង់ក្នុងដំណេក និងភាពនឿយហត់ហួសហេតុផងនោះ រេភ្នែកគេចេញពីក្រសែភ្នែកនាង។

គេដើរទៅរកក្បែរទូភេសជ្ជៈដោយចោលសំនួរកំបុតកំបុយៈ

-អត់ទាន់ទៅទេ?

នារីដឹងហើយថាគេចង់ឲ្យនាងចេញទៅរៀបអីវ៉ាន់សម្រាប់ត្រឡប់ទៅភ្នំពេញនៅព្រឹកស្អែក តែចំណែកនាងបានសម្រេចចិត្តហើយថាមិនទៅចោលគេក្នុងស្ថានភាពនេះដោយសារហេតុផលពីរ ទី១ គឺអ្នកណាធ្វើឲ្យគេរបួសអ្នកនោះត្រូវតែមានភារៈមើលថែគេ ហើយទី២គឺនាងនៅជំពាក់គេចំពោះរឿងដែលធ្វើឲ្យបែកការណ៍ដំណើរមកកាន់ចាយ៉ាពូរ៉ា និងបេសកកម្មឥន្ទ បដិមារបស់គេ។

រយៈពេលដែលបុរសសង្ហានៅត្រាំ ទុក្ខកង្វល់ក្នុងទឹកក្ដៅឧណ្ហៗរបស់គេនៅខាងក្រៅ នារីបង្ហាញម៉ូតបាននឹកឃើញដល់រាត្រីកាលនៅអាម៉ាន់ដារី ទីដែលនាងដេកសន្លប់ឈឹងតែត្រចៀកបានស្ដាប់ឮគ្រប់របាយការណ៍របស់នាយវឿន និងបានបន្តរាយការណ៍ព័ត៌មានទាំងនោះទៅនាយKenដោយសារឆោតល្ងង់ និងជឿសម្ដីពាណិជ្ជករដែកថែបហួសហេតុ។

នាងយល់ថានាងបានជំពាក់បំណុលមួយនៅទីនេះបន្ថែមពីលើបំណុលដែលមីងកុឡាបបានសាងឲ្យ។ នាងទៅក៏មិនមែន ជាជម្រើសគប្បី និងសម្បជញ្ញៈដែរ។

ភេសជ្ជៈពណ៌ឈាមជ្រូកចាស់ដ៏ពេញនិយមរបស់ពលរដ្ឋអាមេរិកាំង ត្រូវបានឃាត់បង្អាក់ដោយដៃសល្វក់របស់ស្រីស្រស់ជំនួសមកវិញនូវកែវទឹកក្រូចស្រស់ដូចដែលនាងបានរៀបចំឲ្យអ្នកម្ដងរួចមកហើយកាលពីព្រឹកមិញ។

-ឈឺថ្នាក់នេះហើយនៅរកកូកាទៀត?

នាងរុញវាទៅម្ខាងហើយដាក់កែវទឹកក្រូចស្រស់ទៅក្នុងប្រអប់ដៃឆ្វេងនាយ។ នរៈបានចិត្តលើកវាមកក្រេបយ៉ាងឆ្ងាញ់ពិសា តែមិនមែនដោយសាររសជាតិផ្អែមចាប់មាត់របស់ផ្លែផល្លាទេ ប៉ុន្តែដោយសារមន្តស្នេហ៍ម្ចាស់វា។

គេបញ្ចប់វាហើយក៏ងាកទៅញាក់ចិញ្ចើមដាក់នាង ក្នុងន័យថាអស់ហើយ?

តែនារីក៏មិនឆ្លើយ នាងបែរក្រោយទៅលើកចានបបរពីថាសម្ហូបមកបន្ត។ រាមនរិន្ទដឹងថានាងចង់បម្រើអ្នក ប្រហែលដោយសារដឹងគុណរឿងជួយជីវិតកាលពីនៅពិធីដេញថ្លៃ ប៉ុន្តែដែលអ្នកចង់បានមិនមែនការសងគុណទេគឺចង់ឲ្យនាងធ្វើដោយសេចក្ដីស្នេហា។ ទោះយ៉ាងណាក្រពះដែលសំចតអស់ពេញមួយថ្ងៃពិតជាទាមទារហើយ គេមានរឿងអីមិនព្រមទទួលយកសុភមង្គលនេះ។ គេញញឹមដាក់នាង រួចសម្លឹងភ្នែកនាងដែលស្រទន់ហើយស្មោះត្រង់។ យ៉ាងហោចណាស់ក៏មិនមែនធ្វើឡើងដោយបង្ខំចិត្តដូចបាយពេលល្ងាចនៅAmandari ដែរ។

គេថយទៅអង្គុយលើសាឡុង ហើយរង់ចាំមើលកាយវិការស្រីស្អាតដែលដួសបបរមកបញ្ចុកខ្លួន។ រសជាតិបបរមិនស្មើនឹងភាពមនោរម្យដែលគេកំពុងមានទេ។ គេនឹកក្នុងចិត្តស្ងាត់ៗ៖

"រាមនរិន្ទ! បើកុំតែឯងរបួសដៃស្ដាំ ប្រហែលជាមិនបានទទួលអំណោយដ៏ផ្អែមនេះទេមើលទៅ?"

នារីធ្វើការប្រតិបត្តិបុរសនៅចំពោះមុខដោយស្ងាត់ស្ងៀម រហូតដល់ឮគេលើកសំនួរមកមុន៖

- ទៅវិញ នឹកគ្នាខ្លះអត់?

នារីសំឡេងស្លាបព្រាបបរជំនួសឲ្យប្រសព្វទៅនឹងកែវភ្នែកគេ។ នាងនិយាយស្ទើៗ៖

- ខ្ញុំទៅកោះស្មៅលឿងជាមួយលោក!

នរៈអរព្រើត ទន្ទឹមនឹងសំឡេងនាងលាន់មកបន្ត៖

- ដៃលោករបួសអត់ស្រាលទេ! កុំធ្វើអីខ្លួនឯងទៀត ចង់បានអីខ្ញុំនៅចាំធ្វើជំនួស!

គេធ្លាក់ទឹកចិត្តមកវិញព្រោះដឹងថានាងព្រមទៅកោះនោះបន្ត ព្រោះតែរឿងរបួសដៃនេះឯង។ គេប្រែទឹកមុខទៅជាស្មើធេង ហើយងាកចេញលែងទទួលបបរស្លាបព្រាចុងក្រោយថាឆ្អែតហើយ។

នរៈក្រោកឈរហើយនិយាយស្រាលៗ៖

-មិនបាច់ទៅទេកេតឌីម៉ា! កន្លែងហ្នឹងសមតែជាមួយប្រុសៗទេ!

នាងប្រមូលចាន និងកែវហើយក្រោកឈរមកទល់មុខនឹងនាយ សម្លឹងនាយផងមាត់ធីតាយើងតបផង។ ទឹកមុខនាងម៉ត់ចត់បញ្ជាក់ថាមិនមែននិយាយលេងទេ៖

-លោកឈឺដៃហើយ! គួរតែមានអ្នកជួយបោកគក់ ដាំទឹកក្ដៅទឹកត្រជាក់ដែរ! រឿងទាំងអស់ហ្នឹងមិនសមឲ្យប្រុសៗធ្វើទេ!

នរៈគេនិយាយបញ្ឆោះបន្សោកទៅនាងវិញ៖

-ចុះយើងម៉េចដឹងថាខ្ញុំអត់មានស្រីៗទៅជាមួយ? ស្រីៗជនជាតិថ្វានៅឯហ្នេះសម្បុរសៗដូចសំលីមានទៅខ្វះអី?

កេតឌីម៉ាប្រែទឹកមុខទៅជាខឹង នាងសម្លឹងគេដោយក្រសែភ្នែកមិនសប្បាយចិត្ត ធ្វើអោយអ្នកប្រុសបានចិត្តញញឹមបញ្ឈឺនិងញាក់ចិញ្ចើមតបឌឺដងផង។

ស្រី ស្រស់បែរក្រោយដើរចេញទៅរឹងដោយដំណើរក្អឹកក្អក់....

----------------------------

.....សត្វ រាត្រីចរលាន់យំកំដររាត្រីចុងក្រោយរបស់ក្រុមអ្នកស្វែងឥន្ទ បដិមានៅចាយ៉ាពូរ៉ា។ នៅក្នុងសួន ផ្កាក្រអូបឆ្ងួល ស្រីស្រស់ប្រមុខកិន្នរីហ្វេស្សិនឈរឱបដៃដោយទឹកមុខមិនសប្បាយចិត្ត។

នាងនិយាយទៅកាន់អង្គរក្សខ្ពស់ស្រាវដែលកំពុងអង្គុយហូបបរពីក្រោយខ្នងក្បែរតុផ្តៅ។

- អ្នកប្រុសធំរបស់លោកមិនត្រូវការឲ្យខ្ញុំទៅទេ! លោកចាំបាច់មកខំនិយាយម្តងជាពីរដងធ្វើអី រឿន? បុរសនោះនៅតែជាប់ចិត្ត និងអាហារពេលយប់មិនរវល់តប និងសកម្មភាពខឹងសម្បាររបស់នាងឡើយ។ ធ្វើឲ្យនាងនៅតែនិយាយបន្តម្នាក់ឯង៖

- ពួកលោកត្រូវចេញទៅសមុទ្រពីព្រឹកផង! រឿងទៅប្រលានយន្តហោះ ខ្ញុំអាចទៅខ្លួនឯងបាន! កុំបាច់ខ្វល់អី! ខ្ញុំចូលទៅរៀបចំហើយ!

រឿនងើបមុខនិយាយបណ្តើរដៃដួសបបរដាក់ចានបន្ថែមបណ្តើរ៖

- នាងមិនទៅបានអ្នកណាមើលថែអ្នកប្រុសឌីម៉ា? កោះហ្នឹងឆ្ងាយដាច់សង្វែង គ្មានចុងភៅគ្មានអ្នកតែលទេ! បាយពីរពេលក៏ប្រហែលជាពិបាករកផង! នាងដាច់ចិត្តដែរ?

ឌីម៉ាបង្ហាញទឹកមុខងក់ងរ នាងតបភ្លាមមិនបង្អង់៖

- គេមានស្រីៗជនជាតិថៃជាច្រើនចាំបម្រើហើយ!

នាងបែរខ្លួនចាកចោលនាយអង្គរក្សដែលខំណាត់នាងចេញមកនិយាយពីដំណើរទៅកោះស្មោលឿង។ ប៉ុន្តែទើបដើរបានមួយជំហាននាងឮនាយអង្គរក្សដែលធ្លាប់តែសោះកក្រោះសើចខឹកៗ។ សំណើចដែលហាក់មានន័យបញ្ឆោះធ្វើឲ្យនាងមិនអស់ចិត្តទ្រឹងដំណើរហើយងាកមកសួរ៖

- មានអីអស់សំណើច?

រឿននិយាយតបដោយបបរនៅពេញក្នុងមាត់៖

- នាងចេះប្រចណ្ឌដែរអ្នកគ្រូឌីម៉ា?

កេតឌីម៉ាប្រែទឹកមុខទៅជាអៀនលាយខឹង។ នាងចង់បដិសេធការគិតផ្តេសផ្តាសនេះ ប៉ុន្តែនិយាយស្តីទៅជាចាប់ចុងប្រយ៉ុងដើម៖

- អត់..អត់...ទេ!អ្នក...អ្នក....អ្នកណាប្រចណ្ឌ?

អង្គរក្សឆ្លាតវៃនិយាយបន្ថែម៖

- ទឹកមុខនាងនិយាយឲ្យខ្ញុំដឹង! នាងគិតថាលោកប្រុសរាមទៅស្រលាញ់ស្រីៗជនជាតិថៃអស់ហ្នឹងអ្ហី?

នាងនៅស្ងៀមប៉ុន្តែតាមពិតគឺសម្ងំស្តាប់។ នាយអង្គរក្សក្រោកឡើងមកជិតនាងជាមួយចានបបរក្នុងដៃ៖

- ហើយបបរមាន់នេះក៏ពិបាករកអ្នកធ្វើដែរ! បើនាងមិនទៅជាមួយពួកខ្ញុំ ចុះពេលអ្នកប្រុសចង់បានបបរនេះទៀត បានអ្នកណាធ្វើ?

នារីគ្មានពេលសម្តាប់សម្តីបុរសអង្គរក្សទេ ប៉ុន្តែនាងកំពុងគិតម្នាក់ឯងដោយអៀនខ្មាស។

"ម៉េចក៏យើងឮគេនិយាយពីស្រីៗឥណ្ឌូណេស៊ីភ្លាម ស្រាប់តែខឹងខ្នាញ់ក្នុងចិត្ត? យើងប្រចណ្ឌដូចដែលអង្គរក្សគេកំពុងនិយាយជាន់កែងយើងមែនទេដឹង? អត់ទេ? យើងមានអីទាក់ទងនឹងគេបានជាត្រូវខឹងសម្បារគ្រាន់តែគេរំលឹកពីស្រីផ្សេងនោះ!"។

នាងបែរក្រោយនិយាយមួយៗដោយរក្សាឫកពារិលទៅរកសភាពដើម៖

- បើលោកមិនចង់ឲ្យចៅហ្វាយលោកពិបាក ម៉េចមិនឃាត់គេកុំឲ្យទៅកន្លែងនោះទៅ!

រឿនប្រែទឹកមុខទៅជាស្មើ។ គេនិយាយមួយៗ៖

- ចំពោះរឿងតន្ទបដិមា! គ្មានអ្នកណាអាចឃាត់អ្នកប្រុសរាមបានទេ!

នារីរវើរវាយ្នែកសញ្ជឹងគិត។ នាងនឹកឃើញភ្លាមដល់គ្រាដែលបុរសមកពីត្រកូលអ្នកនយោបាយបានទាញនាងចេញផុតពីបរិវេណគ្រោះថ្នាក់កាលពីព្រឹកនៅ Winter JayaPura ទីបំផុតគេនៅតែបកក្រោយចូលទៅរកម្ចាស់វត្ថុបុរាណនោះវិញ បើទោះជាមនុស្សជំនិត និងនាងផ្ទាល់បានសុំកុំឲ្យគេទៅក៏ដោយ។

ភ្លាមនោះដែរនាងក៏នឹកឃើញដល់នាយKen។ បុរសដែលនាងបានស្រលាញ់ដោយបេះដូង និងព្រមធ្វើគ្រប់យ៉ាងដើម្បីគេ។ ទីបំផុតនាងទើបតែយល់ថាគេបង្កើតគម្រោងការច្រើនយ៉ាងនេះ រួមទាំងស្នេហាក្លែងក្លាយជាមួយនាងផង សុទ្ធតែដើម្បីវត្ថុបុរាណនោះតែប៉ុណ្ណោះ។ស្រីស្រស់ឱនមុខទប់ទល់ និងអារម្មណ៍ទោមនស្ស។

-កេតឱម៉ា!នាងមិនមែនល្ងង់ដល់ថ្នាក់មិនយល់ពីចិត្តអ្នកប្រុសដែលមានលើនាងទេមែនទេ?បើនាងមិនទាន់មានអ្នកណា ហើយបើនាងក៏មានចិត្តអោយលោកខ្លះដែរ ខ្ញុំសុំនាងអោយតាមជាកម្លាំងចិត្តលោកផងបានដែរអត់?

ធីតារូបល្អកាន់តែក្តុកក្តួលចិត្តកាលបើស្តាប់លឺប្រយោគត្រង់ៗគ្មានលាក់លៀមនិងគ្មានពន្យាពេលរបស់នាយអង្គរក្ស។

"ដោយសារតែបដិមានោះប៉ុណ្ណោះ យើងត្រូវបានលំអងនិងអ្នកមានឈ្មោះKenរួមដៃគ្នាបោកប្រាស់!បើថ្ងៃណាមួយនាងអង្គរក្សដឹងថាយើងធ្លាប់ជាមិត្តស្រីរបស់ពាណិជ្ជករដែកថែបគូរបដិបក្ខរបស់ គេ តើគេគិតយ៉ាងណាចំពោះយើង?ចំណែកថា យើងជាកម្លាំងចិត្តដល់អ្នកប្រុសរាមនរិន្ទរបស់គេនោះ ជារឿងស្មានព្រាវៗប៉ុណ្ណោះ ។គ្មានបុរសអ្នកមានណាមកស្រលាញ់មនុស្សស្រីគ្មានថានៈគ្មានតួនាទីដូចយើងទេ !នាយKenគឺជាឧទាហរណ៍ជាក់ស្តែង។គេទន់ភ្លន់ជាមួយយើងថ្នាក់ហ្នឹងនៅតែទីបំផុតជាមនុស្សអាក្រក់ ចំណែកអ្នកប្រុសរបស់លោក ហឹង្សាបែណាក៏ធ្លាប់ប្រើចំពោះយើងដែរ !គេមានលាក់ទុកនូវជម្រៅចិត្តអី ដែលយើងគួរស្វែងយល់នោះ?"

នាងមិនខ្វីរវល់នៅរេរាច្រើននាំតែត្រូវបុរសនោះស្មានកាន់តែផ្តាស់ ទើបស្រវាចាកចេញពីទីនោះវិញភ្លាមដោយអត់ចេញស្តីមួយម៉ាត់។

មកដល់ក្នុងបន្ទប់តុរុណីស្រវារៀបចំសម្លៀកបំពាក់សារជាថ្មី ញាប់ដៃញាប់ជើងហាក់មិន ចង់គិតពីរឿងអ្វីទៀតទាំងអស់ប៉ុន្តែនៅពេល រៀបចំចប់នាងនៅអង្គុយស្ញៀមសម្លឹងវា។

"កេតឪមាអើយកេតឪម៉ា បើឯងមិនទៅភ្នំពេញមានតែល្ងង់បំផុតហើយ?"

នាងងាកទៅម្ខាងក៏ឃើញអាវពណ៌ត្រួយចេកខ្ចីដែលដាច់ដោចអស់ដោយសារឧប្បត្តិហេតុនៅសណ្ឋាគារWinter Jayapura។នាងលូកដៃទៅទាញអាវនោះព្រមពេលដែលទិដ្ឋភាពគ្រោះថ្នាក់នៅឯជណ្តើរឈើអណ្តែតមកវិញក្នុងកែវភ្នែក។

"បើពេលនោះរាមនរិន្ទមិនរវល់នឹងយើងម្នាក់ទៀត យើងប្រាកជាគ្មានពេលមកអង្គុយអញ្ចឹងទេ។គេមិនត្រឹមផ្សងគ្រោះថ្នាក់រត់ត្រឡប់ទៅជាន់លើរកកាំបិតមកជួយយើង ថែមទាំងរងកំណាត់ឈើជំនួសយើងរហូតដល់របួសដៃទៀត!ហេតុអីគេចាំបាច់ធ្វើដល់ម្លឹងដើម្បីយើង?"

រំពេជនោះនាងក៏នឹកឃើញដល់បុរសបោកប្រាស់ដែរ។ទេកមុខត្រជាក់គ្មានឈាមរបស់គេធ្វើអោយនាងមានអារម្មណ៍ដូចត្រូវចាក់នឹងមុខកាំបិត។តាំងពីដើមដល់ចប់គឺនាងត្រូវគេបោកប្រាស់ វាល្អហើយដែលនាងមិនដែលព្រមស្និទ្ធស្នាលជាមួយគេ ហើយគេក៏ប្រហែលជាមិនហ៊ានបង្ខំនាងដោយសារតែទុកនាងប្រើក្នុងស្រោមជាសុភាពបុរសដូច្នេះឯង។ទោះយ៉ាងណាសម្រាប់បេះដូងស្រីខ្មែរម្នាក់នេះ ការខូចចិត្តក៏គ្រាន់បើជាងខូចប្រាណដែរ។

នាងខាំមាត់តាំងចិត្តថាតទៅឈប់ជាជឿបុរសណាទៀតហើយ ហើយទទួលស្គាល់ថានាងពិតជាមានភាពឆោតល្ងង់សម្រាប់អោយអ្នកផងកេងចំណេញ សូម្បីតែមិត្តភក្តិដែលនាងបានស្រលាញ់ប្តូរផ្តាច់ក៏ដោយ។

មកដល់ត្រង់នេះនាងនឹកឃើញសម្តីរាមនរិន្ទនៅជាន់ខាងលើ"ស្អែកមានគេជូនយើងត្រឡប់ទៅភ្នំពេញវិញហើយ!តទៅត្រូវចេះគិតពីខ្លួនឯង ហើយរៀនប្រើបញ្ញាផង!លឺអត់?"

សម្តីគេ បានន័យ ថាគេក៏ដឹងដែរថានាងជាស្រីល្ងង់ណាស់ ល្ងង់ដល់ថ្នាក់ គួរអោយស្អប់ខ្លួនឯង។

ចុះគេខ្លួនឯងដែលតាំងចិត្តថាជាអ្នកឆ្លាតនោះមានដឹងដែរទេថា ពាណិជ្ជករដែកថៃបដែលចាប់រលាក់ដៃនិងហៅគេថាបងពេញមាត់ៗតាមពិតកំពុងលាក់កាំបិតប្រុងចាក់គេពីក្រោយខ្នង?

នាងក្រោកឃើតៗទៅរកទ្វារបន្ទប់ដោយមិនដឹងខ្លួន។

(នៅមានត)